ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គណៈកម្មការការិយាល័យបោះឆ្នោត
## និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) និង
## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)
## សម្រាប់
## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត
## ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
## អាណត្តិទី៤ ឆ្នាំ២០២៤

ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤

# មាតិកា


**គោលបំណង** ........ ១

**ផ្នែកទី១**

**គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ)**

I. **គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត** ........ ២

១. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ២

ក. សមាសភាព ........ ២

ខ. ភារកិច្ច និងការទទួលខុសត្រូវ ........ ២

២. ភ្នាក់ងារសន្តិសុខបោះឆ្នោត ........ ២

ក. សមាសភាព ........ ២

ខ. ភារកិច្ច ........ ២

II. **ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត** ........ ៣

១. បរិវេណខាងក្នុង ........ ៣

២. បរិវេណខាងក្រៅ ........ ៣

៣. វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ........ ៣

ក. វិធានការរួមសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ........ ៣

ខ. វិធានការសម្រាប់ការិយាល័យបោះឆ្នោត ........ ៤

គ. វិធានការសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត ........ ៥

ឃ. វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ........ ៥

III. **ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត** ........ ៥

១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប ........ ៥

២. ការទទួល និងការត្រួតពិនិត្យសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ........ ៦

ក. សម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប ត្រូវទទួលពី គធ.ខប ........ ៦

ខ. ការត្រួតពិនិត្យសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ........ ៨

គ. ក្រោយការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត ........ ៩

ឃ. ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត ........ ៩

៣. ការពិនិត្យទីតាំងការិយាល័យបោះឆ្នោត ........ ១០

៤. ការប្រើប្រាស់បញ្ជីបោះឆ្នោត ........ ១០

IV. **ឯកសារប្រើប្រាស់ផ្លូវការសម្រាប់ការបោះឆ្នោត** ..................... **១១**
V. **ការប្រព្រឹត្តទៅនៃការបោះឆ្នោត** ..................... **១១**
១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ..................... ១២
ក. ការរៀបចំសម្ភារ ឯកសារបោះឆ្នោតតាមគំរូប្លង់ ..................... ១២
ខ. ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ..................... ១៣
២. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ ព្រឹកដល់ម៉ោង ៦:៣០នាទីព្រឹកនៃថ្ងៃបោះឆ្នោត ..................... ១៤
៣. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០នាទីព្រឹកដល់ម៉ោង ៧:០០ ព្រឹកនៃថ្ងៃបោះឆ្នោត ..................... ១៥
ក. ការពិនិត្យកញ្ចប់សន្លឹកឆ្នោត ..................... ១៥
ខ. ការត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ ..................... ១៦
៤. ភារកិច្ចរបស់ គ.ក.ប នៅពេលបោះឆ្នោតចាប់ពីម៉ោង ៧:០០ ព្រឹកដល់ម៉ោង ១៥:០០ ..................... ១៦
៥. ការងាររបស់ប្រធាន គ.ក.ប ក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត ..................... ២១
ក. ករណីអ្នកបោះឆ្នោតមានម្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ..................... ២១
ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ..................... ២១
គ. ករណីអ្នកបោះឆ្នោតអះអាងថា មិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ..................... ២២
ឃ. ករណីអ្នកបោះឆ្នោតណាម្នាក់បម្រុងស៊កសន្លឹកឆ្នោតលើសពី ១សន្លឹក ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត ..................... ២២
ង. ករណីអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន ..................... ២២
ច. ករណីអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ..................... ២២
ឆ. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្សនយោបាយ ..................... ២៣
ជ. ករណីអ្នកបោះឆ្នោតធ្វើឱ្យសន្លឹកឆ្នោតខូច ឬធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ដោយអចេតនា ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយ តែបានប្ដូរចិត្តវិញ ..................... ២៤
ឈ. ករណីមានការជំទាស់ ឬការតវ៉ាពីភ្នាក់ងារគណបក្សនយោបាយ ..................... ២៤
ញ. ករណីមានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត (ទោះបីនៅក្នុងការិយាល័យបោះឆ្នោតក្ដី ឬកំពុងឈរជាជួរនៅក្នុងបរិវេណខាងក្នុងក្ដី) ..................... ២៥
ដ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលធ្វើឱ្យអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ..................... ២៥
ឋ. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ១៥:០០ ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ..................... ២៥
ឌ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬការគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬ/និងក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត ..................... ២៦

VI. **ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត** ........ ២៨
១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ២៩
ក. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច ........ ២៩
ខ. រូបមន្តនៃការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ៣០
គ. កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងការប្រើប្រាស់ ........ ៣០
ឃ. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «កស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ... ៣១
២. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ........ ៣២
VII. **ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត** ........ ៣២
១. ការចាត់ចែងរៀបចំ ........ ៣៣
២. វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី ដើម្បីចង់ដឹងអ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ........ ៣៤
៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ........ ៣៤
ក. សន្លឹកឆ្នោតបានការ ........ ៣៤
ខ. សន្លឹកឆ្នោតមិនបានការ ........ ៣៤
៤. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការវេចខ្ចប់ ........ ៤៣
ក. ការរៀបចំសម្ភារ ឯកសារបោះឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ៤៣
ខ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ........ ៤៩
៥. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ការវេចខ្ចប់ និងការបញ្ជូនទៅ គធ.ខប ........ ៥១
៦. ការវេចខ្ចប់ស្បោង «ខ₂» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ........ ៥២
៧. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ........ ៥៣
៨. ការបញ្ជូនស្បោង «ខ» នៃប្រភេទក្រុមប្រឹក្សានីមួយៗ និងស្បោងដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គធ.ខប ........ ៥៣
VIII. **ការរាប់សន្លឹកឆ្នោតនៅ លគធ.ខប ឬនៅទីកន្លែងមានសុវត្ថិភាពដែល គ.ជ.ប បានកំណត់** .. ៥៤

## ផ្នែកទី២
## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)


I. **គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត** ..... ៥៥

១. សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប ..... ៥៦

២. សមាសភាព គធ.ខប និង លគធ.ខប ..... ៥៧

៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប ..... ៥៧

II. **ការទទួលសម្ភារ ឯកសារបោះឆ្នោតពី គ.ជ.ប** ..... ៥៩

១. សម្ភារ ឯកសារបោះឆ្នោតសម្រាប់ គធ.ខប ..... ៥៩

២. សម្ភារ ឯកសារបោះឆ្នោតដែល គធ.ខប ត្រូវបញ្ជូនបន្តទៅ គ.ក.ប ..... ៦០

III. **ការប្រមូលនិងការបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោតដើម្បីបញ្ជូនទៅគ.ជ.ប** ... ៦០

IV. **ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទៅ គធ.ខប** ..... ៦១

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ)នៃច.ប.ក ..... ៦១

២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់នឹងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ..... ៦១

ក. ការដាក់ពាក្យបណ្តឹង ..... ៦១

ខ. ការទទួលពាក្យបណ្តឹង ..... ៦២

គ. ការដោះស្រាយពាក្យបណ្តឹងដែលគោរពរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់ ..... ៦៣

V. **ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅ លគធ.ខប** ..... ៦៦

១. ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ..... ៦៦

២. វិធានការសន្តិសុខ សុវត្ថិភាពនៅមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប ..... ៦៦

៣. សមាសភាពក្រុមត្រួតពិនិត្យ និងក្រុមកំណត់បែងចែកអាសនៈ ..... ៦៧

៤. ការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ លគធ.ខប ..... ៦៧

ក. ពេលត្រួតពិនិត្យ ..... ៦៧

ខ. ក្រោយពេលត្រួតពិនិត្យ ..... ៦៨

VI. **កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ..... ៦៨

១. កិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ..... ៦៨

ក. សម្ភារ ឯកសារបោះឆ្នោតសម្រាប់ប្រើប្រាស់ ..... ៦៨

ខ. ការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្នក្នុងករណីការិយាល័យណាគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬមានពាក្យបណ្តឹង ប៉ុន្តែមិនបើកកញ្ចប់សុវត្ថិភាព «ក» ..... ៦៩

គ. ការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ហើយត្រូវបាន គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «កស» ......... ៧១
ឃ. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹង ......... ៧១
២. កិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ......... ៧៤
ក. សម្ភារ ឯកសារបោះឆ្នោតសម្រាប់ប្រើប្រាស់ ......... ៧៤
ខ. នីតិវិធីនៃការត្រួតពិនិត្យ ......... ៧៥
៣. ការពិនិត្យ និងសម្រេចលើតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៦តព) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១១) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ) ដោយ គធ.ខប ......... ៧៦
៤. ការប្រើប្រាស់តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៦តព) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១១) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ) ......... ៧៦
**VII. ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ......... ៧៧**
១. ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សាសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ......... ៧៧
២. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលអាសនៈ ឬ/និងជាប្រធានក្រុមប្រឹក្សា ......... ៧៨
ក. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយត្រូវទទួលបានអាសនៈ ......... ៧៨
ខ. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយត្រូវទទួលបានជាប្រធានក្រុមប្រឹក្សា ... ៧៨
៣. ការពិនិត្យសម្រេច និងប្រើប្រាស់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៤) ដោយ គធ.ខប ......... ៧៩
**VIII. ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅ គ.ជ.ប ......... ៧៩**
១. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» ......... ៧៩
ក. ការវេចខ្ចប់កញ្ចប់ «ឃ$_{ស}$ ពិសេស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ......... ៧៩
ខ. ការវេចខ្ចប់កញ្ចប់ «ឃ$_{ខ}$ ពិសេស» នៃក្រុមប្រឹក្សារាជធានី ខេត្ត ......... ៨១
២. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» នៃក្រុមប្រឹក្សាដែល គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្នលទ្ធផលនៃការបោះឆ្នោត ......... ៨២
៣. ការវេចខ្ចប់ស្បោង «ឃ$_{ស}$» និង «ឃ$_{ខ}$» ......... ៨៣
៤. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ......... ៨៥

៥. ការបញ្ជូនកញ្ចប់ «ឃ ពិសេស» ស្បោង «ឃ» និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គ.ជ.ប .. ៨៥

IX. **ការបោះឆ្នោតសាជាថ្មី** ..... **៨៥**

១. ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ..... ៨៥

ក. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងមុនថ្ងៃបោះឆ្នោត ..... ៨៥

ខ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងនៅថ្ងៃបោះឆ្នោត ..... ៨៥

២. ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និងដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ឬ/និងលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គ.ជ.ប ..... ៨៦

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤. | ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ក្រុមប្រឹក្សា |
| ៥. | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៦. | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៧. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ក |
| ៨. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៩. | ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត | ច.វ.ច.ប |
| ១០. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ប.ន.ក |
| ១១. | នាយកដ្ឋាន | ន. |
| ១២. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១៣. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

ក្នុងគោលបំណងឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានាថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០២៤ ប្រព្រឹត្តទៅប្រកបដោយភាពរលូន ត្រឹមត្រូវតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ក) និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ប.ន.ក) គ.ជ.ប បានរៀបចំចងក្រងសៀវភៅណែនាំ គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) និងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ដែលមាន ២ផ្នែក គឺ ផ្នែកទី១ ណែនាំការងារ គ.ក.ប/គ.ក.រ និងផ្នែកទី២ ណែនាំការងារ គធ.ខប ដើម្បីឱ្យមន្ត្រីបោះឆ្នោតពាក់ព័ន្ធនឹងការងារនេះអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន តាមនីតិវិធីឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សៀវភៅណែនាំនេះ ជាសេចក្ដីពន្យល់អំពីបច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍លើចំណុចសំខាន់ៗនៃកិច្ចប្រតិបត្តិការបោះឆ្នោត រាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការបញ្ជូនរាល់សម្ភារ ឯកសារបោះឆ្នោតតាមលំដាប់លំដោយនៃការងារ។

គ.ក.ប/គ.ក.រ និង គធ.ខប ត្រូវយកចិត្តទុកដាក់សិក្សា ស្វែងយល់តាមខ្លឹមសារនៃសៀវភៅណែនាំនេះ ដើម្បីតម្រង់ទិសដៅ និងជំរុញការអនុវត្តបច្ចេកទេសជាក់ស្ដែងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងការត្រួតពិនិត្យបូកសរុបលទ្ធផលនៃការបោះឆ្នោតឱ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងសម្រេចបានជោគជ័យ។

សៀវភៅណែនាំនេះក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួននៅក្នុងការសង្កេតមើលដំណើរការបោះឆ្នោត។

# ផ្នែកទី១

## គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ)

### I. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោត

**១. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

គ.ក.ប/គ.ក.រ ជាគណៈកម្មការដែលមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខ្លួនទទួលខុសត្រូវ។

**ក. សមាសភាព**

គ.ក.ប មានសមាសភាពចំនួន ៦រូប ដែលរួមមានៈ

- ប្រធាន ១រូប
- អនុប្រធាន ១រូប
- លេខាធិការ ១រូប
- សមាជិក ៣រូប

គ.ក.ប នឹងក្លាយទៅជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត (គ.ក.រ) នៅពេលរាប់សន្លឹកឆ្នោត។

**ខ. ភារកិច្ច និងការទទួលខុសត្រូវ**

សមាសភាព គ.ក.ប/គ.ក.រ ទាំងអស់ត្រូវចូលរួមវគ្គបណ្តុះបណ្តាល រួចម្ចាស់ការចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យរាល់កិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យដែលខ្លួនទទួលខុសត្រូវ។ ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ក.ប/គ.ក.រ មានចែងលម្អិតនៅក្នុងសកម្មភាពជាក់ស្តែងនៃដំណាក់កាលនីមួយៗក្នុងសៀវភៅណែនាំនេះ។

**២. ភ្នាក់ងារសន្តិសុខបោះឆ្នោត**

**ក. សមាសភាព**

នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតមានចំនួនមិនលើសពី ៣នាក់ ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខបោះឆ្នោត នៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែមួយដាច់តែឯង។ ចំណែកឯការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើនប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការិយាល័យនីមួយៗ ត្រូវមានចំនួនសមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងសន្តិសុខជាក់ស្តែង។

**ចំណាំៈ**

- ភ្នាក់ងារសន្តិសុខបោះឆ្នោតអាចជានគរបាលជាតិ ឬយោធិននៃកងយោធពលខេមរភូមិន្ទ ឬប្រជាការពារ
- ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវស្លៀកពាក់ឯកសណ្ឋានតាមប្រភេទនៃកងកម្លាំងនីមួយៗឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច។

**ខ. ភារកិច្ច**

ភ្នាក់ងារសន្តិសុខបោះឆ្នោតមានភារកិច្ចការពារកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬហេតុការណ៍អសន្តិសុខផ្សេងៗ ដែលអាចនឹងកើតមាន ដោយហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗចូលក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## II. ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខសម្រាប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

ការិយាល័យបោះឆ្នោតដែលត្រូវបានកំណត់ និងផ្តល់សុពលភាពជាការិយាល័យបោះឆ្នោតផ្លូវការដោយ គ.ជ.ប ហើយ នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត។

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវរៀបចំឱ្យមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។

**១. បរិវេណខាងក្នុង**

បរិវេណខាងក្នុង គឺជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារ ដែលការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។

**២. បរិវេណខាងក្រៅ**

បរិវេណខាងក្រៅ គឺជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែង ១០០ម៉ែត្រ ឬតូចជាង ស្របតាមស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈជាដើម។

**ចំណាំ៖**

- នៅទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គធ.ខប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ
- នៅទីប្រជុំជនណាដែលមានបញ្ហាអសន្តិសុខ និងខ្វះសណ្តាប់ធ្នាប់ដែលអាចរំខានដល់ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត គ.ក.ប/គ.ក.រ ត្រូវបង្កើតបរិវេណសន្តិសុខនៅបរិវេណខាងក្រៅទាំងមូល ឬផ្នែកណាមួយនៃបរិវេណខាងក្រៅនោះ។

**៣. វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់**

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ក ។

**ក. វិធានការរួមសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត**

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម៖

- ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- ហាមយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិណាម្នាក់ក្នុងឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត ឬ/និងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើម ឬ/និងក្រោយពេលបិទការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។

**ចំណាំ៖** ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ឬប្រធាន គ.ក.ប/គ.ក.រ។

**ខ. វិធានការសម្រាប់ការិយាល័យបោះឆ្នោត**

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

- មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប
- ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលបានអនុញ្ញាត ហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប
- អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប
- អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
- អ្នកដែលមានសិទ្ធិបោះឆ្នោតហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ
- ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពតាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ត.រ
- ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប ធ្វើសំណូមពរ ក្នុងករណីចាំបាច់។

សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ការរារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត
- ការធ្វើសកម្មភាពនានាដែលនាំឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត
- ការបង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន
- ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត
- ការប្រើប្រាស់ឧបករណ៍ដែលអាចថតរូប ឬវីដេអូបាននៅក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះ ដោយ គ.ជ.ប
- ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ក ច.ប.ត.រ ច.វ.ច.ប និង ប.ន.ក ហាមឃាត់។

គ. វិធានការសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

- មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប
- ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលបានអនុញ្ញាត ហើយដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប
- អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប
- អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប
- ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរក្នុងករណីចាំបាច់។

សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់
- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយណាមួយ
- ការបង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន
- ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលរាប់សន្លឹកឆ្នោត
- ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ក ច.ប.ត.រ ច.រ.ច.ប និង ប.ន.ក ហាមឃាត់។

ឃ. វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ

គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងទៀត ដើម្បីបង្ការការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ជនគ្រប់រូបដែលនៅបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យបោះឆ្នោត ឬក្នុងការិយាល័យរាប់សន្លឹកឆ្នោតត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗស្តីពីវិធានការការពារ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ក្នុងករណីតម្រូវឱ្យអនុវត្ត។

**ចំណាំ៖** ក្នុងករណីចាំបាច់ ប្រធាន គ.ក.ប/គ.ក.រ ត្រូវហាមជនគ្រប់រូបចូលក្នុងបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។

## III. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារៈ ឯកសារបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត

### ១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប

នៅព្រឹកថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាព គ.ក.ប ទាំងអស់ឱ្យមកបង្ហាញខ្លួននៅការិយាល័យបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមាន និងទីតាំងការិយាល័យបោះឆ្នោត ព្រមទាំងសម្ភារៈ ឯកសារ និងបរិក្ខារបម្រើឱ្យការបោះឆ្នោត។

សមាសភាព គ.ក.ប ទាំងអស់ត្រូវតែមកបង្ហាញខ្លួន តាមការអញ្ជើញរបស់ប្រធាន គ.ក.ប និងធានាថា មានវត្តមានក្នុងការបំពេញការងារ នៅថ្ងៃបោះឆ្នោតជាចាំបាច់។

ប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប ដើម្បី៖

- ឱ្យដឹងថា តើសមាជិក គ.ក.ប មានវត្តមានគ្រប់ទាំង ៦រូបឬទេ ឬមានសមាជិកណាម្នាក់ ឬច្រើននាក់មិនអាចមកបំពេញការងារនៅថ្ងៃបោះឆ្នោតបាន
- ចាត់តាំងសមាជិកម្នាក់ៗ ឱ្យទទួលខុសត្រូវក្នុងការរៀបចំសម្ភារ ឯកសារបោះឆ្នោតតាមតួនាទីរៀងៗខ្លួន
- ឱ្យសមាជិកម្នាក់ៗរំឭកឡើងវិញអំពីតួនាទី ភារកិច្ចដែលត្រូវបំពេញនៅថ្ងៃបោះឆ្នោតដូចមានចែងក្នុងសៀវភៅណែនាំនេះ។

**ចំណាំ៖**

- ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចមកបំពេញការងារបានក្នុងថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវជូនដំណឹងទៅ គធ.ខប ជាបន្ទាន់ ដើម្បីចាត់វិធានការដាក់អ្នកថ្មីជំនួសឱ្យបានទាន់ពេលវេលា ដោយត្រូវអនុវត្តដូចខាងក្រោម៖
  - ▪ប្រសិនបើប្រធាន គ.ក.ប មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធាន គ.ក.ប ត្រូវចូលកាន់តំណែងប្រធាន គ.ក.ប ហើយសមាជិកទី១ ចូលកាន់តំណែងអនុប្រធាន គ.ក.ប រីឯអ្នកដែលជ្រើសរើសថ្មី ត្រូវជំនួសតំណែងសមាជិកទី១
  - ▪ប្រសិនបើអនុប្រធាន គ.ក.ប មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន គ.ក.ប ហើយអ្នកដែលជ្រើសរើសថ្មី ឱ្យកាន់តំណែងជាសមាជិកទី១
  - ▪ប្រសិនបើលេខាធិការមិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលជ្រើសរើសថ្មី ឱ្យកាន់តំណែងជាសមាជិកទី១។
- សមាជិកថ្មីត្រូវតែទទួលការបំពាក់បំប៉ន ដោយសិក្សារួមគ្នាឡើងវិញជាមួយសមាជិកទាំងអស់នៃ គ.ក.ប នូវនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ដោយផ្អែកលើសៀវភៅណែនាំរបស់ គ.ជ.ប នៅ ១ថ្ងៃមុនថ្ងៃបោះឆ្នោត
- ប្រសិនបើ គធ.ខប មិនអាចជូនដំណឹងមកវិញបានទាន់ពេលវេលា ដោយសារយថាហេតុណាមួយ ប្រធាន គ.ក.ប ត្រូវជ្រើសរើសអ្នកជំនួសតំណែងសមាជិកអវត្តមាននោះ និងត្រូវជូនដំណឹងជាបន្ទាន់ទៅ គធ.ខប។

**២. ការទទួល និងការត្រួតពិនិត្យសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងការរាប់សន្លឹកឆ្នោត**

**ក. សម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប ត្រូវទទួលពី គធ.ខប**

បន្ទាប់ពីធ្វើការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប រួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលបានទទួល ហើយដែលមានរាយមុខនៅក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

រាល់សម្ភារ ឯកសារបោះឆ្នោតទាំងនេះ រួមមាន៖

១. បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចំនួន ២ច្បាប់។

២. សន្លឹកឆ្នោត ២កញ្ចប់ដែលត្រូវបានវេចខ្ចប់ដោយឡែកពីគ្នា ។

៣. លេខកូដការិយាល័យបោះឆ្នោតចំនួន ៥ ច្បាប់ សម្រាប់បិទនៅមុខការិយាល័យបោះឆ្នោត ១ច្បាប់ និង២ច្បាប់ សម្រាប់បិទនៅជញ្ជាំងខាងមុខ និងខាងក្រោយនៃហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង២ច្បាប់ សម្រាប់បិទនៅជញ្ជាំងខាងមុខ និងខាងក្រោយនៃហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត។

៤. ស្លាកសម្គាល់ «ការិយាល័យបោះឆ្នោត» បោះពុម្ពលើកំណាត់ប្លាស្ទិកចំនួន ១។

៥. ហិបឆ្នោតចំនួន ២ ដែលមិនទាន់ដំឡើង និងវេចខ្ចប់ដោយឡែក។

៦. បន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតចំនួន ២ ដែលមិនទាន់ដំឡើង និងវេចខ្ចប់ច្រកក្នុងការុង ឬកេសក្រដាសមួយដោយឡែក និងអមដោយស្កុត ១ដុំ។

៧. បណ្ណប្រកាសហាមប្រើទូរសព្ទដៃ និងម៉ាស៊ីនថតរូបចំនួន ២សន្លឹក។

៨. ទឹកខ្មៅលុបមិនជ្រះចំនួន ២ ដប។

៩. ត្រា គ.ក.ប ចំនួន ១។

១០. ត្រាសម្ងាត់ចំនួន ២ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ដែលដាក់ក្នុងស្រោមសំបុត្របិទជិត។

១១. តាំប៉ុងពណ៌ក្រហមចំនួន ២ប្រអប់ និងទឹកតាំប៉ុងពណ៌ក្រហមចំនួន ១ដប។

១២. ប៊ិកមានចងខ្សែសម្រាប់គូសសន្លឹកឆ្នោត និងប៊ិកធម្មតាសម្រាប់ គ.ក.ប សរុបទាំងពីរមុខចំនួន ៨ដើម។

១៣. ប៊ិកហ្វឺតធំលុបមិនជ្រះចំនួន ១ដើម។

១៤. ប៊ិកហ្វឺតធំចំនួន ១ដើម។

១៥. បន្ទាត់ជ័រចំនួន ១ដើម។

១៦. ប្រដាប់ចោះសន្លឹកឆ្នោតចំនួន ១។

១៧. ជ័រការពារចំនួន ១ដប។

១៨. ស្កុតថ្លាធំចំនួន ១ដុំ។

១៩. កៅស៊ូកងមួយចំនួន សម្រាប់ចងសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយ។

២០. ស្រោមសំបុត្រធំចំនួន ២ មធ្យមចំនួន ១៨ និងតូចចំនួន ៣។

២១. ក្រដាសស្តើងសម្រាប់បិទពាសសន្ទះបិទប្រឡោះស៊កសន្លឹកឆ្នោតចំនួន ១២សន្លឹក។

២២. ក្រដាសរ៉ាម សម្រាប់ប្រើប្រាស់ការងារផ្សេងៗចំនួន ២០សន្លឹក។

២៣. ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោតចំនួន ២ផ្ទាំង។

២៤. ផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោតចំនួន ២សន្លឹក។

២៥. ទម្រង់បែបបទលេខ ១១០១ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ចំនួន ១២សន្លឹក។

២៦. ទម្រង់បែបបទលេខ ១១០២ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ចំនួន ២០សន្លឹក។

២៧. ទម្រង់បែបបទលេខ ១១០៧ ចំនួន ៦ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត។

២៨. ទម្រង់បែបបទលេខ ១១០៨ សម្រាប់កត់ត្រាសំឡេងឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ចំនួន ៨ច្បាប់។
២៩. ទ.១១១២ ចំនួន ៨ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត នៅមុនថ្ងៃបោះឆ្នោត ដែល គ.ក.ប បានទទួល។
៣០. ទ.១១១៥ ចំនួន ២ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោត។
៣១. ទ.១១២០ ចំនួន ២ច្បាប់ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ ក្នុងអំឡុងពេលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
៣២. ទ.១២០២ ចំនួន ២ក្បាល ក្នុងមួយក្បាលមាន ២០ច្បាប់ សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់។
៣៣. ស្បោងសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួន ២។
៣៤. ស្បោងសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួន ២។
៣៥. កញ្ចប់សុវត្ថិភាព «កស» និងកញ្ចប់សុវត្ថិភាព «កខ» ចំនួន ២ សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតនៃក្រុមប្រឹក្សាពាក់ព័ន្ធ។
៣៦. ស្បោង «ខស» និងស្បោង «ខខ» ចំនួន ២ សម្រាប់ដាក់កញ្ចប់សុវត្ថិភាព «ក» និងសម្ភារ ឯកសារបោះឆ្នោត។
៣៧. សោឃ្លុំជ័រតូចមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោតចំនួន ៦។
៣៨. សោឃ្លុំជ័រមធ្យមមានលេខសម្រាប់ឃ្លុំបិទមាត់ស្បោង «ខ» ចំនួន ២។

**ខ. ការត្រួតពិនិត្យសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

ក្នុងការត្រួតពិនិត្យសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត គ.ក.ប បានទទួលហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។ បន្ទាប់មក គ.ក.ប ត្រូវ ៖

- ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយផ្អែកលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត (ទ.១១១២)
- ចុះហត្ថលេខាដោយសមាសភាព គ.ក.ប ទាំងអស់លើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតនោះនៅមុនថ្ងៃបោះឆ្នោត (ទ.១១១២) និងរក្សាទុកឱ្យបានហ្មត់ចត់ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលទទួលបានត្រឹមត្រូវគ្រប់ចំនួន
- ឱ្យលេខាធិការបំពេញលើ ទ.១១១២ ត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតណាដែលនៅខ្វះ ឬបាត់បង់ ហើយផ្ញើ ទ.១១១២ នេះចំនួន ១ច្បាប់ជាបន្ទាន់ទៅ គធ.ខប ប្រសិនបើសម្ភារឯកសារណាមួយ ឬមួយចំនួនដែលបានទទួលមិនគ្រប់តាមចំនួនកំណត់
- ចាត់សមាជិក គ.ក.ប ចំនួន ២រូបឱ្យធ្វើដំណើរទៅកាន់ លគធ.ខប ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោតថ្មី ជំនួសសម្ភារ ឯកសារបោះឆ្នោតដែលខ្វះ ឬបានបាត់បង់នោះ ឬក៏ទាក់ទងតាមវិទ្យុទាក់ទង ឬទូរសព្ទបញ្ជូនព័ត៌មានស្នើសុំទៅ គធ.ខប ដើម្បីដោះស្រាយបញ្ហា ប្រសិនបើសម្ភារដែលមិនបានទទួលនោះជាសម្ភារ ឯកសារបោះឆ្នោតចាំបាច់ មិនអាចខ្វះបានសម្រាប់ការបោះឆ្នោត

- យកចិត្តទុកដាក់ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតសំខាន់ៗដែលមិនអាចខ្វះបាន និងដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត ដែលរួមមាន៖
  - បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះចំនួន ២ច្បាប់
  - សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ចំនួន ២កញ្ចប់
  - ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតចំនួន ២
  - ហិបឆ្នោតទាំង ២ ដែលហិបឆ្នោតមួយ ប្រើសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងហិបឆ្នោតមួយទៀត ប្រើសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសោឃ្លុំមានលេខ
  - ទឹកខ្មៅលុបមិនជ្រះ។
- ច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯងផ្ទាល់ ចំពោះសម្ភារ ឯកសារបោះឆ្នោតដទៃទៀត ប្រសិនបើមិនបានផ្ដល់ឱ្យដោយ គធ.ខប ឬបាត់បង់នោះ ដែលមានដូចជា៖
  - បន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ត្រូវជំនួសដោយកន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចយកមកបិទបាំងបាន
  - ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុជាគំរូ ត្រូវជំនួសដោយក្រដាស សម្រាប់សរសេរកំណត់ហេតុដោយដៃ
  - ប៊ិកសរសេរ បន្ទាត់ ខ្សែចង...។

**ចំណាំ៖**

- ចំពោះកញ្ចប់សន្លឹកឆ្នោត ត្រូវពិនិត្យឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ និងពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតតែប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតដាច់ខាត
- ចំពោះត្រាសម្ងាត់ គ្រាន់តែពិនិត្យស្រោមសំបុត្រទាំងពីរ ដើម្បីឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់ចំនួន ២ នៅខាងក្នុងតែប៉ុណ្ណោះ ដោយមិនត្រូវបើកស្រោមសំបុត្រដាច់ខាត
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានជូនដំណឹង និងអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតរបស់ គ.ក.ប។

**គ. ក្រោយការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត**

| *ប្រធាន គ.ក.ប ត្រូវ* | *- ចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ច្បាប់នៅមុខទីតាំងការិយាល័យបោះឆ្នោត*<br>*- ចាត់សមាជិកទី២ លើកស្លាក និងបិទលេខកូដការិយាល័យបោះឆ្នោតនៅលើច្រកទ្វារចូលការិយាល័យបោះឆ្នោត*<br>*- ចាត់ចែងសមាជិកទាំងអស់ឱ្យបោាត់ដំឡើងហិបឆ្នោតនិងបន្ទប់សម្ងាត់។* |
|---|---|

**ឃ. ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត**

| *ប្រធាន គ.ក.ប ត្រូវ* | *- រក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅផ្ទះប្រធាន គ.ក.ប ឬសមាជិក គ.ក.ប ណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព*<br>*- ចាត់ឱ្យសមាជិក គ.ក.ប ៣នាក់ គិតទាំងប្រធាន គ.ក.ប ផង សម្រាកនៅផ្ទះ ឬទីតាំងដែលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព*<br>*- ស្នើសុំកម្លាំងសន្តិសុខការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត។* |
|---|---|

### ៣. ការពិនិត្យទីតាំងការិយាល័យបោះឆ្នោត

ប្រធាន គ.ក.ប ត្រូវចាត់ចែងរៀបចំការិយាល័យបោះឆ្នោត ឱ្យបានរួចរាល់ជាស្រេចនៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះអាចធ្វើការបោះឆ្នោតបាន និងអាចរៀបចំរួចស្រេចនៅម៉ោង ៦:០០ ព្រឹកនៃថ្ងៃបោះឆ្នោត។ ប្រធាន គ.ក.ប ត្រូវចាត់ចែង៖

- បោសសម្អាតការិយាល័យបោះឆ្នោត
- រៀបចំការិយាល័យបោះឆ្នោតឯកភាពគ្នាតាមគំរូប្លង់ ដូចមាននៅក្នុងសៀវភៅណែនាំនេះ
- រៀបចំតុ កៅអីឱ្យមានចំនួនគ្រប់គ្រាន់ សម្រាប់ធ្វើការបោះឆ្នោត។ ប្រសិនបើគ្មាន ឬមានចំនួនមិនគ្រប់គ្រាន់ ប្រធាន គ.ក.ប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់
- បិទបង្អួច និងចាក់សោទ្វារ (ប្រសិនបើអាចធ្វើបាន) និងស្នើសុំកម្លាំងសន្តិសុខយាមកាមការពារ
- ណាត់សមាជិកទាំងអស់នៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនរាល់សម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត
- ជម្រាបសមាជិកទាំងអស់នៃ គ.ក.ប ឱ្យត្រៀមអាហារសម្រាប់រយៈពេល ១ថ្ងៃសម្រាប់បរិភោគនៅពេលទំនេរ ដែលពុំមានវត្តមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប។




*គំរូប្លង់ការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា*

### ៤. ការប្រើប្រាស់បញ្ជីបោះឆ្នោត

| | |
|---|---|
| *បញ្ជីបោះឆ្នោតសម្រាប់ គ.ក.ប ចំនួន ២ច្បាប់* | *- ១ច្បាប់ បិទនៅមុខទីតាំងការិយាល័យបោះឆ្នោតនៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត*<br>*- ១ច្បាប់ ទុកប្រើប្រាស់នៅថ្ងៃបោះឆ្នោត។* |

## IV. ឯកសារប្រើប្រាស់ផ្លូវការសម្រាប់ការបោះឆ្នោត

ឯកសារផ្លូវការប្រើប្រាស់សម្រាប់ការបោះឆ្នោត គឺឯកសារណាមួយក្នុងចំណោមឯកសារខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬ
- បណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស ។

**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព**







**បណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស**





## V. ការប្រព្រឹត្តទៅនៃការបោះឆ្នោត

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០ ព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដោយនាំសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតមកជាមួយផង។

បន្ទាប់មក ប្រធាន គ.ក.ប ត្រូវ៖

- ប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ចូលក្នុងការិយាល័យបោះឆ្នោត ដោយត្រូវត្រួតពិនិត្យបណ្ណសម្គាល់ខ្លួនជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែងដែលបានបម្រុងទុកសម្រាប់ពួកគាត់
- ចាត់ចែងសមាជិកដទៃទៀត ឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារ ឯកសារបោះឆ្នោតតាមតួនាទី ភារកិច្ច និងតាមទីកន្លែងដែលបានឯកភាពគ្នាលើគំរូប្លង់ការិយាល័យ ដែលបានរៀបចំទុក ១ថ្ងៃមុនថ្ងៃបោះឆ្នោត
- ចាត់ចែង និងណែនាំសមាជិកទី២ ឱ្យបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងការិយាល័យបោះឆ្នោត។

**ចំណាំ៖**

- លេខាធិការត្រូវចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មានវត្តមានពេលបើកការបោះឆ្នោតក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)
- ប្រធាន គ.ក.ប ត្រូវជម្រាបអ្នកសង្កេតការណ៍ឱ្យចុះវត្តមាន ពេលម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខាក្នុងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០)។

១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត

ក. ការរៀបចំសម្ភារ ឯកសារតាមគំរូប្លង់

- តុមួយនៅខាងឆ្វេងដែលបន្ទាប់ពីផ្លូវចូល សម្រាប់ប្រធាន គ.ក.ប។

**តុប្រធាន គ.ក.ប មាន**

- *បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងពាក្យបណ្តឹង (ទ.១២០២)*
- *ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារ ឯកសារបោះឆ្នោតមិនទាន់ប្រើប្រាស់។*

- តុមួយនៅខាងស្តាំដែលបន្ទាប់ពីផ្លូវចូលសម្រាប់លេខាធិការ។

**តុលេខាធិការ មាន**

- *បញ្ជីបោះឆ្នោត ១ច្បាប់*
- *កញ្ចប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ*
- *ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតាំប៉ុងពណ៌ក្រហម*
- *កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) សម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ*
- *ទម្រង់បែបបទផ្សេងៗទៀត។*

- បន្ទប់សម្ងាត់ទី១ សម្រាប់ការគូសសន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវដាក់តម្កល់លើតុមួយក្បែរជញ្ជាំងក្នុងចម្ងាយប្រមាណ ១,៥០ម៉ែត្រ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោត។

**បន្ទប់សម្ងាត់ទី១ មាន**

- *ប៊ិកចងខ្សែភ្ជាប់ស្រាប់*
- *ផ្ទាំងក្រដាសដែលត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត។*

- តុវែងមួយស្ថិតនៅចន្លោះកណ្តាលប៉ែកខាងមុខរវាងបន្ទប់សម្ងាត់ទី១ និងបន្ទប់សម្ងាត់ទី២ សម្រាប់អនុប្រធាន គ.ក.ប។

**តុអនុប្រធាន គ.ក.ប មាន**

- *ហិបឆ្នោតបិទលេខកូដការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ*
- *កញ្ចប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត*
- *ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងតាំប៉ុងពណ៌ក្រហម*
- *ទម្រង់បែបបទផ្សេងៗទៀត។*

- រាំងនន ឬរបាំងផ្សេងទៀតដែលអាចរកបាន និងមានកម្ពស់មួយជំហរដែលមិនអាចឱ្យអ្នកបោះឆ្នោតមើលគ្នាឃើញ
- បន្ទប់សម្ងាត់ទី២ សម្រាប់គូសសន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវឃ្លាតឆ្ងាយពីតុអនុប្រធាន គ.ក.ប យ៉ាងតិច ១,៥០ម៉ែត្រ និងត្រូវរៀបចំ និងបំពាក់សម្ភារដូចបន្ទប់សម្ងាត់ទី១ ដែរ
- តុវែងមួយស្ថិតនៅកណ្តាលបន្ទប់ទល់មុខនឹងតុប្រធាន គ.ក.ប សម្រាប់សមាជិកទី១។

| | |
|---|---|
| *តុសមាជិកទី១ មាន* | *- ហិបឆ្នោតបិទលេខកូដការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត*<br>*- ទឹកខ្មៅលុបមិនជ្រះចំនួន ២ដប*<br>*- កំណាត់សម្រាប់ជូតម្រាមដៃអ្នកបោះឆ្នោត។* |

- តុ និងកៅអី (ប្រសិនបើមាន) សម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវដាក់អែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុប្រធាន គ.ក.ប និងខាងក្រោយតុលេខាធិការ។

**ចំណាំ៖**

- អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ស្ថិតនៅទីជិតខាងក្រោយលេខាធិការល្មមដែលអាចមើលឃើញឯកសារបាន
- ការផ្លាស់ប្តូរទីកន្លែងឈរ ឬអង្គុយរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវមានការអនុញ្ញាតពីប្រធាន គ.ក.ប
- បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អភិបាល អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយ ដើម្បីពិនិត្យមើលការបោះឆ្នោតឡើយ។

**ខ. ការពន្យល់ណែនាំដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

នៅពេលរៀបចំសម្ភារ ឯកសារបោះឆ្នោតរួចរាល់ ប្រធាន គ.ក.ប ត្រូវណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដែលពួកគាត់ត្រូវគោរព និងអនុវត្ត ដូចខាងក្រោម៖

- ត្រូវគោរព ច.ប.ក ច.ប.ត.រ ច.វ.ច.ប ប.ន.ក ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប
- ត្រូវតាមដានជាប្រចាំរាល់កិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត បង្ការក្រែងមានភាពមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតក្លែងក្លាយចូលក្នុងការិយាល័យបោះឆ្នោត និងការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត
- មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ ឬថតឯកសារ
- មិនត្រូវណែនាំ ឬសាកសួរអ្វីដល់អ្នកបោះឆ្នោត
- មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ
- ត្រូវលើកសំណួរ ឬ/និងសំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប ចំពោះភ្នាក់ងារគណបក្សនយោបាយ
- ត្រូវបំពេញបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា
- ត្រូវចូលបំពេញការងារតាមទីកន្លែង ដែល គ.ក.ប បានកំណត់។

២. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ព្រឹកដល់ម៉ោង ៦:៣០នាទីព្រឹកនៃថ្ងៃបោះឆ្នោត

**ប្រធាន គ.ក.ប ត្រូវ**

- *ពិនិត្យហិបឆ្នោតទាំងពីរឡើងវិញ ម្តងមួយៗ ដើម្បីឱ្យប្រាកដថា ត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ*
- *បើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោតនីមួយៗ បង្ហាញហិបឆ្នោតដែលទទេ ចំពោះមុខអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ រួចត្រូវបិទគម្របក្នុងវិញ បន្ទាប់មកមូលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ហើយខ្ទាស់គន្លឹះបិទគម្របក្នុង រួចចាក់សោឃ្លុំ និងប្រាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកត់ត្រាលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត នៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ)*
- *ចាត់ចែងយកក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌ផ្ទៃមេឃ ចំនួន ២សន្លឹក និងបោះត្រា គ.ក.ប រួចបិទភ្ជាប់ទៅនឹងជញ្ជាំងខាងមុខ និងខាងក្រោយនៃហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បន្ទាប់មកយកក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌សចំនួន ២សន្លឹក និងបោះត្រា គ.ក.ប រួចបិទភ្ជាប់ទៅនឹងជញ្ជាំងខាងមុខ និងខាងក្រោយនៃហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត*
- *អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតទាំង ២ នៃការិយាល័យបោះឆ្នោតនោះ*
- *ចាត់លេខាធិការឱ្យកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោតនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ)*
- *ប្រកាសប្រាប់អ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ហាមប្រើទូរសព្ទដៃ ឬម៉ាស៊ីនថតរូប ឬ/និងឧបករណ៍ផ្សេងៗដែលអាចថតរូបបាន ឬ/និងធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។*

**ចំណាំ៖**

- មិនអនុញ្ញាតឱ្យបើកចំហហិបឆ្នោត ដែលបានចាក់សោឃ្លុំមានលេខរួចហើយ និងបិទស្លាកសម្គាល់លេខកូដការិយាល័យបោះឆ្នោតដាច់ខាត ក្រៅពីគោលបំណងរាប់សន្លឹកឆ្នោត
- មិនអនុញ្ញាតឱ្យយកហិបឆ្នោតចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន
- ក្នុងករណី គ.ក.ប បានអនុវត្តនីតិវិធីពីម៉ោង ៦:០០ព្រឹកទៅម៉ោង ៦:៣០នាទីព្រឹករួចរាល់មុនពេលកំណត់ គ.ក.ប អាចអនុវត្តនីតិវិធីដែលត្រូវអនុវត្តពីម៉ោង ៦:៣០នាទីព្រឹកទៅម៉ោង ៧:០០ព្រឹកទៀតបាន ដោយពុំចាំបាច់រង់ចាំពេលវេលាឡើយ។




ប្រធាន គ.ក.ប បង្ហាញហិបឆ្នោតទទេដល់សមាជិក គ.ក.ប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍




*ហិបឆ្នោតដែលមានចាក់ភ្ជាប់សោឃុំមានលេខត្រង់គន្លឹះគម្របខាងក្នុង*

**៣. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០នាទីព្រឹកដល់ម៉ោង ៧:០០ ព្រឹកនៃថ្ងៃបោះឆ្នោត**

ប្រធាន គ.ក.ប ត្រូវចាត់ចែងត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង (សន្លឹកឆ្នោតពណ៌ផ្ទៃមេឃជាសន្លឹកឆ្នោតសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឯសន្លឹកឆ្នោតពណ៌សជាសន្លឹកឆ្នោតសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត) ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ផ្លូវការសម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត។

**ក. ការពិនិត្យកញ្ចប់សន្លឹកឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ*

*- ចាត់អនុប្រធាន គ.ក.ប ឱ្យ៖*

- *ពិនិត្យ និងបង្ហាញអ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា កញ្ចប់សន្លឹកឆ្នោតមិនត្រូវបានគេរុះរើឡើយ*
- *ត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោតទាំង ២ ម្តងមួយកញ្ចប់ៗ ដើម្បីធានាថា សន្លឹកឆ្នោតទាំងនេះជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ពិតប្រាកដមែន*
- *បើកកញ្ចប់សន្លឹកឆ្នោត រួចរាប់ចំនួនសន្លឹកឆ្នោតដែលជាធម្មតាកញ្ចប់នីមួយៗមានចំនួនសន្លឹកឆ្នោតលើសពីចំនួនអ្នកបោះឆ្នោតដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះក្នុងចន្លោះពី ២៥ ដល់ ៧៤សន្លឹក។*

**ប្រធាន គ.ក.ប ត្រូវ(ត)**

- ចាត់លេខាធិការឱ្យ៖
  - កត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែង (ទោះចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ ទទួលក្តី) និងកត់ត្រាលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ)
  - ពិនិត្យ និងកត់ត្រាចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោតនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ)។

ខ. **ការត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់**

**ប្រធាន គ.ក.ប ត្រូវ**

- ពិនិត្យ និងបង្ហាញអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ដើម្បីឱ្យដឹងប្រាកដថា ស្រោមសំបុត្រដាក់ត្រាសម្ងាត់មិនត្រូវបានគេរុះរើឡើយ
- បើកស្រោមសំបុត្រដែលមានត្រាសម្ងាត់
- ដកយកត្រាសម្ងាត់ទាំងពីរបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស
- លើកបង្ហាញអ្នកមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំរូបសញ្ញាដូចគ្នានៃត្រាសម្ងាត់នីមួយៗ។

**ចំណាំ៖** ករណីសម្ភារ ឯកសារបោះឆ្នោតត្រូវបានប្រគល់ ទទួលនៅក្រោយម៉ោង ៦:៣០នាទីព្រឹក ប៉ុន្តែមិនហួសម៉ោង ៧:០០ ព្រឹកនៃថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវ៖

- ព្យួរការអនុវត្តនីតិវិធីបន្ទាប់ៗសិន រហូតទាល់តែនីតិវិធីត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតត្រូវបានបំពេញចប់សព្វគ្រប់
- ចាត់លេខាធិការឱ្យកត់ត្រាពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ) ឱ្យបានច្បាស់លាស់
- បើកការបោះឆ្នោតនៅក្រោយម៉ោង ៧:០០ ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ ព្រឹកឡើយ។

៤. **ភារកិច្ចរបស់ គ.ក.ប នៅពេលបោះឆ្នោតចាប់ពីម៉ោង ៧:០០ ព្រឹកដល់ម៉ោង ១៥:០០**



ប្រធាន គ.ក.ប ត្រូវប្រកាសបើកការបោះឆ្នោតនៅម៉ោង ៧:០០ ព្រឹកនៃថ្ងៃបោះឆ្នោត ឬអាចប្រកាសបើកនៅចន្លោះម៉ោង ៧:០០ ព្រឹកទៅម៉ោង ៨:០០ ព្រឹក ក្នុងករណីសម្ភារ ឯកសារបោះឆ្នោតត្រូវបានទទួលនៅក្រោយម៉ោង ៦:៣០នាទីព្រឹក។

ប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ត្រួតពិនិត្យក្នុងបន្ទប់សម្ងាត់អំពីសណ្ដាប់ធ្នាប់ និងប៊ិកសម្រាប់គូសសន្លឹកឆ្នោត និងធ្វើអនាម័យសម្លាប់មេរោគយ៉ាងយូរ ១ម៉ោងម្ដងៗ និងត្រូវចាត់ចែងការងារតាមលំដាប់លំដោយដូចតទៅ៖

*សមាជិកទី២ ត្រូវ*

- *ចាត់ចែងសណ្ដាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង*
- *ជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដោយប្រាប់លេខរៀង និងឈ្មោះរបស់អ្នកបោះឆ្នោត*
- *ចេញក្រដាសលេខរៀងលំដាប់មុនក្រោយ*
- *ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរ។*

*សមាជិកទី៣ ត្រូវ*

- *នៅប្រចាំការត្រង់មាត់ទ្វារចេញចូលការិយាល័យបោះឆ្នោត*
- *ចាត់ចែងសណ្ដាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ដោយណែនាំអ្នកបោះឆ្នោតឱ្យឈរជាជួរបន្តគ្នា (ធ្វើមុនប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោត)*
- *ជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តគ្នានៅក្នុងបរិវេណខាងក្នុង អំពីអ្នកបោះឆ្នោតដែលត្រូវផ្ដល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត*
- *ផ្ដល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត តាមលំដាប់លំដោយគឺ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនមានពិការភាពនោះ ព្រមទាំងអ្នកឈរក្បែរជួរខាងមុខគេ*
- *រំឭកអ្នកបោះឆ្នោតឱ្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅមុខទីតាំងការិយាល័យបោះឆ្នោត*
- *ឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ដែលមានសុពលភាព ឬបណ្ណសម្គាល់ខ្លួនសមាជិក កបយ.ស*
- *ពិនិត្យមើលម្រាមដៃរបស់អ្នកបោះឆ្នោត ក្រែងមានប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ*
- *ជម្រាបអ្នកបោះឆ្នោតឱ្យដើរតម្រង់ទៅតុលេខាធិការ*
- *អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលម្ដងម្នាក់ៗ និងរក្សាចំនួនអ្នកបោះឆ្នោតមិនឱ្យលើសពី ៤នាក់ក្នុងពេលតែមួយក្នុងការិយាល័យបោះឆ្នោត។*

*លេខាធិការត្រូវ*

- *ពិនិត្យម្រាមដៃដើម្បីឱ្យប្រាកដថា ពិតជាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះ*
- *ឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបយ.ស និងសួរគាត់ពីលេខរៀង និងឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត*
- *ពិនិត្យមើលលេខរៀងនៅលើប័ណ្ណព័ត៌មានអ្នកបោះឆ្នោត(ប្រសិនបើមាន) ដើម្បីរកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត រួចប្រគល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតជូនអ្នកបោះឆ្នោតវិញ។ បន្ទាប់មកសួរបញ្ជាក់ឈ្មោះ និងពិនិត្យផ្ទៀងផ្ទាត់ អ.ខ ដែលមានសុពលភាព ឬបណ្ណសម្គាល់ខ្លួនសមាជិក កបយ.ស របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត*

| | |
|---|---|
| *លេខាធិការត្រូវ (ត)* | *- ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់អ្នកបោះឆ្នោត និងគូសសញ្ញាធិកបញ្ជាក់ការមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងប្រឡោះទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះរបស់គាត់នោះ*<br>*- ហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ១សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ៤ផ្នត់តាមការណែនាំរបស់ គ.ជ.ប*<br>*- ប្រគល់ អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស របស់គាត់*<br>*- ជម្រាបអ្នកបោះឆ្នោតថា៖*<br>*▪ នេះជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដែលមានពណ៌ផ្ទៃមេឃ*<br>*▪ អញ្ជើញយកសន្លឹកឆ្នោតនេះចូលទៅក្នុងបន្ទប់សម្ងាត់ទី១ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប្រើប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) រួចគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយដែលអ្នកពេញចិត្ត។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់ មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្ដូរចិត្ត បន្ទាប់ពីបានគូសរួច*<br>*▪ មុនចេញពីបន្ទប់សម្ងាត់ ត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើមវិញ ដើម្បីឱ្យសញ្ញាដែលគូសស្ថិតនៅខាងក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញាត្រាសម្ងាត់នៅខាងក្រៅ*<br>*▪ ដើរទៅកាន់ហិបឆ្នោតដែលស្ថិតនៅលើតុអនុប្រធាន គ.ក.ប លើកសន្លឹកឆ្នោតដែលបត់រួច មានត្រាសម្ងាត់នៅខាងក្រៅបង្ហាញអនុប្រធាន គ.ក.ប រួចស៊កសន្លឹកឆ្នោតតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត*<br>*▪ ទៅជួបអនុប្រធាន គ.ក.ប និងរង់ចាំទទួលយកសន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ប្រសិនបើអ្នកបោះឆ្នោតអះអាងថា បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត។* |

**ចំណាំ៖**

- ប្រសិនបើពិនិត្យឃើញថា ម្រាមដៃរបស់អ្នកបោះឆ្នោតមានប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ឬរូបថត ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា លេខាធិការត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍
- ប្រសិនបើរកមិនឃើញឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត លេខាធិការត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍
- លេខាធិការមិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញពីបន្ទប់សម្ងាត់ទី១
- សន្លឹកឆ្នោតនីមួយៗត្រូវមានបោះត្រាសម្ងាត់នៅខាងខ្នង បើមិនមានបោះត្រាទេ ទុកជាសន្លឹកឆ្នោតមិនបានការ
- លេខាធិការមិនត្រូវយកសៀវភៅសន្លឹកឆ្នោតធ្វើជាទ្រនាប់សម្រាប់បោះត្រាសម្ងាត់ និងបត់សន្លឹកឆ្នោតឡើយ (បង្ការការប្រឡាក់ទឹកត្រាលើសន្លឹកឆ្នោតផ្សេងទៀត)
- លេខាធិការមិនអនុញ្ញាតឱ្យហែកសន្លឹកឆ្នោត និងបោះត្រាសម្ងាត់ទុកមុនឡើយ។



*លេខាធិការពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត*

*អនុប្រធាន គ.ក.ប ត្រូវ*

- *ពិនិត្យឱ្យប្រាកដថា សន្លឹកឆ្នោតដែលអ្នកបោះឆ្នោតលើកបង្ហាញនោះជាសន្លឹកឆ្នោតផ្លូវការមានពណ៌ផ្ទៃមេឃ និងមានត្រាសម្ងាត់នៅខាងក្រៅពិតមែន ហើយមានតែមួយសន្លឹក ដែលត្រូវស៊កចូលទៅក្នុងហិបឆ្នោត*
- *ហែកសន្លឹកឆ្នោតសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ១សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់លើផ្នែកខាងខ្នង បន្ទាប់មកបត់សន្លឹកឆ្នោតនោះជា ៤ផ្នត់ តាមការណែនាំ*
- *ជូនសន្លឹកឆ្នោតដែលបានបោះត្រាសម្ងាត់ និងបានបត់ជា ៤ផ្នត់នោះដល់អ្នកបោះឆ្នោត ហើយជម្រាបគាត់ថា៖*
  - *នេះជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត*
  - *យកសន្លឹកឆ្នោតនេះចូលទៅក្នុងបន្ទប់សម្ងាត់ទី២*
  - *គូសសញ្ញាគាំទ្រក្នុងប្រអប់ ៤ជ្រុងទ្រវែងនៃគណបក្សនយោបាយតែមួយគត់ដែលអ្នកពេញចិត្ត ដោយប៊ិកដែលមានក្នុងបន្ទប់ស្រាប់ ឬប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ)។ មុននឹងគូស ត្រូវពិចារណាឱ្យបានហ្មត់ចត់ ដើម្បីបង្ការកុំឱ្យខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្ដូរចិត្ត*
  - *គូសសញ្ញាហើយ ត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើមវិញ ដើម្បីឱ្យសញ្ញាដែលគូសស្ថិតនៅខាងក្នុងផ្នត់មិនអាចមើលឃើញ និងរូបត្រាសម្ងាត់នៅខាងក្រៅ*
  - *ដើរតម្រង់ទៅតុដាក់ហិបឆ្នោតដែលស្ថិតនៅលើតុសមាជិកទី១ រួចលើកសន្លឹកឆ្នោតដែលបត់រួច មានត្រាសម្ងាត់នៅខាងខ្នងបង្ហាញសមាជិកទី១*
  - *ស៊កសន្លឹកឆ្នោតតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត រួចឱ្យសមាជិកទី១ជ្រលក់ម្រាមដៃនឹងទឹកខ្មៅលុបមិនជ្រះ។*

**ចំណាំ៖**

- អនុប្រធាន គ.ក.ប មិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់ទី២
- សន្លឹកឆ្នោតនីមួយៗត្រូវតែមានបោះត្រាសម្ងាត់នៅខាងខ្នង បើមិនមានបោះត្រាទេ ទុកជាសន្លឹកឆ្នោតមិនបានការ
- អនុប្រធាន គ.ក.ប មិនត្រូវយកសៀវភៅសន្លឹកឆ្នោតធ្វើជាទ្រនាប់សម្រាប់បោះត្រាសម្ងាត់ និងបត់សន្លឹកឆ្នោតឡើយ (បង្ការការប្រឡាក់ទឹកត្រាលើសន្លឹកឆ្នោតផ្សេងទៀត)

- អនុប្រធាន គ.ក.ប មិនអនុញ្ញាតឱ្យហែកសន្លឹកឆ្នោត និងបោះត្រាសម្ងាត់ទុកមុនឡើយ
- អនុប្រធាន គ.ក.ប ត្រូវមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតជាបណ្ដោះអាសន្ន បើគ្មានអ្នកបោះឆ្នោតមកបោះឆ្នោត ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត
- ប្រសិនបើឃើញអ្នកបោះឆ្នោតណាម្នាក់បម្រុងស៊កសន្លឹកឆ្នោតលើសពីមួយសន្លឹក ឬសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត អនុប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប។




*សមាជិកទី១ ត្រូវ*

- *ពិនិត្យឱ្យប្រាកដថា សន្លឹកឆ្នោតដែលអ្នកបោះឆ្នោតលើកបង្ហាញនោះជាសន្លឹកឆ្នោតផ្លូវការមានពណ៌ស និងមានត្រាសម្ងាត់នៅខាងខ្នងពិតមែន ហើយមានតែមួយសន្លឹក*
- *ជូតម្រាមចង្អុលដៃស្ដាំអ្នកបោះឆ្នោតឱ្យស្អាតដោយកំណាត់។ ក្នុងករណីម្រាមចង្អុលដៃស្ដាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ម្រាមចង្អុលខ្មោចស្ដាំ ឬនាងដៃស្ដាំ ឬកូនដៃស្ដាំ ឬមេដៃស្ដាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវៈយវៈរបស់គាត់ ត្រូវទទួលយកជាបានការ។*
- *កាន់ និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោត (ទោះបីគាត់មិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយក៏ដោយ) ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យលិចដល់គល់ក្រចក និងរង់ចាំល្មមទឹកខ្មៅស្ងួត ទើបអនុញ្ញាតឱ្យគាត់ចេញពីការិយាល័យបោះឆ្នោត។*



*ការជ្រលក់ម្រាមចង្អុលដៃស្ដាំរបស់អ្នកបោះឆ្នោតទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ*

ចំណាំ

សមាជិកទី១ត្រូវ ៖

- ក្រឡុកដបទឹកខ្មៅលុបមិនជ្រះឱ្យសព្វមុនពេលបើកប្រើ
- ច្នៃប្រឌិតរកកំប៉ុង ឬដបជ័រ (កាត់ឱ្យខ្លី) ដាក់ខ្សាច់ សម្រាប់ដាក់ទប់ដបទឹកខ្មៅលុបមិនជ្រះ ដើម្បីរក្សាលំនឹងជៀសវាងការដួលកំពប់
- រាយការណ៍ជាបន្ទាន់ជូនប្រធាន គ.ក.ប បើពិនិត្យឃើញអ្នកបោះឆ្នោតណាបម្រុងស៊កសន្លឹកឆ្នោតលើសពី ១សន្លឹក ឬស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត
- មូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតជាបណ្ដោះអាសន្ន បើគ្មានអ្នកបោះឆ្នោតមកបោះឆ្នោត ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត
- បិទគម្របដបទឹកខ្មៅលុបមិនជ្រះឱ្យជិតដើម្បីការពារកុំឱ្យហួត បើគ្មានអ្នកបោះឆ្នោតក្នុងរយៈពេលយូរគួរសម រៀងរាល់ ៣០នាទីម្ដងសមាជិកទី១ ត្រូវបិទគម្របដបទឹកខ្មៅលុបមិនជ្រះឱ្យបានជិតហើយក្រឡុក
- បម្រុងទុកទឹកខ្មៅលុបមិនជ្រះ ១ដបទៀត សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅលុបមិនជ្រះដបទី១។

**៥. ការងាររបស់ប្រធាន គ.ក.ប ក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត**

**ក. ករណីអ្នកបោះឆ្នោតមានម្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ**

*ប្រធាន គ.ក.ប ត្រូវ*

- *អញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកកត់សម្គាល់បញ្ហានេះ*
- *ឱ្យអ្នកបោះឆ្នោតនោះពន្យល់បំភ្លឺ បើការបំភ្លឺនោះមិនសមហេតុផល សន្និដ្ឋានថា គាត់មានចេតនាបោះឆ្នោតលើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក*
- *ដកហូត អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស ជាបណ្ដោះអាសន្នរួចបញ្ជូនទៅ គធ.ឃប ដើម្បីចាត់វិធានការបន្ត*
- *ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍នេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស និង ទ.១១០១ខ) និងស្រង់ឈ្មោះ ទិន្នន័យពីក្នុង អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស សម្រាប់ការតាមដានបន្ថែមទៀត*
- *ស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ បើអ្នកបោះឆ្នោតមិនយល់ព្រមតាមវិធានការខាងលើ ។*

**ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា**

*ប្រធាន គ.ក.ប ត្រូវ*

- *ជម្រាបគាត់ថា គាត់ពុំអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ព្រោះគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះ ទោះបីជាគាត់មាន អ.ខ ដែលមានសុពលភាព ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស ក៏ដោយ*
- *ជម្រាបគាត់អំពីទីតាំងការិយាល័យបោះឆ្នោតដែលគាត់ត្រូវទៅបោះឆ្នោត ប្រសិនបើច្រឡំការិយាល័យបោះឆ្នោត*
- *ជម្រាបគាត់ឱ្យចេញពីការិយាល័យបោះឆ្នោតនេះ។*

**គ. ករណីអ្នកបោះឆ្នោតអះអាងថា មិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ**

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* ⇨ | *- បំពេញព័ត៌មានអំពីបញ្ហានេះទៅក្នុងក្រដាសព័ត៌មានអ្នកអះអាងថាមិនបានបោះឆ្នោតក្រុមប្រឹក្សា (ទ.១១០៩) ដោយត្រូវធ្វើនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត*<br>*- ជម្រាបលេខាធិការ ឬអនុប្រធាន គ.ក.ប ថាមិនត្រូវហែកសន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬសន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ជូនគាត់ទេ។* |

**ឃ. ករណីអ្នកបោះឆ្នោតណាម្នាក់បម្រុងស៊កសន្លឹកឆ្នោតលើសពី ១សន្លឹក ឬ/និងសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត**

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* ⇨ | *- ប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមាននៅក្នុងការិយាល័យបោះឆ្នោត*<br>*- ឃាត់អ្នកបោះឆ្នោតមិនឱ្យបោះឆ្នោត*<br>*- ឆែករកសន្លឹកឆ្នោតក្លែងក្លាយ ឬលើសពី ១សន្លឹក ឬ/និងសន្លឹកឆ្នោតផ្លូវការដែលលាក់ទុកនោះដាក់ក្នុងស្រោមសំបុត្រមានកាខ្វងស្រាប់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត»*<br>*- ដកហូត អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស ជាបណ្ដោះអាសន្ន*<br>*- ចាត់ចែងធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គជ.ខប។* |

**ង. ករណីអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន**

អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន អាចជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬអាចស្នើសុំជំនួយពីប្រធាន គ.ក.ប។

ប្រធាន គ.ក.ប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពនោះ ឬអាចចាត់សមាជិក គ.ក.ប ណាម្នាក់ជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីអ្នកបោះឆ្នោតជាជនមានពិការភាពនោះ។ ក្នុងករណីនេះ អ្នកជួយអ្នកបោះឆ្នោតជាជនមានពិការភាព ត្រូវៈ

- សួរអ្នកបោះឆ្នោតជាជនមានពិការភាពតិចៗក្នុងបន្ទប់សម្ងាត់ថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយមួយណា?
- គូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោតតាមការជ្រើសរើសរបស់អ្នកបោះឆ្នោតជាជនមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម រួចត្រូវនាំអ្នកបោះឆ្នោតទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់ទៅក្នុងហិបឆ្នោត
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

**ច. ករណីអ្នកបោះឆ្នោតជាជនមានពិការភាពភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង**

ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនមានពិការភាពភ្នែកទាំងសងខាងនោះឱ្យទៅជួបលេខាធិការ ដើម្បីបង្ហាញ អ.ខ ដែលមានសុពលភាព ឬបណ្ណសម្គាល់ខ្លួន សមាជិក កបឃ.ស របស់ខ្លួន ដូចអ្នកបោះឆ្នោតដែលមិនមានពិការភាពដែរ។ នៅពេលអនុវត្តចំណុចនេះរួចរាល់ លេខាធិការ ត្រូវហុច អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបឃ.ស ជូនសាមីខ្លួនវិញ។

លេខាធិការ ឬ អនុប្រធាន គ.ក.ប

- ត្រូវហែកសន្លឹកឆ្នោត ១សន្លឹក ចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ៤ផ្នត់ និងត្រូវណែនាំអ្នកបោះឆ្នោតជាជនមានពិការភាពភ្នែកទាំងសងខាងនោះ ឱ្យស្ទាបសន្លឹកឆ្នោត និងស្ទាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្របក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើឃ្នាបគាបសន្លឹកឆ្នោតនោះភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការកុំឱ្យប្រអប់លេខរៀងសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយងាក ឬល្អៀងចេញពីប្រហោងនៃក្របក្រដាសពិសេស
- ត្រូវប្រគល់ក្របក្រដាសពិសេសដែលមានដាក់សន្លឹកឆ្នោតខាងក្នុងជូនទៅអ្នកបោះឆ្នោតដែលជាជនមានពិការភាពភ្នែកទាំងសងខាង និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុងទ្រវែង ដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា ៖
  - អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែងដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលមានបញ្ជីបេក្ខជនឈរឈ្មោះក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តនោះ ។
  - អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយ ដែលអ្នកពេញចិត្ត
  - អ្នកត្រូវប្រើប៊ិកគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្ទាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្សដែលអ្នកពេញចិត្ត
  - អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

ប្រធាន គ.ក.ប ត្រូវ

- ជួយជូនអ្នកបោះឆ្នោតដែលជាជនមានពិការភាពភ្នែកទាំងសងខាងនោះទៅកាន់បន្ទប់សម្ងាត់ និងជួយរកប៊ិកសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ
- ជួយរៀបចំក្របក្រដាសពិសេសឱ្យមានភាពត្រឹមត្រូវ ប្រសិនបើពិនិត្យឃើញថា ក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង
- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមានសំណូមពរពីអ្នកបោះឆ្នោតនោះ។

**ចំណាំ៖**

រាល់ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

**ឆ. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រគណបក្សនយោបាយ**

ប្រធាន គ.ក.ប ត្រូវ

- ព្រមានជននេះផ្ទាល់មាត់ ចំពោះការប៉ុនប៉ងលើកទី១
- ចាត់ទុកជាការរំលោភលើភាពសម្ងាត់នៃការបោះឆ្នោត ហើយជនដែលពាក់ព័ន្ធត្រូវបណ្ដេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក ច.ប.ត.រ និង ច.រ.ច.ប ចំពោះការប៉ុនប៉ងជាលើកទី២
- ចាត់លេខាធិការឱ្យកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុមួយដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។

ជ. ករណីអ្នកបោះឆ្នោតធ្វើឱ្យសន្លឹកឆ្នោតខូច ឬធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ដោយអចេតនា ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយ តែបានប្ដូរចិត្តវិញ

| ប្រធាន គ.ក.ប ត្រូវ | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- បង្គាប់លេខាធិការ ឬអនុប្រធាន គ.ក.ប ឱ្យផ្ដល់សន្លឹកឆ្នោតជូនគាត់តែមួយប៉ុណ្ណោះ ក្នុងករណីសន្លឹកឆ្នោតគាត់ខូច ឬរហែក ឬប្រឡាក់ ដោយអចេតនា ឬគូសសញ្ញារួចហើយ តែបានប្ដូរចិត្តវិញ*<br>*- ប្រាប់អ្នកបោះឆ្នោតនោះឱ្យបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម*<br>*- ដាក់សន្លឹកឆ្នោតដែលខូច ឬរហែក ឬប្រឡាក់ ឬគូសខុសនោះទៅក្នុងស្រោមសំបុត្រដែលមានកាខ្វងស្រាប់ «សន្លឹកឆ្នោតខូច»*<br>*- សម្រេចមិនផ្ដល់សន្លឹកឆ្នោតមួយសន្លឹកផ្សេងទៀតតាមការស្នើសុំបានឡើយ ប្រសិនបើអ្នកបោះឆ្នោតមកសុំបន្តបន្ទាប់គ្នា ដោយចាត់ទុកថាជាភាពមិនប្រក្រតី ហើយឱ្យលេខាធិការកត់ត្រាករណីទាំងនេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) ឬ(ទ.១១០១ខ)*<br>*- រំឭកលេខាធិការ ឬអនុប្រធាន គ.ក.ប ឱ្យណែនាំអ្នកបោះឆ្នោតអំពីរបៀបបង្ការសន្លឹកឆ្នោតខូច*<br>*- ធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់អ្នកបោះឆ្នោតទាំងអស់បានបោះឆ្នោតគ្រប់ៗគ្នានៅថ្ងៃបោះឆ្នោត។* |

ឈ. ករណីមានការជំទាស់ ឬការតវ៉ាពីភ្នាក់ងារគណបក្សនយោបាយ

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ឱ្យភ្នាក់ងារគណបក្សនយោបាយលើកការជំទាស់ ឬការតវ៉ានោះមកគាត់ផ្ទាល់*<br>*- ឱ្យបង្ហាញពីមូលហេតុ ឬ/និងភស្តុតាងដែលធ្វើឱ្យគាត់ជឿថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ក។* |

- បើការជំទាស់ ឬការតវ៉ាសមហេតុផល

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ផ្អាកកិច្ចប្រតិបត្តិការបោះឆ្នោតជាបណ្ដោះអាសន្ន*<br>*- ស្ដាប់ការជំទាស់ ឬការតវ៉ានោះ*<br>*- ពិភាក្សាជាមួយសមាជិក គ.ក.ប ដទៃទៀត*<br>*- សម្រេចយល់ព្រម ឬបដិសេធការជំទាស់ ឬការតវ៉ានោះ។* |

○ បើយល់ព្រមតាមការជំទាស់ ឬការតវ៉ានោះ ប្រធាន គ.ក.ប ត្រូវរំឭក និងណែនាំសមាជិក គ.ក.ប និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតអំពីខ្លឹមសារពាក់ព័ន្ធដែលមានចែងក្នុង ច.ប.ក ច.ប.គ.រ ច.វ.ច.ប និង ប.ន.ក ហើយត្រូវរិះរកវិធីណាមួយដើម្បីដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់

○ បើបដិសេធការជំទាស់ ឬការតវ៉ា ប្រធាន គ.ក.ប ត្រូវ៖

- ផ្ដល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះ
- កត់ត្រាការជំទាស់ ឬការតវ៉ានោះទៅក្នុង កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស ឬ/និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ) ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះស្នើសុំឱ្យកត់ត្រា និងយល់ព្រមចុះហត្ថលេខានៅលើ (ទ.១១០១ស) ឬ/និង (ទ.១១០១ខ)។ បើគាត់មិនយល់ព្រមចុះហត្ថលេខាមិនត្រូវកត់ត្រានៅក្នុង (ទ.១១០១ស) ឬ/និង (ទ.១១០១ខ) ឡើយ
- ប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត
- ផ្ដល់ពាក្យបណ្ដឹង (ទ.១២០២) ជូនគាត់សម្រាប់ប្ដឹងទៅ គជ.ខប (ប្រសិនបើគាត់ស្នើសុំ)។

**ចំណាំ៖**

- ការសម្រេចរបស់ប្រធាន គ.ក.ប ត្រូវតែមានប្រសិទ្ធភាព
- អ្នកជំទាស់មិនត្រូវជ្រៀតជ្រែក និងរំខានកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ។

**ញ. ករណីមានអ្នកបោះឆ្នោតរំខានធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត (ទោះបីនៅក្នុងការិយាល័យបោះឆ្នោតក្តី ឬកំពុងឈរជាជួរនៅក្នុងបរិវេណខាងក្នុងក្តី)**

*ប្រធាន គ.ក.ប ត្រូវ* ⇒

- *ណែនាំគាត់ឱ្យរក្សារបៀបរៀបរយ*
- *ស្នើសុំកម្លាំងសន្តិសុខឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួន រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ប្រសិនបើគាត់មិនគោរពតាមការណែនាំ ។*

**ដ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវរំខានដល់កម្រិតដែលធ្វើឱ្យអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី**

ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខ ឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយនៅក្នុងការិយាល័យបោះឆ្នោត ឬបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ។

សកម្មភាពរំខានដល់កម្រិតដែលមិនអាចបោះឆ្នោតបាន រួមមាន៖

- ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្តីគំរាមកំហែង ឬជេរប្រមាថមាក់ងាយ
- ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- ការរុញច្រានដោយប្រើកម្លាំងធ្ងន់
- ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត
- ការអុកឡុកដោយបុគ្គលណាម្នាក់ ឬច្រើននាក់ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត
- ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ
- ការបញ្ចេញឱ្យឃើញអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់។

**ឋ. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ១៥:០០ នៃថ្ងៃបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ* ⇒

- *ចាត់សមាជិកទី២ ឱ្យប្រកាសប្រាប់អ្នកបោះឆ្នោតដែលមានវត្តមានក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត និងត្រូវដើរប្រមូល អ.ខ ឬបណ្ណសម្គាល់ខ្លួនសមាជិក កបយ.ស ពីអ្នកបោះឆ្នោតដែលកំពុងឈរក្នុងជួរដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរខាងក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ឱ្យសមាជិកទី៣*
- *ចាត់សមាជិកទី៣ ឱ្យហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗរហូតដល់អ្នកបោះឆ្នោតចុងក្រោយគេបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយ និងតាមនីតិវិធី។*

**ចំណាំ៖**

- ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានបោះឆ្នោតគ្រប់គ្នាទេនោះ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅមុនម៉ោង ១៥:០០ នៃថ្ងៃបោះឆ្នោតបានឡើយ

- ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាអស់ហើយ ប្រធាន គ.ក.ប អាចប្រកាសបិទការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតរបស់ខ្លួននៅមុនម៉ោង ១៥:០០ បាន
- អ្នកបោះឆ្នោតណាដែលគ្មានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោង ១៥:០០ នៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។

**ឌ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬការគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬ/និងក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត**

| ប្រធាន គ.ក.ប ត្រូវ | - សម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោត ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប<br>- រាយការណ៍ជាបន្ទាន់ជូន គធ.ឃប ដើម្បី គធ.ឃប រាយការណ៍បន្តជូនទៅ គ.ជ.ប។ |
|---|---|

**ឌ-១. ករណីមិនបើកការិយាល័យបោះឆ្នោតនៅមុនថ្ងៃបោះឆ្នោត**

| ប្រធាន គ.ក.ប ត្រូវ | - រាយការណ៍ជាបន្ទាន់ជូន គធ.ឃប ដើម្បី គធ.ឃប រាយការណ៍បន្តជូន គ.ជ.ប<br>- សម្រេចមិនបើកការិយាល័យបោះឆ្នោតរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប។ |
|---|---|

**ឌ-២. ករណីការិយាល័យបោះឆ្នោតមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត**

ប្រធាន គ.ក.ប ត្រូវៈ

- សម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត និងរាយការណ៍ជាបន្ទាន់ជូន គធ.ឃប ដែលត្រូវរាយការណ៍បន្តទៅ គ.ជ.ប (ការិយាល័យបោះឆ្នោតមិនបានបើក ឬត្រូវបានបិទត្រូវតែបិទពេញមួយថ្ងៃ រហូតដល់មានការសម្រេចជាថ្មី)
- ចាត់ចែងបញ្ជូនសម្ភារ ឯកសារបោះឆ្នោតទាំងអស់ទៅ លគធ.ឃប (សម្រាប់ការិយាល័យបោះឆ្នោតមិនបើក)
- ចាត់ចែងវេចខ្ចប់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង សន្លឹកឆ្នោតមិនទាន់ប្រើ និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត (សម្រាប់ការិយាល័យបោះឆ្នោតបានបិទ បន្ទាប់ពីដំណើរការមួយរយៈ)
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ច្បាប់ ប្រើពេលប្រគល់ ទទួល ក្នុងនោះ គធ.ឃប រក្សាទុក ១ច្បាប់ និង គ.ក.ប រក្សាទុក ១ច្បាប់
- ចាត់ចែងធ្វើកំណត់ហេតុដោយឡែកស្តីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ
- បញ្ជូនកំណត់ហេតុទៅ គធ.ឃប រួមជាមួយនឹងសម្ភារ ឯកសារបោះឆ្នោតដែលបានវេចខ្ចប់នោះ
- សន្លឹកឆ្នោតដែលបានបោះឆ្នោតរួចមានក្នុងហិបឆ្នោត និងសន្លឹកឆ្នោតមិនទាន់ប្រើត្រូវទុកជាមោឃៈ

**ឧ-៣. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោត តែសម្ភារ ឯកសារបោះឆ្នោតត្រូវខូចខាត**

ករណីកាលៈទេសៈមានអាសន្នកើតឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុរួច ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតត្រូវខូចខាត គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គធ.ខប ក្នុងនោះ ប្រធាន គ.ក.ប ត្រូវៈ

- ធ្វើរបាយការណ៍ពីសភាពការណ៍ជាក់ស្តែងជូន គធ.ខប
- ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះអមដោយរបាយការណ៍ជូន គធ.ខប
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ច្បាប់ ប្រើពេលប្រគល់ ទទួល ក្នុងនោះ គធ.ខប រក្សាទុក ១ច្បាប់ និង គ.ក.ប រក្សាទុក ១ច្បាប់។

**ឧ-៤. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងក្រោយពេលបិទការបោះឆ្នោត តែសម្ភារ ឯកសារបោះឆ្នោតនៅល្អ**

ករណីកាលៈទេសៈមានអាសន្នកើតឡើងនៅការិយាល័យបោះឆ្នោត ក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចហើយ ហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងឯកសារបោះឆ្នោតនៅរក្សាបានល្អ គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គធ.ខប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតនៅ លគធ.ខប ឬនៅទីតាំងសុវត្ថិភាព។ ក្នុងនោះ ប្រធាន គ.ក.ប ត្រូវចាត់ចែងវេចខ្ចប់ និងបញ្ជូនជាបន្ទាន់ទៅ គធ.ខប នូវៈ

- ហិបឆ្នោតទាំង២ ដែលបានបិទភ្ជិត និងចាក់សោឃ្លុំមានលេខ
- វេចខ្ចប់កញ្ចប់សុវត្ថិភាព «ក$_{ស}$» និងកញ្ចប់សុវត្ថិភាព «ក$_{ខ}$» តែមិនចាំបាច់បិទការសុវត្ថិភាពទេ ដាក់ក្នុងស្បោង «ខ$_{ស}$» និងស្បោង «ខ$_{ខ}$» រួចចាក់សោឃ្លុំមានលេខ
- វេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដោយឡែក
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ច្បាប់ ប្រើពេលប្រគល់ ទទួល ក្នុងនោះ គធ.ខប រក្សាទុក ១ច្បាប់ និង គ.ក.ប រក្សាទុក ១ច្បាប់
- បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង «ខ$_{ស}$» និងស្បោង «ខ$_{ខ}$» និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គធ.ខប។ ក្នុងការបញ្ជូនត្រូវមានការអមដំណើរដោយអនុប្រធាន គ.ក.ប និងសមាជិក គ.ក.ប មួយចំនួនភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងកម្លាំងសន្តិសុខ ២នាក់ផង

**ចំណាំៈ** ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នត្រូវបានកំណត់ដូចខាងក្រោមៈ

- អសន្តិសុខសាធារណៈ
- ទឹកជំនន់ ខ្យល់ព្យុះ ការរញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងៗទៀត
- ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោតដោយយថាហេតុណាមួយ អគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់
- ការរាំងស្ទះផ្នែករដ្ឋបាល ដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន
- ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ។

## VI. **ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត**

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យចាត់វិធានការចាំបាច់ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោតកុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ចាត់ឱ្យសមាជិកទី១ លើកហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត មកដាក់លើតុអនុប្រធាន គ.ក.ប ទន្ទឹមនឹងហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ បន្ទាប់មកត្រូវប្រកាសបិទការបោះឆ្នោតចំពោះមុខសមាជិក គ.ក.ប ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអនុវត្តការងារជាបន្តបន្ទាប់ ដូចតទៅ៖

*ប្រធាន គ.ក.ប ត្រូវ*

- *បិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២នៃហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត*
- *ចុះហត្ថលេខាលើក្រដាសស្តើង ២សន្លឹក និងឱ្យភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាផង (ប្រសិនបើគាត់យល់ព្រម) រួចបិទពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២នៃហិបឆ្នោតនីមួយៗ*
- *បិទគម្របខាងក្រៅនៃហិបឆ្នោតនីមួយៗ រួចចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលទាំង២នៃហិបឆ្នោតទាំងនោះ និងអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បានពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងនោះ*
- *ចាត់លេខាធិការឱ្យកត់ត្រាពេលវេលានៃការបិទការបោះឆ្នោត និងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងនោះនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស និង ទ.១១០១ខ)*
- *ចាត់វិធានការការពារយ៉ាងហ្មត់ចត់នូវហិបឆ្នោតទាំងនោះ នៅការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចពី គ.ជ.ប។*

**ចំណាំ៖** ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោតក្រោយពីការប្រកាសបិទការបោះឆ្នោតដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប។

### ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច

ចំពោះការផ្ទៀងផ្ទាត់នេះ គ.ក.ប ត្រូវធ្វើការផ្ទៀងផ្ទាត់ការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ៖

## ១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

### ក. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់លេខាធិការឱ្យ*
  - *រាប់ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដោយរាប់ចំនួនគំនូសសញ្ញាដែលបានគូសក្នុងកូនប្រអប់ទំនេរ ផ្នែកខាងដើមក្នុងបញ្ជីបោះឆ្នោត*
  - *រាប់ចំនួនអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (មានឈ្មោះក្នុងក្រដាសព័ត៌មាន (ទ.១១០៨) ដែលប្រធាន គ.ក.ប បានកត់ត្រា ប្រសិនបើមាន)*
  - *រាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតសរុបដែលបានបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតសរុបដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។*
- *ចាត់អនុប្រធាន គ.ក.ប ឱ្យ*
  - *បំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើ*
  - *រាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូចដោយឡែកពីគ្នា។*
- *ក្នុងករណីគ្មានអ្នកបោះឆ្នោតដែលអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឱ្យលេខាធិការ និងអនុប្រធាន គ.ក.ប ធ្វើការផ្ទៀងផ្ទាត់គ្នា ប្រសិនបើឃើញថា ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនគំនូសលើបញ្ជីបោះឆ្នោតដែលបញ្ជាក់អ្នកដែលបានមកបោះឆ្នោត ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនស្មើគ្នានោះក្នុង ទ.១១០១ស*
- *ក្នុងករណីមានអ្នកបោះឆ្នោតដែលបានអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឱ្យលេខាធិការ និងអនុប្រធាន គ.ក.ប ធ្វើការផ្ទៀងផ្ទាត់គ្នា ប្រសិនបើឃើញថា ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើ ស្មើគ្នានឹងចំនួនគំនូសលើបញ្ជីបោះឆ្នោតបញ្ជាក់អ្នកបានមកបោះឆ្នោត ដកនឹងចំនួនអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បន្ទាប់មកចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនស្មើគ្នានោះចូលក្នុង ទ.១១០១ស*
- *ប្រសិនបើក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា មានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ (មិនគិតសន្លឹកឆ្នោតខូច) និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ចាត់លេខាធិការ និងអនុប្រធាន គ.ក.ប ឱ្យផ្ទៀងផ្ទាត់ជាលើកទី២ ទៀត*
- *ប្រសិនបើភាពខុសគ្នានៅតែមាន ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនដែលខុសគ្នានោះក្នុង ទ.១១០១ស*
- *បន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត*
- *ចាត់លេខាធិការឱ្យកត់ត្រានូវចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទៅក្នុង ទ.១១០១ស*
- *ចាត់សមាជិកទី២ ឱ្យចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ដើម្បីធ្វើមោឃភាព*
- *ឱ្យអនុប្រធាន គ.ក.ប ដាក់សន្លឹកឆ្នោតដែលមិនបានប្រើ និងត្រូវបានចោះ ឬកាត់រួច និងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែមួយរួចបិទឱ្យជិត។*

ខ. រូបមន្តនៃការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

គោលបំណងនៃការផ្ទៀងផ្ទាត់ គឺចង់បញ្ជាក់រវាងចំនួនអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងចំនួនសន្លឹកឆ្នោតនៅក្នុងហិបឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

តាង៖

**ក** ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង (សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ)

**ខ** ចំនួនសន្លឹកឆ្នោតខូច

**គ** ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ

**ឃ** ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

**ច** ចំនួនគំនូសលើបញ្ជីបោះឆ្នោតដែលបញ្ជាក់អ្នកបានមកបោះឆ្នោត

**ឆ** ចំនួនអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ខ.១ ករណីគ្មានអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ឆ=០)

រូបមន្តមានដូចខាងក្រោម៖

| ឃ = ក – (ខ + គ) = ច |
|---|

ខ.២ ករណីមានអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ឆ≥១)

រូបមន្តមានដូចខាងក្រោម៖

| ឃ = ក – (ខ + គ) = ច – ឆ |
|---|

គ. កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១០១ស) និងការប្រើប្រាស់

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់លេខាធិការឱ្យកត់ត្រាជាមុននូវលេខសោឃ្លុំដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់ស្បោង «ខស» ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងបោះត្រាសម្ងាត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ*
- *ឱ្យលេខាធិការបំពេញ និងចុះហត្ថលេខាលើ ទ.១១០១ស ទាំង ២ច្បាប់*
- *ពិនិត្យ រួចចុះហត្ថលេខាលើ ទ.១១០១ស ទាំង ២ច្បាប់ រួចឱ្យលេខាធិការបោះត្រា គ.ក.ប*
- *ដាក់បង្ហាញកំណត់ហេតុនេះឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ*
- *អញ្ជើញភ្នាក់ងារគណបក្សនយោបាយចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះ។ ការមិនចូលរួមចុះហត្ថលេខាជាសាក្សីពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ។*

*ទ.១១០១ស ចំនួន ២ច្បាប់*

- *១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្ទង់ថា «កំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គ.ជ.ប»*
- *១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ពមានកាខ្ទង់ថា «កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គធ.ខប»។*

### ឃ. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «កស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ប្រធាន គ.ក.ប ត្រូវរៀបចំវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមាន៖

- ស្រោមសំបុត្រដាក់ ទ.១១០១ស ទ.១១០៨ស ទ១១០២ស ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងពេលបោះឆ្នោត និងក្រដាសព័ត៌មានអះអាងមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១០៤)
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ប្រសិនបើមាន)
- ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)

**ចំណាំ៖**

- ផ្ទៀងផ្ទាត់ឡើងវិញឱ្យប្រាកដថា សម្ភារ ឯកសារខាងលើត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ គ្រប់សព្វហើយ
- កុំទាន់បិទភ្ជិតកញ្ចប់សុវត្ថិភាព «កស» ដោយការសុវត្ថិភាពនៅពេលនេះ ព្រោះត្រូវរង់ចាំដាក់ ទ.១១០៨ស និង ទ.១១០២ស នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ចូលក្នុងកញ្ចប់សុវត្ថិភាព «កស» បន្ថែមទៀត នៅពេលដំណើរការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់
- សរសេរលេខកូដការិយាល័យលើកញ្ចប់សុវត្ថិភាព «កស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្នែកខាងក្រៅដោយប៊ិកហ្វឺតលុបមិនជ្រះ
- រក្សាទុកកញ្ចប់សុវត្ថិភាព «កស» យ៉ាងហ្មត់ចត់ និងមានសុវត្ថិភាពមុន និងក្នុងពេលរាប់សន្លឹកឆ្នោត។

( មិនទាន់បិទការសុវត្ថិភាព )

**កញ្ចប់សុវត្ថិភាព "កស"**

- ស្រោមសំបុត្រដាក់ ទ.១១០១ស ទ.១១០៨ស ទ.១១០២ស ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងពេលបោះឆ្នោត និងក្រដាសព័ត៌មានអះអាងមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១០៤)
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ប្រសិនបើមាន)
- ស្បោងប្លាស្ទិកដាក់ «សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។

២. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត

បន្ទាប់ពីការអនុវត្តការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូចនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រួចរាល់ ប្រធាន គ.ក.ប ត្រូវចាត់ចែងការផ្ទៀងផ្ទាត់តួលេខដូចគ្នានេះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជាបន្តទៀត ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីនៃការផ្ទៀងផ្ទាត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចមានបញ្ជាក់ក្រោមចំណុច ១ នៃលេខ VI។

**ចំណាំ៖**

- ចាត់ចែងឱ្យប្រើប្រាស់សម្ភារ ឯកសារ ស្រោមសំបុត្រ ស្បោង ឬកញ្ចប់ និងទម្រង់បែបបទផ្សេងៗ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តតែប៉ុណ្ណោះ។
- កញ្ចប់សុវត្ថិភាព «ក₂» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តដែលពុំទាន់បិទការសុវត្ថិភាព នោះមានតែ៖

(មិនទាន់បិទការសុវត្ថិភាព)

**កញ្ចប់សុវត្ថិភាព «ក₂»**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

- ស្រោមសំបុត្រដាក់ ទ.១១០១ខ ទ.១១០៨ខ ទ.១១០២ខ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» នៃក្រុមប្រឹក្សារាជធានី ខេត្ត (ប្រសិនបើមាន)
- ស្បោងប្លាស្ទិកដាក់ «សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ» នៃក្រុមប្រឹក្សារាជធានី ខេត្ត
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត(ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។

## VII. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតត្រូវធ្វើឡើងដោយផ្ទាល់នៅតាមការិយាល័យបោះឆ្នោតនីមួយៗ លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះដោយ គ.ជ.ប។ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់ចែងប្រមូលទុកដាក់ និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព។

ការរាប់សន្លឹកឆ្នោតត្រូវធ្វើបន្ទាប់ពីការបិទការបោះឆ្នោត និងការធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចរាល់នាល្ងាចថ្ងៃអាទិត្យទី២៦ ខែឧសភា ឆ្នាំ២០២៤។

ការផ្ទៀងផ្ទាត់ និងការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែមួយកន្លែងឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ហើយធ្វើចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវចុះវត្តមានក្នុងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ហើយមានសិទ្ធិចូលរួមសង្កេតមើលបានតែម្នាក់ក្នុង ១គណបក្ស និងក្នុង ១សមាគម អង្គការមិនមែនរដ្ឋាភិបាល ហើយអាចផ្លាស់ប្តូរអ្នកបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យចប់ចុងចប់ដើម។

ដោយឡែក អ្នកសង្កេតការណ៍ក៏ត្រូវចុះវត្តមានបន្ថែម និងពេលម៉ោងចូល ចេញក្នុងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០)។

ប្រធាន គ.ក.រ ត្រូវចាត់ចែងរៀបចំតាមគំរូប្លង់សម្រាប់ការរាប់សន្លឹកឆ្នោត និងមានវិធានការការពារសន្តិសុខក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

១. **ការចាត់ចែងរៀបចំ**

*ប្រធាន គ.ក.រ ត្រូវ*

- *ចាត់ចែងរៀបចំតាមគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត*
- *ចាត់ចែងរៀបចំតុធំមួយ ឬតុតូចច្រើនផ្គុំគ្នា និងកៅអី៥ សម្រាប់សមាជិក គ.ក.រ ដាក់ចំកណ្តាលបន្ទប់ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចដើរចុះឡើងជុំវិញតុ ដើម្បីងាយស្រួលដល់ពួកគាត់មើលឃើញសកម្មភាពនៃការរាប់សន្លឹកឆ្នោត*
- *ដាក់ផ្ទាំងក្រដាសធំមួយសន្លឹកលើជញ្ជាំង ឬលើក្តារខៀន សម្រាប់កត់ត្រាសំឡេងឆ្នោត*
- *ដាក់ហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ចំកណ្តាលតុ និងដាក់កញ្ចប់សុវត្ថិភាព «កស» និងកញ្ចប់សុវត្ថិភាព «ក១» រាល់សម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទចាំបាច់សម្រាប់ប្រតិបត្តិការរាប់សន្លឹកឆ្នោតលើតុត្រង់កន្លែងប្រធាន គ.ក.រ អង្គុយ*
- *ត្រៀមភ្លើងសម្រាប់បំភ្លឺ ក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់*
- *អង្គុយចុងតុម្ខាងទល់មុខលេខាធិការ។ ឱ្យអនុប្រធាន គ.ក.រ និងសមាជិកទី១ អង្គុយអមសងខាងទល់មុខគ្នា*
- *ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យអ្នកដទៃចេញចូល ក្រៅពីសមាសភាព គ.ក.រ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលត្រូវបានអនុញ្ញាត។ មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត*
- *រក្សាហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្តដែលនឹងត្រូវរាប់ជាបន្ទាប់ឱ្យបានត្រឹមត្រូវ។*




**គំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត**

**២. វិធានការចំពោះករណីអ្នកធ្វើសកម្មភាពមិនប្រក្រតី ដើម្បីចង់ដឹងអ្នកបោះឆ្នោតបានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយក្នុងពេលកំពុងរាប់សន្លឹកឆ្នោត**

ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងពេលកំពុងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ហាមជនគ្រប់រូបធ្វើសកម្មភាព ទោះតាមរូបភាពណាក៏ដោយ ក្នុងគោលបំណងកត់សម្គាល់ដើម្បីឱ្យដឹងថា តើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

*ប្រធាន គ.ក.រ ត្រូវ* →

- *ព្រមានផ្ទាល់មាត់ចំពោះការធ្វើសកម្មភាពលើកទី១*
- *បណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក ច.ប.ត.រ និង ច.វ.ច.ប ចំពោះការធ្វើសកម្មភាពដដែលជាលើកទី២*
- *ចាត់លេខាធិការឱ្យកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត*
- *បញ្ជូនកំណត់ហេតុនេះជូន គធ.ខប ជាបន្ទាន់។*

នៅពេលទទួលបានកំណត់ហេតុនេះ គធ.ខប ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានអំពើរំលោភពិតប្រាកដមែន គធ.ខប ត្រូវប្តឹងទៅ គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ**

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេសប្រធាន គ.ក.រ និងអនុប្រធាន គ.ក.រ ត្រូវយល់ដឹងឱ្យបានច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

**ក. សន្លឹកឆ្នោតបានការ**

សន្លឹកឆ្នោតបានការគឺជាៈ

- សន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពណ៌ផ្ទៃមេឃ និងសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តពណ៌ស
- សន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង និង
- សន្លឹកឆ្នោតដែលមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ។

**ខ. សន្លឹកឆ្នោតមិនបានការ**

សន្លឹកឆ្នោតមិនបានការត្រូវចាត់ទុកជាមោឃៈ មាន ៥ប្រភេទ ដូចខាងក្រោមៈ

**ខ.១. សន្លឹកឆ្នោតមិនផ្លូវការ**

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតដែលមានពណ៌ផ្សេង ខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប

- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ
- សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬនិងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្ដល់ឱ្យ គ.ក.ប ពាក់ព័ន្ធ។

**ខ.២. សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែរ តែ គ.ក.រ ពុំអាចសន្និដ្ឋានថា បោះឆ្នោតគាំទ្រឱ្យគណបក្សនយោបាយណាមួយ**

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)
- សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស
- សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយ ដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ។

**ខ.៣. សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត**

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុង ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត។

**ខ.៤. សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូចមិនអាចយកជាការបាន**

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ

- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងនៅផ្នែកខាងខ្នង ដែលមិនអាចមើលឃើញនូវរូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ។

**ខ.៥. សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ**

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- សន្លឹកឆ្នោតមានបោះត្រា ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

**ចំណាំ៖** ក្នុងកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត គ.ក.រ ត្រូវធ្វើការកំណត់សន្លឹកឆ្នោតបានការ ឬមិនបានការ ដោយផ្អែកតាមលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ដូចបានបញ្ជាក់ខាងលើនេះ។

**ឧទាហរណ៍**

**ក. គំរូសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ព**




**ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង**

**ខ. គំរូសន្លឹកឆ្នោតមិនបានការត្រូវបានចាត់ទុកជាមោឃៈ**

**ខ.១ សន្លឹកឆ្នោតដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ**

សន្លឹកឆ្នោតទាំងឡាយណាដែលមិនបានផ្តល់ឱ្យជាផ្លូវការដោយមន្ត្រីការិយាល័យបោះឆ្នោត ឬមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ក្លែងបន្លំ មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ រួមមាន៖




១. សន្លឹកឆ្នោតមានខ្នាតតូចជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




២. សន្លឹកឆ្នោតមានខ្នាតធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៣. សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៤. សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៥.សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៦.សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៧.សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៨. សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ(ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។

ខ.២ សន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូស ដែលពុំអាចសន្និដ្ឋានថា បោះគាំទ្រគណបក្សនយោបាយណាមួយ




១. សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ ,សន្លឹកឆ្នោតទំនេរ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




២. សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងទន្ទឹមនឹងគណបក្សនយោបាយលើស ពីមួយគណបក្ស (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៣. សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់គណបក្សនយោបាយឬមិនចំលេខរៀងនៃគណបក្សនយោបាយណាមួយ ទោះបីជាមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងគណបក្សនយោបាយណាមួយក៏ដោយ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។

ខ.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត




១. សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




២. សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៣. សន្លឹកឆ្នោតដែលមានបិទតែមប្រ៊ី ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗភ្ជាប់នឹងប្រអប់នៃគណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នង (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៤. សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




៥.សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។

### ខ.៤ សន្លឹកឆ្នោតដែលមានរហែក ឬប្រឡាក់ខូច




១. សន្លឹកឆ្នោតរហែក ដាច់បាត់លេខរៀង ឬប្រអប់នៃគណបក្សនយោបាយណាមួយ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។




២. សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។



៣. សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរ ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។

## ខ.៥ សន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការ



១. សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង។



២. សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ចំនួនគណបក្សនយោបាយអាចប្រែប្រួលទៅតាមភាពជាក់ស្តែង)។

៤. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងការវេចខ្ចប់

ប្រធាន គ.ក.រ ត្រូវប្រកាសចាប់ផ្ដើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន និងចាត់ចែងការងារតាមប្រភេទនៃក្រុមប្រឹក្សានីមួយៗ ដូចខាងក្រោម៖

ក. ការរៀបចំសម្ភារ ឯកសារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

*ប្រធាន គ.ក.រ ត្រូវដាក់ក្បែរខ្លួនគាត់*

- *កញ្ចប់សុវត្ថិភាព «កស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ*
- *បញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) និងបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ( ទ.១១២០)*
- *ទ.១២០២ សម្រាប់ជូនភ្នាក់ងារគណបក្សនយោបាយ (ប្រសិនបើគាត់ស្នើសុំ)*
- *ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រសម្រាប់ដាក់សន្លឹកឆ្នោតមិនបានការ*
- *កៅស៊ូកង។*

*ប្រធានគ.ក.រ ត្រូវឱ្យអនុប្រធានគ.ក.រ*

- *តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ចំនួន ១ច្បាប់ និងឱ្យចម្លងតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូចពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស)។*

*ប្រធានគ.ក.រ ត្រូវឱ្យលេខាធិការ*

- *ទ.១១០២ស ចំនួន ៣ច្បាប់*
- *តារាងកត់ត្រាសំឡេងឆ្នោត ទ.១១០៨ស ចំនួន ១ច្បាប់*
- *ស្រោមសំបុត្រដាក់ ទ.១១០១ស ទ.១១០៨ស ទ.១១០២ស ដែលដកយកពីកញ្ចប់សុវត្ថិភាព «កស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រាប់គាត់ឱ្យបំពេញតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ដោយចម្លងតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូច ចំនួនអ្នកបោះឆ្នោតបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតួលេខពាក់ព័ន្ធផ្សេងទៀតដែលមាននៅក្នុង ទ.១១០១ស។*

*ប្រធាន គ.ក.រ ត្រូវឱ្យសមាជិកទី១*

- *ផ្ទាំងក្រដាសធំ ១ផ្ទាំង ដែលត្រូវបិទភ្ជាប់នឹងជញ្ជាំង ឬក្ដារខៀន និងប៊ិកហ្វឺតធំ ១ដើម សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឱ្យចម្លងតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូចពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស)។*

ក.១. ការពិនិត្យហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

*ប្រធាន គ.ក.រ ត្រូវ*

- *ពិនិត្យផ្ទៀងផ្ទាត់សោឃ្លុំមានលេខទាំង ២ ដែលចាក់ជាប់គម្របខាងក្រៅនៃហិបឆ្នោតក្រុមប្រឹក្សាក្រុងស្រុកខណ្ឌ ឱ្យប្រាកដថាមានសភាពនៅដដែលដូចដើម*
- *កាត់ផ្ដាច់សោឃ្លុំទាំង ២ ដោយកន្ត្រៃ ឬកាំបិត រួចបើកគម្របខាងក្រៅចេញ*
- *ផ្ទៀងផ្ទាត់សោឃ្លុំមានលេខដែលចាក់ជាប់គន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត នឹងក្រដាសស្ទើងដែលបិទពាសលើសន្ទះបិទភ្ជិតប្រឡោះស៊កសន្លឹកឆ្នោតឱ្យប្រាកដថា គ្មានការរុះរើ*

*ប្រធាន គ.ក.រ ត្រូវ(ត)*

- *កាត់ផ្ដាច់សោឃ្លុំនោះចេញ ហែកក្រដាសបិទពាសនេះចោល*
- *បើកគម្របខាងក្នុងនៃហិបឆ្នោត*
- *ចាក់សន្លឹកឆ្នោតចេញឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុត្រង់ចន្លោះអនុប្រធាន គ.ក.រ និងសមាជិកទី១*
- *ដាក់ហិបឆ្នោតទទេនៅក្បែរខ្លួនគាត់។*




**ការចាក់សន្លឹកឆ្នោតចេញពីហិបឆ្នោត**

ក.២. ការរាប់ចំនួនសន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលបានចាក់ចេញពីហិបឆ្នោត

ប្រធាន គ.ក.រ ត្រូវចាត់៖

*សមាជិកទី១*

- *រើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត និងដែលមិនស្ថិតនៅជាប់នឹងសន្លឹកឆ្នោតចេញពីគំនរសន្លឹកឆ្នោត (ប្រសិនបើមាន) រួចដាក់ក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់។*

*លេខាធិការ*

- *កត់ត្រាករណីមានវត្ថុដែលមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)។*

*អនុប្រធាន គ.ក.រ និងសមាជិកទី១*

- *លា និងតម្រៀបសន្លឹកឆ្នោតដែលមានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ដោយដាក់ផ្កាប់ជាបាច់ៗ (១បាច់ មាន ២៥សន្លឹក) ដាក់នៅពំនូកទី១*
- *ដាក់សន្លឹកឆ្នោតគ្មានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង នៅពំនូកទី២(ប្រសិនបើមាន)*
- *រាប់ចំនួនសន្លឹកឆ្នោតទាំង ២ពំនូកនេះឱ្យបានត្រឹមត្រូវ*
- *រាយការណ៍ជូនប្រធាន គ.ក.រ នូវចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ*
- *ជូនសន្លឹកឆ្នោតទាំង ២ពំនូកទៅប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ពំនូកទី១ នៅខាងឆ្វេងដៃ និងពំនូកទី២ នៅខាងស្ដាំដៃ (ជូនប្រធាន គ.ក.រ ក្រោយពីបានផ្ទៀងផ្ទាត់រួច)។*

### ក.៣. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត

អនុវត្តតាមរូបមន្តៈ

| | | | | |
|---|---|---|---|---|
| ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប | = | ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត | | |

ឬ

| | | | | |
|---|---|---|---|---|
| ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប | = | ចំនួនសន្លឹកឆ្នោតបានទទួលជាក់ស្តែង | - | ចំនួនសន្លឹកឆ្នោតខូច + ចំនួនសន្លឹកឆ្នោតមិនបានប្រើ |

ឬ

| | | | | |
|---|---|---|---|---|
| ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប | = | ចំនួនគំនូសលើបញ្ជីបោះឆ្នោតបញ្ជាក់អ្នកបានមកបោះឆ្នោត | - | ចំនួនអ្នកបោះឆ្នោតដែលបានអះអាងមិនបានបោះឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ |

បើស្មើគ្នា លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននោះចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)។

បើខុសគ្នា ប្រធានត្រូវផ្ទៀងផ្ទាត់ និងរាប់ឡើងវិញយ៉ាងហ្មត់ចត់ជាលើកទី២។

បើនៅតែខុសគ្នានោះៈ

*ប្រធាន គ.ក.រ ត្រូវ*

- *ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនខុសគ្នានោះចូលក្នុង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)*
- *ប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនោះ ដើម្បីឱ្យអ្នកទាំងនោះបានដឹង និងងាយស្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផល។*

### ក.៤. ការកំណត់សុពលភាព និងការប្រកាសសន្លឹកឆ្នោតនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ

ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតមានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ១សន្លឹកម្តងៗ រហូតដល់អស់សន្លឹកឆ្នោតពីពំនូកទី១ ដើម្បីពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ។




*ការកំណត់សុពលភាពសន្លឹកឆ្នោត*

**សន្លឹកឆ្នោតបានការ**

| ប្រធាន គ.ក.រ ត្រូវ | |
|---|---|
| | - *ប្រកាសឱ្យឮៗនូវឈ្មោះគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ*<br>- *កាន់លើកបង្ហាញយឺតៗផ្នែកខាងមុខ ខាងខ្នងឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បានឃើញច្បាស់ តែមិនអនុញ្ញាតឱ្យប៉ះពាល់ ឬកាន់សន្លឹកឆ្នោតនោះឡើយ*<br>- *ដាក់សន្លឹកឆ្នោតបានការនោះទៅតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ*<br>- *ចាត់អនុប្រធាន គ.ក.រ និងលេខាធិការឱ្យគូសពិន្ទុ១ នៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស)*<br>- *ចាត់សមាជិកទី១ ឱ្យគូសពិន្ទុ១ នៅលើផ្ទាំងក្រដាសធំដោយប៊ិកហ្វឺត*<br>- *ប្រសិនបើមានការជំទាស់ពីភ្នាក់ងារគណបក្សនយោបាយក្នុងការកំណត់សុពលភាព ដាក់សន្លឹកឆ្នោតជំទាស់នោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការនៅខាងស្ដាំដៃសិន ដែលនឹងត្រូវយកមកពិនិត្យផ្ទៀងផ្ទាត់ និងកំណត់ម្ដងទៀតជាចុងក្រោយ។* |

**សន្លឹកឆ្នោតមិនបានការ**

| ប្រធាន គ.ក.រ ត្រូវ | |
|---|---|
| | - *ប្រកាសឱ្យឮៗបញ្ជាក់ពីហេតុផលសម្រាប់សន្លឹកឆ្នោតមិនបានការនោះ*<br>- *កាន់លើកបង្ហាញយឺតៗផ្នែកខាងមុខ ខាងខ្នងឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតមិនបានការនោះ តែមិនអនុញ្ញាតឱ្យប៉ះពាល់ ឬកាន់សន្លឹកឆ្នោតនោះឡើយ*<br>- *ដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការនៅខាងស្ដាំដៃ។* |

**ក.៥. ការពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្ដងទៀតជាចុងក្រោយនូវរាល់សន្លឹកឆ្នោតក្នុងពំនូកសន្លឹកឆ្នោតមិនបានការ**

ប្រធាន គ.ក.រ ត្រូវបន្តយកសន្លឹកឆ្នោតម្ដង ១សន្លឹកៗពីពំនូកសន្លឹកឆ្នោតមិនបានការ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាចុងក្រោយ។ ប្រសិនបើប្រធាន គ.ក.រ សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ប្រធាន គ.ក.រ ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ ដើម្បីកំណត់ជាចុងក្រោយថា ជាសន្លឹកឆ្នោតបានការ ឬមិនបានការ។ ប្រសិនបើប្រធាន គ.ក.រ សម្រេចថាជាសន្លឹកឆ្នោតបានការវិញ ត្រូវអនុវត្តដូចចំណុច ក.៤. ត្រង់ **«សន្លឹកឆ្នោតបានការ»** ខាងលើ។ ប្រសិនបើប្រធាន គ.ក.រ សម្រេចថាជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដដែល។

ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ មិនឯកភាពចំពោះការសម្រេចរបស់ប្រធាន គ.ក.រ ក្នុងការកំណត់សន្លឹកឆ្នោតបានការ និងមិនបានការខាងលើនោះ៖

- ភ្នាក់ងារគណបក្សនយោបាយនោះមានសិទ្ធិជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)

▪ ខ្លឹមសារ និងហេតុផលនៃការជំទាស់នេះ មិនត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារគណបក្សនយោបាយនោះ មិនយល់ព្រមចុះហត្ថលេខាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)

▪ ការសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត

▪ ប្រធាន គ.ក.រ ត្រូវជូនពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ច្បាប់ ដល់ភ្នាក់ងារគណបក្សនយោបាយនោះ (ប្រសិនបើគាត់ស្នើសុំ) សម្រាប់បំពេញពាក្យបណ្តឹងទៅ គជ.ឃប។

**ក.៦. ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

❖ **ការបូកសរុបលទ្ធផល**

*ប្រធាន គ.ក.រ ត្រូវ* ⇒

- *ឱ្យអនុប្រធាន គ.ក.រ និងលេខាធិការ បូកសរុបលើ ទ.១១០៨ស រៀងៗខ្លួន*
- *ឱ្យសមាជិកទី១ បូកសរុបលើផ្ទាំងក្រដាសធំ*

⇒

- *ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ*
- *ចំនួនសន្លឹកឆ្នោតបានការសរុប*
- *ចំនួនសន្លឹកឆ្នោតមិនបានការសរុប*
- *ផ្ទៀងផ្ទាត់តួលេខគ្នា។*

*ប្រធាន គ.ក.រ ត្រូវ* ⇒

- *រាប់ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ*
- *រាប់ចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់*
- *បូកសរុបចំនួនសន្លឹកឆ្នោតបានការគ្រប់គណបក្សនយោបាយទាំងអស់*
- *បូកសរុបបញ្ចូលគ្នាចំនួនសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ*
- *ផ្ទៀងផ្ទាត់តួលេខខាងលើជាមួយតួលេខរបស់អនុប្រធាន គ.ក.រ លេខាធិការ និងសមាជិកទី១។*

❖ **រូបមន្តនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

| | | |
|---|---|---|
| ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត | = | ចំនួនសន្លឹកបានការសរុប + ចំនួនសន្លឹកឆ្នោតមិនបានការសរុប |

- ប្រសិនបើឃើញស្មើគ្នា ប្រធាន គ.ក.រ ត្រូវ៖
  ▪ ចុះហត្ថលេខារួមជាមួយលេខាធិការ និងបោះត្រា គ.ក.ប លើ (ទ.១១០៨ស) ទាំង ២ច្បាប់ និងលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត
  ▪ ប្រកាសជាចំហនូវលទ្ធផលនៃការរាប់សន្លឹកឆ្នោត
  ▪ ចាត់លេខាធិការឱ្យកត់ត្រាតួលេខចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗចំនួនសន្លឹកឆ្នោតបានការសរុប និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)។
- ប្រសិនបើឃើញមិនស្មើគ្នា ប្រធាន គ.ក.រ ត្រូវ៖

▪ រាប់សន្លឹកឆ្នោតបានការតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗឡើងវិញ និងរាប់សន្លឹកឆ្នោតមិនបានការ រួចធ្វើប្រមាណវិធីឡើងវិញ។ បើនៅតែខុសគ្នាដដែល ហើយគ្មានសន្លឹកឆ្នោតដែលត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយការធ្លាក់ជ្រុះ ឬ/និងគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេនោះ សន្មតថា ភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ

▪ ចាត់លេខាធិការឱ្យកត់ត្រាតួលេខទាំងនេះចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)។

- ក្រោយការផ្ទៀងផ្ទាត់ ប្រធាន គ.ក.រ ត្រូវចាត់ចែង៖

▪ ចងនឹងកៅស៊ូកងនូវសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗដោយឡែកពីគ្នា

▪ ចងនឹងកៅស៊ូកង និងដាក់សន្លឹកឆ្នោតមិនបានការទាំងអស់ក្នុងស្រោមសំបុត្រដែលមានកាខ្វងថា «សន្លឹកឆ្នោតមិនបានការ»។

**ក.៧. ការប្រើប្រាស់តារាងកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១០៨ស) និងកំណតហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)**

**- ការប្រើប្រាស់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស)**

តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ចំនួន ២ច្បាប់ ចុះហត្ថលេខាដោយប្រធាន គ.ក.រ និងលេខាធិការ ព្រមទាំងបោះត្រា គ.ក.ប ផង ត្រូវបានប្រើប្រាស់ ដូចខាងក្រោម៖

ទ.១១០៨ស ចំនួន ២ច្បាប់

- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)" ផ្ញើជូន គ.ជ.ប (ដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស»)
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គធ.ខប"។

**- ការប្រើប្រាស់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)**

កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ចំនួន៣ច្បាប់ ដែលចុះហត្ថលេខាដោយប្រធាន គ.ក.រ និងលេខាធិការ ព្រមទាំងបោះត្រា គ.ក.ប ផងនោះ ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

ទ.១១០២ស ចំនួន ៣ច្បាប់

- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស)" ផ្ញើជូន គ.ជ.ប (ដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស»)
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រតែ ១ មានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គធ.ខប"
- ១ច្បាប់ ឱ្យសមាជិកទី២ បិទផ្សាយនៅមុខទីតាំងការិយាល័យបោះឆ្នោត។

**ចំណាំ៖**

- ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចូលរួមចុះហត្ថលេខាជាសាក្សី។ ការមិនព្រមចុះហត្ថលេខាជាសាក្សីពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកឯកសារទាំងនេះជាមោឃៈបានឡើយ
- សមាជិកទី២ ត្រូវបញ្ជូនជាបន្ទាន់នូវស្រោមសំបុត្រដាក់ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមប្រភេទក្រុមប្រឹក្សានីមួយៗទៅ គធ.ខប ដោយផ្ទាល់ សម្រាប់បញ្ចូលទិន្នន័យជាលទ្ធផលបឋម។ ស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ត្រូវបញ្ជូនស្របពេលជាមួយគ្នានេះដែរ។

**ខ. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍**

**ខ.១. ការវេចខ្ចប់ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ**

គ.ក.រ ត្រូវដាក់សម្ភារ ឯកសារបោះឆ្នោតក្នុងស្បោងប្លាស្ទិកសម្រាប់ត្រៀមបញ្ជូនទៅ គធ.ខប។

| | |
|---|---|
| *ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មាន* | *- សន្លឹកឆ្នោតបានការដែលបានចងនឹងកៅស៊ូតាមគណបក្សនយោបាយនីមួយៗ*<br>*- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ*<br>*- ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតដែលចុះហត្ថលេខាដោយប្រធាន គ.ក.រ និងលេខាធិការ និងបោះត្រា គ.ក.ប ព្រមទាំងអាចមានការចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយ*<br>*- ស្រោមសំបុត្រដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន)។* |
| *ប្រធាន គ.ក.រ ត្រូវ* | *- ចងភ្ជិតមាត់ស្បោងប្លាស្ទិក*<br>*- សរសេរលេខកូដការិយាល័យបោះឆ្នោតដោយប៊ិកហ្វឺតធំលុបមិនជ្រះនៅផ្នែកខាងក្រៅនៃស្បោងប្លាស្ទិក។* |

**ខ.២. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «កស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

ប្រធាន គ.ក.រ ត្រូវធានាថា បានដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស» នូវ៖

- ស្រោមសំបុត្រដាក់ ទ.១១០១ស ចំនួន ១ច្បាប់ ទ.១១០៨ស ចំនួន ១ច្បាប់ និង ទ.១១០២ស ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងពេលបោះឆ្នោត និងក្រដាសព័ត៌មានអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១០៩)
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់«សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»

- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)
- ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន)។

ប្រធាន គ.ក.រ ត្រូវផ្ទៀងផ្ទាត់ បិទភ្ជិតកញ្ចប់សុវត្ថិភាព«កស»ដោយការសុវត្ថិភាព បំពេញលេខកូដការិយាល័យបោះឆ្នោត ដោយបិកហ្វឺតធំលុបមិនជ្រះ។

**កញ្ចប់សុវត្ថិភាព «កស»**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

- ស្រោមសំបុត្រដាក់ ទ.១១០១ស ចំនួន ១ច្បាប់ ទ.១១០៨ស ចំនួន ១ច្បាប់ និងទ.១១០២ស ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើក្នុងពេលបោះឆ្នោត និងក្រដាសព័ត៌មានអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១០៥)
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់«សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)
- ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន)។

**ខ.៣. ការវេចខ្ចប់ស្បោង «ខស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ការបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)**

លេខាធិការត្រូវបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោតដែលមានក្នុងស្បោង «ខស» នៅក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.រ។

ទ.១១០៧ ចំនួន ៣ ច្បាប់:
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ខស»
- ១ច្បាប់ ដាក់ក្នុងហោប៉ៅក្រៅស្បោង «ខស»
- ១ច្បាប់ ប្រើក្នុងការប្រគល់ ទទួល នៅ លគផ.ខប។

គ.ក.រ ត្រូវដាក់ក្នុងស្បោង «ខស» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នូវ៖

- កញ្ចប់សុវត្ថិភាព «កស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់
- ស្រោមសំបុត្រតូចដាក់ត្រា គ.ក.ប (ដាក់ក្រោយពេលបានបោះត្រាលើ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួចរាល់ហើយ)។

**ចំណាំ៖**

- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចសង្កេតមើលការវេចខ្ចប់នេះ
- ប្រធាន គ.ក.រ ត្រូវផ្ទៀងផ្ទាត់ ចងភ្ជិត ចាក់សោឃ្លុំមានលេខ និងសរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើបិកហ្វឺតលុបមិនជ្រះ និងដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង«ខស»។




**៥. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ការវេចខ្ចប់ និងការបញ្ជូនទៅ គធ.ខប**

បន្ទាប់ពីបានអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត និងបំពេញទម្រង់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបញ្ចប់រួចរាល់ហើយ គ.ក.រ ត្រូវបន្តអនុវត្តការរាប់សន្លឹកឆ្នោត និងការបំពេញទម្រង់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាបន្ទាន់បន្តទៀត បន្ទាប់មកធ្វើការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ។

**ចំណាំ៖**

- ប្រធាន គ.ក.រ ត្រូវចាត់ចែងអនុវត្តការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត តាមលំនាំនីតិវិធីនៃការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចមានបញ្ជាក់ក្នុងចំណុចទី៤ លេខ VII ខាងលើ
- ចាត់ចែងឱ្យប្រើប្រាស់សម្ភារ ឯកសារបោះឆ្នោត ស្រោមសំបុត្រ ស្បោង ឬកញ្ចប់ និងទម្រង់បែបបទសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តតែប៉ុណ្ណោះ
- ក្នុងកញ្ចប់សុវត្ថិភាព «ក₂» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តមាន៖
  - ស្រោមសំបុត្រដាក់ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ) ចំនួន ១ច្បាប់ តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ខ) ចំនួន ១ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ខ) ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
  - ស្រោមសំបុត្រដាក់ត្រាសម្ងាត់
  - ស្រោមសំបុត្រដាក់សន្លឹកឆ្នោតខូច (ប្រសិនបើមាន)
  - ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
  - ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ
  - ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន)

**កញ្ចប់សុវត្ថិភាព «ក₂»**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

- ស្រោមសំបុត្រដាក់ ទ.១១០១ខ ចំនួន ១ច្បាប់ ទ.១១០៨ខ ចំនួន ១ច្បាប់ និង ទ.១១០២ខ ចំនួន ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតខូច (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ត្រាសម្ងាត់
- ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន)

៦. **ការវេចខ្ចប់ស្បោង «ខ₂» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត**

- កញ្ចប់សុវត្ថិភាព «ក₂» នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់។




**៧. ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់**

ប្រធាន គ.ក.រ ត្រូវចាត់ចែងរៀបចំ៖

- បត់ហិបឆ្នោតតាមលំនាំដើម ច្រកចូលក្នុងស្រោមកេសក្រដាស
- បត់បន្ទប់សម្ងាត់តាមផ្នត់ដើម ច្រកចូលការុងនីឡុង ឬកេសក្រដាស
- ដាក់ក្នុងកេសស័ង្កសីនូវស្លាកការិយាល័យ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត
- វេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដាក់ដោយឡែក (មិនដាក់ក្នុងកេសស័ង្កសីទេ)
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ច្បាប់ ដែលមានលម្អិតមុខសម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងនោះ សម្រាប់ប្រើក្នុងពេលប្រគល់ ទទួលនៅ លគធ.ខប។

**៨. ការបញ្ជូនស្បោង «ខ» នៃប្រភេទក្រុមប្រឹក្សានីមួយៗ និងស្បោងដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គធ.ខប**

ការបញ្ជូនស្បោង «ខ» នៃប្រភេទក្រុមប្រឹក្សានីមួយៗ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ លគធ.ខប ត្រូវធ្វើនៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត។ ប្រធាន គ.ក.រ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលរួមអមដំណើរការបញ្ជូនសម្ភារ ឯកសារបោះឆ្នោតទាំងនោះ ដោយជម្រាបពីពេលវេលាចេញដំណើរ និងគោលដៅផង។

សមាសភាពក្នុងការបញ្ជូន រួមមាន៖

- ប្រធាន គ.ក.រ អនុប្រធាន គ.ក.រ និងសមាជិក គ.ក.រ មួយចំនួន តាមការចាំបាច់
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ (ប្រសិនបើចូលរួម)
- កម្លាំងសន្តិសុខបោះឆ្នោត ២នាក់ (ប្រសិនបើចាំបាច់)។

## VIII. ការរាប់សន្លឹកឆ្នោតនៅ លគធ.ខប ឬនៅទីកន្លែងមានសុវត្ថិភាពដែល គ.ជ.ប បានកំណត់

ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើង ក្រោយពីបានបិទការបោះឆ្នោត និងក្រោយពីបានធ្វើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ទាំងពីរប្រភេទរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅរក្សាបានល្អ គ.ជ.ប ត្រូវណែនាំដល់ គធ.ខប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅ លគធ.ខប ឬនៅទីតាំងសុវត្ថិភាពណាមួយ។

*ប្រធាន គ.ក.ប ត្រូវ*

- *រាយការណ៍ជាបន្ទាន់ជូន គធ.ខប ដើម្បីបន្តរាយការណ៍ជូន គ.ជ.ប ស្តីពីករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះបាន*
- *ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំមានលេខរួចឱ្យបានហ្មត់ចត់ត្រៀមសម្រាប់ការបញ្ជូនទៅ លគធ.ខប*
- *រៀបចំស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងវេចខ្ចប់រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ទៅក្នុងកញ្ចប់សុវត្ថិភាព «ក$_{ស}$» និងកញ្ចប់សុវត្ថិភាព «ក$_{ខ}$» ប៉ុន្តែមិនចាំបាច់បិទភ្ជិតដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មកត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ*

*ប្រធាន គ.ក.ប ត្រូវ(ត)*

- *វេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ព្រមទាំងស្រោមសំបុត្រដាក់ត្រា គ.ក.ប (បន្ទាប់ពីបោះត្រាលើ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួច) ទៅក្នុងស្បោង «ខ» ហើយចងភ្ជិត និងចាក់សោឃ្លុំ*
- *ប្រមូល និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ដោយឡែក*
- *បំពេញ ទ.១១០៧ ចំនួន ២ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលនៅ លគធ.ខប*
- *ផ្តល់ព័ត៌មានអំពីករណីនេះដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងអញ្ជើញគាត់ឱ្យចូលរួមអមដំណើរផង*
- *បញ្ជូនទៅ លគធ.ខប ជាបន្ទាន់នៅថ្ងៃបោះឆ្នោតនូវហិបឆ្នោតទាំង ២ ដែលមានសន្លឹកឆ្នោតនៅខាងក្នុង ស្បោង «ខ» ទាំង ២ និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់។*

**ចំណាំ៖** សមាសភាពក្នុងការបញ្ជូនរួមមាន៖

- ប្រធាន គ.ក.ប អនុប្រធាន គ.ក.ប និងសមាជិក គ.ក.ប មួយចំនួន
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ (ប្រសិនបើគាត់ចូលរួម)
- កម្លាំងសន្តិសុខបោះឆ្នោតចំនួន ២នាក់។

| | |
|---|---|
| *គ.ក.រ ឬមន្ត្រីរាប់សន្លឹកឆ្នោតត្រូវ* | *- មកកាន់ លគធ.ឃប ឬទីកន្លែងមានសុវត្ថិភាពតាមការកំណត់របស់ គធ.ឃប*<br>*- អនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដែលមាននីតិវិធីដូចគ្នានឹងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោតដែរ ដោយឡែកតែត្រង់ចំណុចមួយចំនួនដូចខាងក្រោម៖*<br>▪ *ត្រូវទទួលខុសត្រូវចាត់ចែងយក ទ.១១០២ស និង ទ.១១០២ខ ចំនួន ១ច្បាប់ៗ ទៅបិទផ្សាយជាលទ្ធផលបណ្ដោះអាសន្ននៅមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ*<br>▪ *បិទផ្សាយ ទ.១១០២ស និង ទ.១១០២ខ ១ច្បាប់ៗ នៅមុខ លគធ.ឃប និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន*<br>▪ *វេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតតាមនីតិវិធី ហើយចងមាត់ស្បោង «ខ» ទាំង ២ប្រភេទ រួចត្រូវប្រគល់ជូន គធ.ឃប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោត ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍*<br>▪ *ប្រគល់ហិបឆ្នោតទទេជូន គធ.ឃប*<br>▪ *បំពេញ (ទ.១១០៧) និងប្រើប្រាស់ទៅតាមការណែនាំរបស់ គ.ជ.ប។* |

**ចំណាំ៖** នៅពេលប្រគល់ ទទួល ប្រធាន គធ.ឃប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួល សម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ច្បាប់នោះ ។

## ផ្នែកទី២
## គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប)

### I. គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

១. សមាសភាព និងរចនាសម្ព័ន្ធរបស់ គធ.ខប

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតឡើងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។

រចនាសម្ព័ន្ធរបស់ គធ.ខប




១.លគធ.ខប

- -ប្រធាន ១រូប
- -អនុប្រធាន ១រូប
- -សមាជិក ៣រូប

២.អនុគណៈកម្មការបច្ចេកទេស

-ប្រធាន លគធ.ខប ជាប្រធាន
-អនុប្រធាន លគធ.ខប ជាអនុប្រធាន
-សមាជិកគធ.ខបជាប្រធានផ្នែកនីមួយៗ
-សមាជិកលគធ.ខបជាអនុប្រធានផ្នែកនីមួយៗ
-អនុប្រធានផ្នែក លគធ.ខប ជាអនុប្រធាន នៃផ្នែកនីមួយៗ
-អនុប្រធានផ្នែកជំនាញនៃ គធ.ខប ទទួលបន្ទុកការងារភស្តុភារជាអនុប្រធានផ្នែក។

៣.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល

-ប្រធាន គធ.ខប ជាប្រធាន
-អនុប្រធាន គធ.ខប ជាអនុប្រធាន
-ប្រធាន និងអនុប្រធាន លគធ.ខប ជាសមាជិក

**ភារកិច្ចប្រធាន លគធ.ខប**

ទទួលខុសត្រូវគ្រប់គ្រងការងារហិរញ្ញវត្ថុ អគារ រថយន្ត និងសម្ភារបរិក្ខារទាំងអស់របស់ គធ.ខប និងចុះហត្ថលេខាលើលិខិតស្នាមពាក់ព័ន្ធនឹងការងារទាំងអស់នេះ ហើយស្នើសុំយោបល់សម្រេចពីប្រធាន គធ.ខប។

**ភារកិច្ចប្រធានអនុគណៈកម្មការបច្ចេកទេស**

-ធានាថា សមាជិក សមាជិកានៃអនុគណៈកម្មការបច្ចេកទេសទាំងអស់ត្រូវបំពេញភារកិច្ចតាមផ្នែកនីមួយៗដែលខ្លួនទទួលខុសត្រូវ
-ចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ គធ.ខប
-ចុះហត្ថលេខាគ្រប់ឯកសារផ្លូវការរបស់អនុគណៈកម្មការបច្ចេកទេស។

## ២. សមាសភាព គធ.ខប និង លគធ.ខប

គធ.ខប ត្រូវមានសមាសភាពចំនួន ៧ រូប ដែលមានប្រធាន ១ រូប អនុប្រធាន ១ រូប និងសមាជិក ៥ រូប មានលេខាធិការដ្ឋានមួយជាជំនួយការ និងមានអនុគណៈកម្មការបច្ចេកទេស ដែលមានផ្នែកជំនាញចំនួន ៥ ដែលត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួនដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

### ក. អនុគណៈកម្មការរបស់ គធ.ខប

គធ.ខប មានអនុគណៈកម្មការដូចខាងក្រោម៖

- អនុគណៈកម្មការបច្ចេកទេស
- អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល
- អនុគណៈកម្មការផ្សេងៗទៀតតាមការចាំបាច់

អនុគណៈកម្មការខាងលើនេះត្រូវសម្រេច និងតែងតាំងដោយ គធ.ខប។

### ខ.អនុគណៈកម្មការបច្ចេកទេស

អនុគណៈកម្មការបច្ចេកទេស មានសមាសភាពដូចខាងក្រោម៖

- ប្រធាន លគធ.ខប ជាប្រធាន
- អនុប្រធាន លគធ.ខប ជាអនុប្រធាន
- សមាជិក គធ.ខប ជាប្រធានផ្នែកនីមួយៗ
- សមាជិក លគធ.ខប ដែលជាប្រធានផ្នែកនីមួយៗ នៃ លគធ.ខប ជាអនុប្រធានផ្នែក
- អនុប្រធានផ្នែកនីមួយៗ នៃ លគធ.ខប ជាអនុប្រធានផ្នែក
- អនុប្រធានផ្នែកជំនាញនៃ គធ.ខប ទទួលបន្ទុកការងារភស្តុភារ ជាអនុប្រធានផ្នែក

អនុគណៈកម្មការបច្ចេកទេសមានផ្នែកជំនាញទាំង ៥ (ប្រាំ) របស់ គធ.ខប សម្រាប់អនុវត្តការងារបច្ចេកទេសទាក់ទងនឹងការបោះឆ្នោត។

### គ.អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួល មានសមាសភាព៖

| | |
|---|---|
| - ប្រធាន គធ.ខប | ជាប្រធាន |
| - អនុប្រធាន គធ.ខប | ជាអនុប្រធាន |
| - ប្រធាន អនុប្រធាន លគធ.ខប | ជាសមាជិក |

អនុគណៈកម្មការត្រួតពិនិត្យ សម្របសម្រួលមានផ្នែកពាក់ព័ន្ធទាំង ៥ (ប្រាំ) ជាជំនួយការ។

## ៣. ភារកិច្ច និងការទទួលខុសត្រូវរបស់ គធ.ខប

គធ.ខប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួនតាមការប្រគល់សិទ្ធិអំណាច និងត្រួតពិនិត្យនីត្យានុកូលភាពដោយ គ.ជ.ប។

គធ.ខប ត្រូវ៖

- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់
- អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភណ្ឌនៃសម្ភារបរិក្ខារសម្រាប់បម្រើការបោះឆ្នោត និងគោរពតាមប្រតិទិននៃការបោះឆ្នោត
- គោរព និងអនុវត្ត ច.ប.ក ច.ប.ត.រ ច.វ.ច.ប ប.ន.ក គោលការណ៍ណែនាំរបស់ គ.ជ.ប និងក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត
- ចាត់វិធានការពាក់ព័ន្ធទៅនឹងកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងដំណើរការបោះឆ្នោត

- តាមដាន ត្រួតពិនិត្យការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គ.ក.ប
- បែងចែក សម្ភារ បរិក្ខារសម្រាប់ការបោះឆ្នោតទៅ គ.ក.ប
- ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត
- លើកគម្រោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីការបោះឆ្នោតក្នុងក្របខណ្ឌរាជធានី ខេត្ត តាមការណែនាំរបស់ គ.ជ.ប
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការបោះឆ្នោត ដោយធ្វើការសហការ និងសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតក្នុងក្របខណ្ឌរាជធានី ខេត្ត ជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល
- ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- សម្របសម្រួល និងត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- ចាត់គ្រប់វិធានការ ដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អគារ ឬទីសាធារណៈដល់គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះទាំងអស់ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត
- ដំណើរការកម្មវិធីផ្សព្វផ្សាយព័ត៌មាន
- លើកសំណើសុំតែងតាំងសមាជិក គ.ក.ប ក្នុងរាជធានី ខេត្ត និងធ្វើតារាងប្រាក់កម្រៃសម្រាប់សមាជិក និងមន្ត្រីនៃ គធ.ខប និង គ.ក.ប តាមការណែនាំរបស់ គ.ជ.ប
- រៀបចំ ចាត់ចែងប្រមូលលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ កំណត់ចំនួនអាសនៈសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយ
- រៀបចំវេចខ្ចប់ និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត កំណត់ហេតុ ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សាក្នុងរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតពាក់ព័ន្ធជូនទៅ គ.ជ.ប
- ទទួលពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុង ច.ប.ក និង ប.ន.ក
- ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត
- សហការចាត់ចែងការងារសន្តិសុខបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួន
- រាយការណ៍ជូន គ.ជ.ប អំពីស្ថានភាពទូទៅក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការនានាធានាឱ្យការ បោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងមានតម្លាភាព
- ទទួលពាក្យសុំ និងពិនិត្យសម្រេច ព្រមទាំងចេញបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ
- ផ្តល់បណ្ណសម្គាល់ជូនអ្នកសង្កេតការណ៍ជាតិ
- វាយតម្លៃអំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គ.ក.ប
- អនុវត្តការងារដទៃទៀតដែល ច.ប.ក និង ប.ន.ក អនុញ្ញាត ឬតម្រូវឱ្យអនុវត្ត
- អនុវត្តការងារ ឬសិទ្ធិអំណាចដទៃទៀតដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប។

**ចំណាំ៖** ភារកិច្ចរបស់ប្រធាន អនុប្រធាន សមាជិក គធ.ខប និងភារកិច្ចរបស់ប្រធាន អនុប្រធាន និងសមាជិក លគធ.ខប មានចែងលម្អិតនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## II. ការទទួលសម្ភារៈ ឯកសារបោះឆ្នោតពី គ.ជ.ប

១. សម្ភារៈ ឯកសារបោះឆ្នោតសម្រាប់ គធ.ខប

- បណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង)
- បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយចំនួន ១០សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង)
- បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិចំនួន ២សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុង រាជធានី ខេត្ត (ត្រូវបញ្ជូនមុន)
- បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ ចំនួន ៣ច្បាប់ (ត្រូវបញ្ជូនមុន)
- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ ចំនួន ២ច្បាប់ (ត្រូវបញ្ជូនមុន)
- កញ្ចប់សន្លឹកឆ្នោតបម្រុងចំនួន ១កញ្ចប់
- ទ.១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុងសមាសភាព គ.ក.ប ចំនួន ១២សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុន)
- ទ.១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កម្រៃរបស់សមាសភាព គ.ក.ប ចំនួន ៣ច្បាប់ (ត្រូវបញ្ជូនមុន)
- ទ.១១០៦ ចំនួន ៦ច្បាប់ សម្រាប់កត់ត្រា ការត្រួតពិនិត្យ ការបែងចែក និងបញ្ជូនសន្លឹកឆ្នោត
- ទ.១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារបោះឆ្នោត ចំនួន ១២ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត
- ទ.១១១០ខ ចំនួន ៥ច្បាប់ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត
- ទ.១១១១ខ សម្រាប់បំពេញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ចំនួន ១០ច្បាប់
- ទ.១១១៣ សម្រាប់បំពេញកំណត់ហេតុវាយតម្លៃសមាសភាព គ.ក.ប ចំនួន ១២ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត
- ទ.១១១៤ ចំនួន ១០ច្បាប់ សម្រាប់បំពេញលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ
- ទ.១១១៦គព ចំនួន ១០ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ផ្ទៀងផ្ទាត់ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប
- ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ចំនួន ៣ក្បាល ក្នុងមួយក្បាលមាន ២០ច្បាប់
- ទ.១២០៣ សម្រាប់បំពេញសម្រង់សេចក្ដីសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ចំនួន ៣ក្បាល ក្នុងមួយក្បាលមាន ២០ច្បាប់
- ស្រោមសំបុត្រធំ ២ ស្រោមសំបុត្រមធ្យម ៧ និងបន្ថែមស្រោមសំបុត្រមធ្យមចំនួនសមាមាត្រនឹងស្បោង «យ» ដែលត្រូវប្រើនៅ គធ.ខប
- ម៉ាស៊ីនគិតលេខ ១គ្រឿង
- ប៊ិកហ្វឺតធំលុបមិនជ្រះចំនួន ២ដើម
- ប៊ិកហ្វឺតធំ ពណ៌ខៀវ ចំនួន ១ដើម

- កញ្ចប់ «យ ពិសេស» គិតចំនួនសមាមាត្រស្បោង «ខ»
- ស្បោង «យ» ចំនួនគិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត
- សោឃ្លុំជ័រមានលេខ សម្រាប់ចាក់ឃ្លុំស្បោង «យ» ចំនួនស្មើនឹងស្បោង «យ»
- បន្ទប់សម្ងាត់បម្រុង (បែងចែកតាម គធ.ខប)
- ហិបឆ្នោតបម្រុង (បែងចែកតាម គធ.ខប)។

២. **សម្ភារ ឯកសារបោះឆ្នោតដែល គធ.ខប ត្រូវបញ្ជូនបន្តទៅ គ.ក.ប**

- ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតផ្សេងៗដែល គធ.ខប ត្រូវប្រគល់ជូន គ.ក.ប នីមួយៗ មិនត្រូវឱ្យលើសពី ៣៦ម៉ោង មុនថ្ងៃបោះឆ្នោត
- គ្រឿងបរិក្ខារ និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះមានរាយមុខ ដូចមានចែងក្នុងផ្នែកការិយាល័យបោះឆ្នោតនៃសៀវភៅណែនាំនេះ។

## III. ការប្រមូល និងការបញ្ជូនទិន្នន័យលទ្ធផលបឋមនៃការបោះឆ្នោត ដើម្បីបញ្ជូនទៅ គ.ជ.ប

នៅរសៀលនៃថ្ងៃបោះឆ្នោត គធ.ខប ត្រូវរង់ចាំទទួលស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោតនិងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ពីគ្រប់ការិយាល័យបោះឆ្នោតដែលសមាជិកទី២ នៃ គ.ក.រ បានប្រគល់ជូន ដើម្បីស្ដែន និងបញ្ចូលទិន្នន័យជាលទ្ធផលបឋមនៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ និងចាត់ចែងបញ្ជូនលទ្ធផលនេះតាមកម្មវិធីកំណត់ដោយ គ.ជ.ប។ បន្ទាប់មក គធ.ខប ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ជាលទ្ធផលបឋមនៃការបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌជាមុន រួចរាជធានី ខេត្តតាមក្រោយ ដោយត្រូវចាត់ចែងបញ្ជូនលទ្ធផលនេះដូចខាងក្រោម៖

*ប្រធាន លគធ.ខប ត្រូវ៖*

- *ត្រូវពិនិត្យ ផ្ទៀងផ្ទាត់អំពីភាពពេញលេញនៃការបំពេញទិន្នន័យនានាក្នុង តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ទាំងនោះរួចចារបញ្ជាក់ពីការបានទទួលនៅលើផ្នែកខាងលើនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ទាំងពីរប្រភេទនោះចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួល រួចចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប*
- *ចាត់ឱ្យមន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសធ្វើលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយស្ដែនកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ*
- *បញ្ចូលទិន្នន័យ និងតួលេខលទ្ធផលពី កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត រួចបញ្ជូនមក គ.ជ.ប តាមអ៊ីនធឺណិត ដើម្បីផ្សាយជាព័ត៌មានអំពីលទ្ធផលបឋមនៃការបោះឆ្នោត*
- *រក្សាទុកស្រោមសំបុត្រដាក់ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) សម្រាប់ដំណើរការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ*

ចំណាំ៖

បន្ទាប់ពីអនុវត្តកិច្ចការលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រួច មន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវធ្វើលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត តាមលំនាំខាងលើនេះ។

## IV. ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅ គធ.ខប

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ)នៃ ច.ប.ក

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ)នៃ ច.ប.ក ដែលកើតឡើងនៅ១ថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលអាចនាំឱ្យមានការផ្តន្ទាទោសចំពោះជនប្រព្រឹត្តអំពើល្មើស ត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

### ២. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់នឹងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌ អាចដាក់ពាក្យបណ្តឹងទៅ គធ.ខប ក្នុងរយៈពេល ២ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬ/និងក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ពាក្យបណ្តឹងប្រភេទនេះអាចមានកម្មវត្ថុចំនួន ៣ ផ្សេងគ្នាគឺ៖

- ការស្នើសុំកែតម្រូវតួលេខនៃលទ្ធផលនៃការបោះឆ្នោត
- ការស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ
- ការស្នើសុំឱ្យមានការបោះឆ្នោតសាជាថ្មី។

#### ក. ការដាក់ពាក្យបណ្តឹង

*អ្នកប្តឹង* →

- *បំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ច្បាប់*
- *ចុះហត្ថលេខា ឬផ្តិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ទាំង ៣ច្បាប់*
- *ត្រូវប្តឹងក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬក្នុងរយៈពេលយ៉ាងយូរ២ថ្ងៃបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។*

ព័ត៌មានចាំបាច់មួយចំនួនក្នុងពាក្យបណ្ដឹង រួមមាន៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង
- លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត
- ពេលវេលា និងទីកន្លែងកើតឡើងនូវភាពមិនប្រក្រតី
- ប្រភេទនៃភាពមិនប្រក្រតី ឬកំហុសឆ្គង ដែលជាកម្មវត្ថុនៃពាក្យបណ្ដឹង
- បើអាចធ្វើបានត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ក ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬប្រការនៃ ប.ន.ក ដែលត្រូវបានរំលោភ
- ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)
- សេចក្ដីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

**ខ. ការទទួលពាក្យបណ្ដឹង**

**ខ.១. ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់**

*ប្រធាន គធ.ខប ឬ សមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ* →

- *ចារបដិសេធលើ ទ.១២០២ គ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ*
- *ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប លើពាក្យបណ្ដឹង (ទ.១២០២) គ្រប់ច្បាប់*

*ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាងវិញ*
- *១ច្បាប់ ជូន គ.ជ.ប*
- *១ច្បាប់ រក្សាទុកជាឯកសារ*

- *ជម្រាបអ្នកប្ដឹង ឬតំណាងថា ពាក្យបណ្ដឹងរបស់គាត់ដាក់ក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។*

**ខ.២. ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់**

*ប្រធាន គធ.ខប ឬ សមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ* →

- *ណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង*
- *កត់ត្រាក្នុងកំណត់ហេតុសាកសួរ*
- *ចារបដិសេធលើពាក្យបណ្ដឹង (ទ.១២០២) គ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ក្នុងករណីដែលដល់រយៈពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមចំណុចខ្វះខាតនោះ*

*ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់*
- *១ច្បាប់ ផ្ញើជូនអ្នកប្ដឹង ឬតំណាងវិញ*
- *១ច្បាប់ ជូន គ.ជ.ប*
- *១ច្បាប់ រក្សាទុកជាឯកសារ*

ខ.៣. ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់

*សមាជិក គធ.ឃប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត*

- *ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ឃប លើគ្រប់ពាក្យបណ្ដឹង (ទ.១២០២)*

*ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាងវិញ*
- *១ច្បាប់ បិទផ្សាយជាសាធារណៈនៅ គធ.ឃប*
- *១ច្បាប់ សម្រាប់ប្រើក្នុងការដោះស្រាយពាក្យបណ្ដឹង*

- *ជម្រាបអ្នកប្ដឹង ឬតំណាងថា គធ.ឃប នឹងដោះស្រាយពាក្យបណ្ដឹងនេះក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ.១២០២)។*

គ. ការដោះស្រាយពាក្យបណ្ដឹងដែលគោរពរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់

គ.១. ករណីគ្មានភស្ដុតាងបញ្ជាក់ដែលអាចជឿថាមានកំហុសឆ្គងក្នុងប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ

*ប្រធាន គធ.ឃប*

- *សម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ទេ*
- *ចាត់មន្ត្រី លគធ.ឃប បំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ និងចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ឃប និងប្រធាន គធ.ឃប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ឃប*

*សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់*
- *១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង*
- *១ច្បាប់ ផ្ញើជូន គ.ជ.ប*
- *១ច្បាប់ រក្សាទុកជាឯកសារ*

- *ជម្រាបអ្នកប្ដឹង ឬតំណាងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ឃប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)*
- *ប្រគល់ជូនទៅអ្នកប្ដឹង ឬតំណាងនូវពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)*
- *ចាត់ចែងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតគ្រប់ការិយាល័យទាំងអស់ក្នុងរាជធានី ខេត្ត ជាធម្មតាតាមការកំណត់របស់ គ.ជ.ប។*

គ.២. ករណីមានភស្ដុតាងបញ្ជាក់ដែលអាចជឿថា មានកំហុសឆ្គងក្នុងប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ

នៅចំពោះមុខអ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត និងអ្នកសង្កេតការណ៍ ប្រធាន គធ.ឃប ត្រូវណែនាំក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន អនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖

- ចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនៃការបោះឆ្នោតនៃ គធ.ឃប បោះឆ្នោតដែលមានពាក្យបណ្ដឹង
- បើកកញ្ចប់សុវត្ថិភាព «កស» ឬកញ្ចប់សុវត្ថិភាព «កខ» ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុង ប.ន.ក ដោយយកចិត្តទុកដាក់នឹងបញ្ហាពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ និងបញ្ហាជារួម ដូចជា៖

- ពិនិត្យ ផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត
- ពិនិត្យ ផ្ទៀងផ្ទាត់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត
- ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត (បើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត នៅការិយាល័យណាមួយ ត្រូវដកយកបញ្ជីបោះឆ្នោតពីកញ្ចប់សុវត្ថិភាព «កស» នៃការិយាល័យក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ)
- ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនអ្នកដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយនៅក្នុងក្រដាសព័ត៌មាននៃអ្នកមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ (ទ.១១០៤) (ប្រសិនបើមាន)
- ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតជាមួយនឹងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតពាក់ព័ន្ធពេលទទួលមកវិញ
- រាប់ចំនួនសន្លឹកឆ្នោតខូចពេលបោះឆ្នោត (ប្រសិនបើមាន)
- រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ
- ពិនិត្យសន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)
- ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ
- ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ
- ពិនិត្យមើលកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតឬទេ និងមានការចុះហត្ថលេខាជាសាក្សីរបស់ភ្នាក់ងារគណបក្សនយោបាយឬទេ
- អនុវត្តការរាប់សន្លឹកឆ្នោតឡើងវិញនៃការិយាល័យបោះឆ្នោតមានពាក្យបណ្តឹងនោះតាម ប.ន.ក
- ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក» ចំនួន ២ច្បាប់ ដោយលើកយោបល់ យល់ព្រមទទួលយកលទ្ធផល ឬកែតម្រូវតួលេខ ឬព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យពាក់ព័ន្ធ (ចុះហត្ថលេខាដោយសមាសភាពក្រុមត្រួតពិនិត្យ)។

<u>សម្គាល់៖</u>

- ក្នុងករណីចាំបាច់ គធ.ខប អាចបើកការស៊ើបអង្កេតស្រាវជ្រាវលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដើម្បីមានមូលដ្ឋានក្នុងសម្រេចឱ្យបើក ឬមិនបើកកញ្ចប់សុវត្ថិភាព «ក»។
- អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលរួមសង្កេតមើលដំណើរការត្រួតពិនិត្យបញ្ជាក់ និងការរាប់សន្លឹកឆ្នោតនេះ។

**គ.២.១. ករណី គធ.ខប សម្រេចបដិសេធលើពាក្យបណ្តឹង**

ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញហើយ គធ.ខប នៅតែមិនឃើញមានកំហុសឆ្គង ឬភាពមិនប្រក្រតីណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» របស់ក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងកាលបរិច្ឆេទ ព្រមទាំងដាក់បង្ហាញនៅចំពោះមុខអ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន
- ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ បដិសេធលើពាក្យបណ្ដឹង ដោយបញ្ជាក់មូលហេតុនៃការបដិសេធ ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប

*សម្រង់សេចក្ដីសម្រេច (ទ.១២០៣)* ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ

- ជម្រាបអ្នកប្ដឹង ឬតំណាងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) នេះ
- ប្រគល់ជូនអ្នកប្ដឹង ឬតំណាងនូវពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

**គ.២.២. ករណី គធ.ខប សម្រេចយល់ព្រមលើពាក្យបណ្ដឹង**

ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញ គធ.ខប រកឃើញភស្ដុតាងបញ្ជាក់ថា មានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវៈ

- ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ យល់ព្រមលើពាក្យបណ្ដឹង ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប

ទ.១២០៣ ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ។

- ជម្រាបអ្នកប្ដឹង ឬតំណាងថា គធ.ខប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត ឬព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ ក្នុងករណី គធ.ខប សម្រេចព្យួរលទ្ធផល ត្រូវៈ
  - ធ្វើរបាយការណ៍លើកយោបល់អំពីករណីនេះជូន គ.ជ.ប
  - ប្រកាសថា សេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរជាបណ្ដោះអាសន្ននៃលទ្ធផល ស្ថិតក្រោមការត្រួតពិនិត្យសម្រេចឡើងវិញដោយ គ.ជ.ប
  - ធ្វើការវេចខ្ចប់ឯកសារពាក់ព័ន្ធដោយឡែកផ្ញើជូន គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២៤ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្ដីសម្រេចព្យួរលទ្ធផល។

## V. ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅ លគធ.ខប

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យ សម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ។ ការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវទទួលបន្ទុកដោយអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប ក្រោមការត្រួតពិនិត្យនីត្យានុកូលភាពពី គធ.ខប ។

### ១. ទីតាំងនៃមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត

មជ្ឈមណ្ឌលនេះ ត្រូវមានទីតាំងនៅ លគធ.ខប ហើយត្រូវរៀបចំឱ្យមានកន្លែងបម្រុងដូចខាងក្រោម៖

- កន្លែងសម្រាប់ទទួល និងរក្សាទុកស្បោង «ខ» និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត
- បន្ទប់ធំទូលាយមួយដែលមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត
- បន្ទប់តូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រ ដែលមានភ្ជាប់អ៊ីនធឺណិត និងកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតដែលរៀបចំដោយ គ.ជ.ប។

### ២. វិធានការសន្តិសុខ សុវត្ថិភាពនៅមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប

គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលរបស់ គធ.ខប និងត្រូវរៀបចំឱ្យមានបរិវេណសន្តិសុខមួយ ដោយបរិវេណខាងក្រៅត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់កម្លាំងការពារ និងនៅបរិវេណខាងក្នុងត្រូវរៀបចំចាត់ចែងកម្លាំងសន្តិសុខផ្ទាល់របស់ លគធ.ខប ដើម្បីការពារ។

ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលនៃ គធ.ខប ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គធ.ខប ឬ គ.ជ.ប លើកលែងតែ៖

- ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប ដែលបានទទួលការចាត់តាំង
- តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្ដឹង ឬតំណាង
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន គធ.ខប ឬតំណាងមានសំណូមពរ
- មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពើល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ.ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

សកម្មភាពដែលបានត្រូវហាមឃាត់នៅមជ្ឈមណ្ឌលនៃ គធ.ខប រួមមាន៖

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយណាម្នាក់
- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីនៃក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៣. **សមាសភាពក្រុមត្រួតពិនិត្យ និងក្រុមកំណត់បែងចែកអាសនៈ**

គធ.ខប ត្រូវចាត់តាំងក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប មួយក្រុម ឬច្រើនក្រុម ឱ្យទទួលបន្ទុកតាមប្រភេទក្រុមប្រឹក្សានីមួយៗ និងចាត់តាំងក្រុមមួយផ្សេងទៀតឱ្យទទួលបន្ទុកកំណត់បែងចែកអាសនៈ និងស្រង់បេក្ខជនជាប់ឆ្នោត។

សមាសភាពក្រុមត្រួតពិនិត្យ និងក្រុមកំណត់បែងចែកអាសនៈនៃ គធ.ខប ត្រូវជ្រើសរើសឡើងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងមន្ត្រី លគធ.ខប ដូចខាងក្រោម៖

- សមាសភាពក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃ គធ.ខប នីមួយៗមាន ៤រូប ដឹកនាំដោយប្រធាន ១រូប ជាសមាសភាពអនុគណៈកម្មការបច្ចេកទេស អនុប្រធាន ១រូប លេខាធិការ ១រូប និងជំនួយការ ១រូប ដែលជាមន្ត្រី លគធ.ខប
- សមាសភាពក្រុមកំណត់បែងចែកអាសនៈ រួមមានសមាជិក គធ.ខប ដែលជាប្រធានផ្នែករដ្ឋបាលជាប្រធានក្រុម និងមានសមាជិក លគធ.ខប និងមន្ត្រី លគធ.ខប មួយចំនួនទៀតតាមការចាំបាច់ ជាសមាជិក និងលេខាធិការ។ ក្នុងចំណោមសមាជិកក្រុម ត្រូវតែមានអ្នកចេះប្រើប្រាស់កុំព្យូទ័រ និងអ៊ីមែល។

៤. **ការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ លគធ.ខប**

នៅពេលប្រគល់ ទទួលស្បោង «ខ» នៃប្រភេទក្រុមប្រឹក្សានីមួយៗ និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ មន្ត្រី លគធ.ខប ត្រូវពិនិត្យផ្ទៀងផ្ទាត់ស្បោង «ខ» នៃក្រុមប្រឹក្សាទាំងពីរប្រភេទ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលប្រធាន គ.ក.រ បានប្រគល់ជូន ដោយត្រួតពិនិត្យស្បោង «ខ» នៃក្រុមប្រឹក្សាប្រភេទណាមួយចប់សព្វគ្រប់ហើយ ទើបយកស្បោង «ខ» នៃក្រុមប្រឹក្សាប្រភេទមួយទៀតមកត្រួតពិនិត្យបន្តទៀត ដើម្បីបង្ការការច្រឡំគ្នា។

ក. **ពេលត្រួតពិនិត្យ**

- មិនអនុញ្ញាតឱ្យរុះរើកញ្ចប់សុវត្ថិភាព «ក» ឡើយ
- បើកស្បោង «ខ» ឬ/និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់
- ដកយកលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពីស្បោង «ខស» ឬស្បោង «ខខ» ១ច្បាប់ ពីក្នុងហោប៉ៅក្រៅស្បោង «ខស» ឬស្បោង «ខខ» ១ច្បាប់ និងពីអ្នកប្រគល់ ទទួល ១ច្បាប់
- ពិនិត្យផ្ទៀងផ្ទាត់រាល់សម្ភារ ឯកសារបោះឆ្នោតក្នុងស្បោង «ខស» ឬស្បោង «ខខ» ឬ/និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)
- ចុះហត្ថលេខាលើ ទ.១១០៧ ទាំង ៣ច្បាប់ នៃស្បោង «ខស» ឬស្បោង «ខខ» និងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ច្បាប់នៃសម្ភារ ឯកសារបោះឆ្នោតនៅសល់ ។

| | |
|---|---|
| ទ.១១០៧<br>ចំនួន ៣ច្បាប់ | - ១ច្បាប់ ដាក់ក្នុងហោប៉ៅខាងក្រៅស្បោង «ខស» ឬស្បោង «ខខ»<br>- ១ច្បាប់ ជូនប្រធាន គ.ក.រ វិញ<br>- ១ច្បាប់ រក្សាទុកជាឯកសាររបស់ គធ.ខប |
| ទ.១១០៧<br>ចំនួន ២ច្បាប់ | - ១ច្បាប់ ជូនប្រធាន គ.ក.រ វិញ<br>- ១ច្បាប់ រក្សាទុកជាឯកសាររបស់ គធ.ខប។ |

ខ. ក្រោយពេលត្រួតពិនិត្យ

- កត់ចំណាំរាល់ស្បោង «ខស» ឬស្បោង «ខខ» និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ រក្សាទុកនៅកន្លែងមានសុវត្ថិភាព និងដាក់តាមលំដាប់លំដោយនៃលេខកូដការិយាល័យបោះឆ្នោតនីមួយៗ
- ចាត់ចែងឱ្យមានកម្លាំងសន្តិសុខបោះឆ្នោតដើម្បីយាមការពារបរិវេណ លគធ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង «ខ» ទាំង ពីរប្រភេទ និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់
- ចាត់ចែងឱ្យមានភ្លើងបំភ្លឺនៅ លគធ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង «ខ» នៃក្រុមប្រឹក្សាទាំង ពីរប្រភេទ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់។

## VI. កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីទទួលបានស្បោង «ខ» នៃការិយាល័យបោះឆ្នោតនីមួយៗ គធ.ខប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗពីគ្រប់ការិយាល័យបោះឆ្នោត ដែលក្នុងនោះរួមទាំងការិយាល័យដែលត្រូវរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង និងរួមទាំងការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ (ទោះបី គធ.ខប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «ក» ក៏ដោយ ឬ/និងបានសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក៏ដោយ) ឱ្យរួចរាល់ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ដោយត្រូវចាប់ផ្តើមពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមុន។ ក្នុងដំណើរការនេះ ប្រធាន គធ.ខប ត្រូវ ៖

- ណែនាំក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផល ឱ្យអនុវត្តតាម ប.ន.ក និងការណែនាំរបស់ គ.ជ.ប
- ជូនដំណឹងជាសាធារណៈដល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងភាគីពាក់ព័ន្ធ អំពីដំណើរការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលក្នុងរាជធានី ខេត្តរបស់ខ្លួន។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវរៀបចំឱ្យស្ថិតនៅទីជិត ល្មមអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការអនុវត្ត
- ផ្តល់ទម្រង់បែបបទ និងសម្ភារ ឯកសារបោះឆ្នោតផ្សេងៗដល់ក្រុមត្រួតពិនិត្យ សម្រាប់ប្រើប្រាស់ក្នុងដំណើរការនេះ។

<u>សម្គាល់</u>៖ គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អាចថតយករូបភាពនៃដំណើរការអនុវត្តការងាររបស់ក្រុមត្រួតពិនិត្យ ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

### ១. កិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ក. សម្ភារ ឯកសារបោះឆ្នោតសម្រាប់ប្រើប្រាស់

ប្រធានក្រុមត្រួតពិនិត្យត្រូវ៖

*ទុកលើតុខាងមុខខ្លួន* ⇨

- *ពាក្យបណ្តឹង (ទ.១២០២) សម្រាប់ជូនតំណាងគណបក្សនយោបាយ (ប្រសិនបើគាត់ស្នើសុំ)*
- *ម៉ាស៊ីនគិតលេខ ១គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការ*
- *សម្ភារ ឯកសារបោះឆ្នោតចាំបាច់ផ្សេងទៀត។*

**ខ. ការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្នក្នុងករណីការិយាល័យណាគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬមានពាក្យបណ្ដឹង ប៉ុន្តែមិនបើកកញ្ចប់សុវត្ថិភាព "ក"**

*ក្រុមត្រួតពិនិត្យ* ⇒

- *មិនចាំបាច់បើកកញ្ចប់សុវត្ថិភាព «កស» ណាមួយឡើយ*
- *គ្រាន់តែពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨ស)នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធតែប៉ុណ្ណោះ។*

*ប្រធានក្រុមត្រូវ* ⇒

- *ចាត់ចែងឱ្យលេខាធិការរៀបចំដំឡើងកុំព្យូទ័រ និងភ្ជាប់អ៊ីនធឺណិតដើម្បីទាញយកទិន្នន័យ និងរូបភាពកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ពីសេវូបករណ៍ (Server) គ.ជ.ប ដែលបានបញ្ចូល និងបញ្ជូនទៅ គ.ជ.ប សម្រាប់ផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត*
- *បង្គាប់ឱ្យលេខាធិការបញ្ជាប់ចូល (Login) ក្នុងកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវូបករណ៍ (Server) គ.ជ.ប សម្រាប់បង្ហាញលទ្ធផលនៃការបោះឆ្នោតនីមួយៗលើឧបទស្សន៍កុំព្យូទ័រ (Monitor) ជូនភាគីពាក់ព័ន្ធដែលមានវត្តមានបានឃើញទាំងអស់គ្នា*
- *បង្គាប់ជំនួយការឱ្យនាំយកស្រោមសំបុត្រដាក់ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) នៃការិយាល័យបោះឆ្នោតម្ដងមួយៗពីកន្លែងរក្សាទុក មកដាក់នៅលើតុចំពីមុខគាត់*
- *បង្គាប់ឱ្យលេខាធិការបោះពុម្ពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ពីប្រព័ន្ធកុំព្យូទ័រ ១ច្បាប់ រួចបោះត្រា គធ.ខប រួចប្រគល់ជូនជំនួយការយកទៅបិទផ្សាយនៅខាងមុខ លគធ.ខប។*

**+ ពេលត្រួតពិនិត្យផ្ទៀងផ្ទាត់**

*ប្រធានក្រុមត្រូវ ចាត់ចែង* ⇒

- *ផ្ទៀងផ្ទាត់ និងបូកសរុបតួលេខក្នុង កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងតារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨ស)នៃការិយាល័យបោះឆ្នោតនីមួយៗ*
- *ប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធក្នុង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ដើម្បីឱ្យដឹងថា ពិតជាត្រឹមត្រូវមែន ឬ គ.ក.រ មានកំហុសក្នុងការគណនាតួលេខណាមួយ*
- *ករណី គ.ក.រ មានកំហុសក្នុងការគណនាលេខ ត្រូវបង្ហាញកំហុស និងកែតម្រូវកំហុសនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដោយបញ្ជាក់ពីហេតុផលនៃការកែតម្រូវ*
- *ធានាថា ទ.១១១៦តពស ចំនួន ២ច្បាប់បានបោះពុម្ពចេញ ត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយគ្នា និងត្រូវបញ្ជាក់ឈ្មោះនិងលេខកូដក្រុងស្រុកខណ្ឌពាក់ព័ន្ធផង*
- *ធានាថា ទ.១១១៦តពស ខាងលើទាំង ២ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម៖*
    - *តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ*

| | |
|---|---|
| | ➢ គ.ក.រ មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផល នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៃ គធ.ខប។<br>- ក្នុងករណីក្រុមត្រួតពិនិត្យ បានរកឃើញកំហុសក្នុងការគណនាតួលេខលទ្ធផលនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ប្រធានក្រុមត្រូវបង្ហាញកំហុស និងការកែតម្រូវ ព្រមទាំងហេតុផលនៃការកែតម្រូវនោះនៅចំពោះតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។ ក្នុងការកែតម្រូវកំហុសនោះត្រូវ៖<br>➢ គូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង<br>➢ ចាត់ឱ្យលេខាធិការកត់ត្រាទៅក្នុងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១១ស) ក្នុងប្រព័ន្ធកុំព្យូទ័រផង<br>- ចាត់ឱ្យលេខាធិការស្កែនទម្រង់បែបបទទាំងឡាយណាដែលមានការកែតម្រូវ<br>- ណែនាំលេខាធិការឱ្យកែតម្រូវទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ដែលបានទាញយកពីស៊េវបករណ៍ (Server) គ.ជ.ប ក្នុងករណីមានការកែតម្រូវទិន្នន័យនៃទម្រង់បែបបទណាមួយ |
| ប្រធានក្រុម ត្រូវ ចាត់ចែង (ត) | - ណែនាំលេខាធិការឱ្យផ្ទេរទិន្នន័យពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) បញ្ចូលទៅលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១៤ស)<br>- ណែនាំលេខាធិការឱ្យបោះពុម្ពកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១១ស) ចំនួន ៣ច្បាប់ ដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២ស)<br>- ធានាថាតារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១៦គពស) (ផ្ទៀងផ្ទាត់ដោយ គធ.ខប) និងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១១ស) ខាងលើនេះ ត្រូវបានដាក់ភ្ជាប់ជាមួយកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) នៃការិយាល័យបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ ត្រៀមដាក់ជូន គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប។ |

**+ ក្រោយពេលត្រួតពិនិត្យផ្ទៀងផ្ទាត់**

ប្រធានក្រុម ត្រូវ

*- ធានាថាកំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) នៃការិយាល័យបោះឆ្នោតដែលបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យបញ្ជាក់ខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដែលមានកាខ្វង « កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គ.ជ.ប » ដើម្បីត្រៀមផ្ញើជូន គ.ជ.ប និងបោះពុម្ព មួយមុខ មួយច្បាប់ ទុកជាឯកសាររបស់ គធ.ខប។*

**គ. ការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ ហើយត្រូវបាន គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព «កស»**

ក្នុងករណីការិយាល័យបោះឆ្នោតណាមួយដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប ហើយពាក្យបណ្តឹងនោះតម្រូវឱ្យ គធ.ខប បើកកញ្ចប់សុវត្ថិភាព «កស» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធាន គធ.ខប ត្រូវណែនាំប្រធានក្រុម ត្រួតពិនិត្យ ដូចខាងក្រោម៖

ប្រធានក្រុម ត្រូវ

- *បង្គាប់ជំនួយការឱ្យយកស្បោង «ខស» នៃការិយាល័យបោះឆ្នោតមានពាក្យបណ្តឹងពាក់ព័ន្ធ មកដាក់នៅលើតុចំពីមុខគាត់*
- *ស្រាយមាត់ស្បោង «ខស» ដកយកកញ្ចប់សុវត្ថិភាព «កស» មកដាក់លើតុ*
- *បើកកញ្ចប់សុវត្ថិភាព «កស» រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែលមាននៅខាងក្នុង មកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់*
- *ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ផ្ញើជូន គ.ជ.ប ឱ្យទៅលេខាធិការសម្រាប់តាមដានពិនិត្យ និងប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត*
- *បើកស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធី។*

**+ នីតិវិធីនៃការបើកកញ្ចប់សុវត្ថិភាព «កស»**

ប្រធានក្រុម ត្រូវ

*ចាត់ចែងការត្រួតពិនិត្យបញ្ជាក់សរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជាធម្មតាដូចករណីការិយាល័យបោះឆ្នោតគ្មានពាក្យបណ្តឹង និងអនុវត្តបន្ថែមនីតិវិធីរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹង និងបញ្ហារួម ដូចខាងក្រោម ៖*
- *ពិនិត្យ ផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត*
- *ពិនិត្យ ផ្ទៀងផ្ទាត់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត*
- *ពិនិត្យនិងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត*

*ប្រធានក្រុម ត្រូវ*

- *ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយនៅក្នុងក្រដាសព័ត៌មានអ្នកអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១០៤) (ប្រសិនបើមាន)*
- *ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតពាក់ព័ន្ធដែលទទួលពីការិយាល័យនោះវិញ*
- *រាប់ចំនួនសន្លឹកឆ្នោតខូចពេលបោះឆ្នោត (ប្រសិនបើមាន)*
- *រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ*
- *ពិនិត្យសន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)*
- *ពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ*
- *ពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ*
- *ពិនិត្យមើលថាតើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត និងការចុះហត្ថលេខាជាសាក្សីពីភ្នាក់ងារគណបក្សនយោបាយឬទេ?*
- *អនុវត្តការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្ដឹងនោះ តាម ប.ន.ក និងការណែនាំពី គធ.ខប*
- *ធ្វើការប្រៀបធៀបលទ្ធផលដែលបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបានរាប់ឃើញជាមួយនឹងទិន្នន័យ និងតួលេខដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) ។*

**+ ការធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «កស»**

បន្ទាប់ពីបានអនុវត្តការបើកកញ្ចប់សុវត្ថិភាព «កស» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធានក្រុមត្រួតពិនិត្យត្រូវចាត់ចែងធ្វើរបាយការណ៍ចំនួន ២ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យ។ ក្នុងរបាយការណ៍នេះត្រូវតែមានការលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យ និងសម្រេច ៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ
- កែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ក្នុងករណីមានកំហុសក្នុងការគណនា ឬ
- ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

ប្រធានក្រុមត្រួតពិនិត្យ ត្រូវដាក់របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «កស» ជាមួយ ទ.១១១៦តពស និងសំណុំឯកសារពាក់ព័ន្ធជូន គធ.ខប ពិនិត្យ និងសម្រេចតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប។

<u>សម្គាល់</u>៖ គធ.ខប ត្រូវណែនាំប្រធានក្រុមត្រួតពិនិត្យ ឱ្យថតចម្លង កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប។

+ **ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតឡើងវិញ**

ប្រធានក្រុមត្រួតពិនិត្យ ត្រូវចាត់ចែងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រពាក់ព័ន្ធនានា រួចដាក់ក្នុងកញ្ចប់សុវត្ថិភាព «កស» ហើយដាក់កញ្ចប់សុវត្ថិភាព «កស» និងរាល់ស្រោមសំបុត្រទៅក្នុងស្បោង «ខស» តាមលំនាំដើម រួចនាំយកទៅរក្សាទុកនៅកន្លែងដើមវិញ។

**ឃ. ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹង**

គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹង បន្ទាប់ពីក្រុមត្រួតពិនិត្យបានបញ្ចប់ការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតមានពាក្យបណ្ដឹង ដោយផ្អែកលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «កស» ទ.១១១៦តពស និងសំណុំឯកសារ ដែលប្រធានក្រុមត្រួតពិនិត្យ បានដាក់ជូនតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។

+ **ករណី គធ.ខប បដិសេធពាក្យបណ្ដឹង ដោយយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត**

ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញហើយ គធ.ខប នៅតែមិនឃើញមានកំហុសឆ្គង ឬភាពមិនប្រក្រតីណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តពស) ទាំង ២ច្បាប់ និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «កស» រួចចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងកាលបរិច្ឆេទព្រមទាំងដាក់បង្ហាញចំពោះអ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន
- ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ បដិសេធលើពាក្យបណ្ដឹង ដោយបញ្ជាក់មូលហេតុនៃការបដិសេធ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប

| | |
|---|---|
| ទ.១២០៣<br>ចំនួន ៣ច្បាប់ | - ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង<br>- ១ច្បាប់ ផ្ញើជូន គ.ជ.ប<br>- ១ច្បាប់ រក្សាទុកជាឯកសារ |

- ជម្រាបអ្នកប្ដឹង ឬតំណាងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប
- ប្រគល់ជូនអ្នកប្ដឹង ឬតំណាង នូវពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

+ **ករណី គធ.ខប យល់ព្រមលើពាក្យបណ្ដឹង ដោយសម្រេចកែតម្រូវតួលេខ ឬព្យួរលទ្ធផលជាបណ្ដោះអាសន្ន**

ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញ គធ.ខប រកឃើញភស្តុតាងបញ្ជាក់ថាមានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវ៖

- ចារយល់ព្រម (ករណីកែតម្រូវតួលេខលទ្ធផល) ឬចារព្យួរលើលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១៦តពស) ទាំង ២ច្បាប់ និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «កស» រួចចុះហត្ថលេខា បោះត្រា គធ.ខប និងកាលបរិច្ឆេទ ឈ្មោះ ហើយដាក់បង្ហាញដល់អ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន
- ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ យល់ព្រមកែតម្រូវតួលេខលទ្ធផល ឬព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងយល់ព្រមលើពាក្យបណ្ដឹង ព្រមទាំងចុះហត្ថលេខា ឈ្មោះផង
- ចុះហត្ថលេខា កាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប លើសម្រង់សេចក្ដីសម្រេច (ទ.១២០៣)

សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់
- ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ

- ជម្រាបអ្នកប្ដឹង ឬតំណាងថា គធ.ខប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត ឬព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ ក្នុងករណី គធ.ខប សម្រេចព្យួរលទ្ធផល ត្រូវ៖
  - ធ្វើរបាយការណ៍លើកយោបល់អំពីករណីនេះជូន គ.ជ.ប
  - ប្រកាសថា សេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរលទ្ធផលបណ្ដោះអាសន្ន ស្ថិតក្រោមការត្រួតពិនិត្យសម្រេចឡើងវិញដោយ គ.ជ.ប
  - ធ្វើការវេចខ្ចប់ឯកសារពាក់ព័ន្ធដោយឡែកផ្ញើជូន គ.ជ.ប (មានចែងក្នុងចំណុច ២ នៃចំណុច VIII នៃសៀវភៅណែនាំនេះ) ក្នុងរយៈពេលយ៉ាងយូរ ២៤ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ព្យួរលទ្ធផល។

**២. កិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត**

**ក. សម្ភារ ឯកសារបោះឆ្នោតសម្រាប់ប្រើប្រាស់**

ទម្រង់បែបបទសម្រាប់ប្រើប្រាស់រួមមាន ៖

- តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១៦តពខ)
- តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ)
- កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១១ខ)
- ពាក្យបណ្ដឹង (ទ.១២០២)។

ខ. នីតិវិធីនៃការត្រួតពិនិត្យ

បន្ទាប់ពីបានអនុវត្តកិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពីគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ចំណុះរាជធានី ខេត្តរួចរាល់សព្វគ្រប់ហើយ គធ.ខប ត្រូវណែនាំក្រុមត្រួតពិនិត្យឱ្យបន្តអនុវត្តត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាបន្តទៀត ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីនៃការត្រួតពិនិត្យបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងចំណុច ១ នៃចំណុច VI ខាងលើនេះ លើកលែងតែការបំពេញទម្រង់បែបបទសម្រាប់ការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតត្រូវអនុវត្តនីតិវិធីដោយឡែក ក្នុងនោះប្រធានក្រុម ត្រូវ ៖

- ធានាថា តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ) ត្រូវបានបំពេញត្រឹមត្រូវដោយផ្អែកលើតួលេខក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ខ) តាមការិយាល័យបោះឆ្នោតនីមួយៗ។ ទន្ទឹមនេះចាត់ចែងសមាជិកក្រុមគណនាសរុបតួលេខលទ្ធផលដែលបានស្រង់ដាក់ក្នុងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) ដោយធ្វើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង បន្ទាប់មកផ្ទៀងផ្ទាត់លទ្ធផលគ្នា និងកត់ត្រាទិន្នន័យ និងតួលេខទាំងនេះទៅក្នុងតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១៦តពខ)
- ណែនាំលេខាធិការឱ្យបោះពុម្ពកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១១ខ) ចំនួន ៣ច្បាប់ ដោយផ្អែកលើតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) និងតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១៦តពខ)
- ធានាថាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១៦តពខ) តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) និងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១១ខ) ត្រូវបានដាក់ភ្ជាប់ជាមួយនឹងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ខ) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ខ) ត្រៀមដាក់ជូន គធ.ខប ពិនិត្យ និងសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។

<u>សម្គាល់</u>៖ គធ.ខប ត្រូវណែនាំប្រធានក្រុមត្រួតពិនិត្យ ឱ្យថតកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ខ) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ខ) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២ខ) ត្រៀម សម្រាប់ផ្ញើជូន គ.ជ.ប។

៣. ការពិនិត្យ និងសម្រេចលើតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៦ត៣) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១១) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ) ដោយ គធ.ខប

ប្រធាន គធ.ខប ត្រូវពិនិត្យសម្រេចលើ ទ.១១១៦ត៣ ទ.១១១១ តាមប្រភេទក្រុមប្រឹក្សានីមួយៗ និង ទ.១១១០ខ ដែលក្រុមត្រួតពិនិត្យបានដាក់ជូន ហើយប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវផ្ដល់ការយល់ព្រម រួចចុះហត្ថលេខា ឈ្មោះបោះត្រា គធ.ខប ចុះកាលបរិច្ឆេទ និងដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។

តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខាជាសាក្សីលើ ទ.១១១១ស និង ទ.១១១១ខ។ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនេះ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។

៤. ការប្រើប្រាស់តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៦ត៣) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១១) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១០ខ)

គធ.ខប ត្រូវចាត់ចែងប្រើប្រាស់ ដូចខាងក្រោម ៖

- តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) ចំនួន ២ច្បាប់

ទ.១១១០ខ ចំនួន ២ច្បាប់
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ទុកជាឯកសារនៅ គធ.ខប ។

- តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៦ត៣ខ) និងតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៦ត៣ស) ចំនួន ២ច្បាប់

ទ.១១១៦ត៣ខ និង ទ.១១១៦ត៣ស ចំនួន ២ច្បាប់
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ទុកជាឯកសារ គធ.ខប និងប្រើសម្រាប់កំណត់ចំនួនអាសនៈ។

- កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១១ខ និង ទ.១១១១ស) ចំនួន ៣ច្បាប់។

ទ.១១១១ខ និង ទ.១១១១ស ចំនួន ៣ច្បាប់
- ១ច្បាប់ បិទផ្សាយនៅ លគធ.ខប អមជាមួយកំណត់ហេតុស្ដីពីការបិទផ្សាយ
- ១ច្បាប់ ផ្ញើជូន គ.ជ.ប
- ១ច្បាប់ ទុកជាឯកសារនៅ គធ.ខប និងប្រើសម្រាប់កំណត់ចំនួនអាសនៈ។

<u>សម្គាល់</u>៖ ប្រធាន គធ.ខប អាចថតចម្លង ទ.១១១១ខ និង ទ.១១១១ស សម្រាប់ចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ១ច្បាប់ៗ តាមការស្នើសុំ។

## VII. ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

### ១. ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សាសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោត រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

បន្ទាប់ពីបានអនុវត្តកិច្ចដំណើរការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ បានធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក» (ប្រសិនបើមាន) និងបានដោះស្រាយពាក្យបណ្ដឹងនៅថ្នាក់របស់ខ្លួនរួចរាល់សព្វគ្រប់ ប្រធាន គជ.ខប ត្រូវចាត់ចែងកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឱ្យហើយរួចរាល់ បន្ទាប់មកត្រូវអនុវត្តកំណត់ចំនួនអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានីខេត្តជាបន្តទៀត ដូចខាងក្រោមៈ

- ក្នុងការគណនា និងកំណត់ចំនួនអាសនៈ ក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ឬមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ប្រធានក្រុមកំណត់ចំនួនអាសនៈ ត្រូវៈ

*ប្រធានក្រុមត្រូវ* ⇨

- *ចាត់ចែងសមាជិកក្រុមឱ្យផ្ទេរទិន្នន័យពីកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១១ស) បញ្ចូលទៅក្នុងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទ.១១១៤ស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១១ខ) បញ្ចូលទៅក្នុងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត (ទ.១១១៤ខ) តាមប្រព័ន្ធកុំព្យូទ័រ*
- *អនុវត្តកម្មវិធីបែងចែកអាសនៈ និងបញ្ជាកម្មវិធីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់ក្រុមប្រឹក្សាពាក់ព័ន្ធ ហើយលេខាធិការក្រុមត្រូវបោះពុម្ពលទ្ធផលទាំងនេះ ១ច្បាប់*
- *ចាត់សមាជិកដទៃធ្វើប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ តាមរូបមន្តនៃការបែងចែកអាសនៈ ដូចបានកំណត់ក្នុង ប.ន.ក*
- *ចាត់សមាជិកក្រុមឱ្យសហការគ្នាផ្ទៀងផ្ទាត់ និងគណនាឡើងវិញតាមរូបមន្តនៃការបែងចែកអាសនៈ ប្រសិនបើលទ្ធផលនៃការគណនាតាមរូបមន្តទាំង ២ ខាងលើខុសគ្នា*
- *ធានាថា ក្រដាសលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈដែលបានគណនាតាមរបៀប ទាំង ២ ខាងលើ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នាហើយ ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ។*

- ផ្អែកតាមលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈខាងលើ ប្រធានក្រុម ត្រូវ៖

| ប្រធានក្រុមត្រូវ | *- ចាត់ចែងសមាជិកក្រុមឱ្យបោះពុម្ពលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទ.១១១៤ស ឬ ទ.១១១៤ខ) ចំនួន ៣ច្បាប់ ដោយបញ្ជាក់នូវ៖*<br>▪ *ឈ្មោះគណបក្សនយោបាយឈរឈ្មោះក្នុងរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ចំនួនសំឡេងឆ្នោតគាំទ្រសរុប និងចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ ទទួលបានដោយគិតតាមលំដាប់ពីខ្ពស់មកទាប*<br>▪ *ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្នុងនោះត្រូវបញ្ជាក់ ចំពោះបេក្ខជនដែលត្រូវជាប់ជាប្រធានក្រុមប្រឹក្សាតាមប្រភេទនីមួយៗ*<br>*- ធានាថា ទ.១១១៤ស ឬ ទ.១១១៤ខ ទាំង ៣ច្បាប់ ត្រូវចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈ ព្រមទាំងរៀបចំដាក់ជូនប្រធាន គធ.ខប ពិនិត្យ និងសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។* |
|---|---|

**២. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលអាសនៈ ឬ/និងជាប្រធានក្រុមប្រឹក្សា**

**ក. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយត្រូវទទួលបានអាសនៈ**

ប្រសិនបើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាមួយ មានលទ្ធផលមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ហើយអាសនៈដែលនៅសល់មានចំនួនតិចជាង ប្រធាន គធ.ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោត ដោយផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីស្ដីពីការចាប់ឆ្នោត ដូចមានចែងក្នុងផ្នែកទី២ នៃជំពូកទី២ នៃ ប.ន.ក។ ក្នុងការចាប់ឆ្នោតនេះ ប្រធាន គធ.ខប ត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោតចំនួន ២ច្បាប់។

**ខ. ការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយត្រូវទទួលបានជាប្រធានក្រុមប្រឹក្សា**

ប្រសិនបើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាមួយ មានលទ្ធផលសំឡេងឆ្នោតស្មើគ្នា និងចំនួនអាសនៈស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ប្រធាន គធ.ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោត ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលបានជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ដោយផ្អែកតាមនីតិវិធីដូចមានចែងក្នុងផ្នែកទី២ នៃជំពូកទី២ នៃ ប.ន.ក។ ក្នុងការចាប់ឆ្នោតនេះ ប្រធាន គធ.ខប ត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោតចំនួន ២ច្បាប់។

| កំណត់ហេតុ ចំនួន ២ច្បាប់ | - ១ច្បាប់ ដាក់ក្នុងកញ្ចប់ «យ$_{ស}$ ពិសេស» ឬកញ្ចប់ «យ$_{ខ}$ ពិសេស» ផ្ញើជូន គ.ជ.ប<br>- ១ច្បាប់ រក្សាទុកជាឯកសារ គធ.ខប។ |
|---|---|

៣. ការពិនិត្យសម្រេច និងប្រើប្រាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១៩) ដោយ គធ.ខប

ប្រធាន គធ.ខប ពិនិត្យ សម្រេចលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៩ស) ឬលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៩ខ) រួចចុះហត្ថលេខា បោះត្រា គធ.ខប ព្រមទាំងដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។ ប្រធាន គធ.ខប ត្រូវចាត់ចែងប្រើប្រាស់ ដូចខាងក្រោម៖

ទ.១១១៩ស ឬ ទ.១១១៩ខ ចំនួន ៣ច្បាប់
- ២ច្បាប់ ច្រកក្នុងស្រោមសំបុត្រដែលមានកាខ្ទងថា «លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ លេខកូដ... (បំពេញលេខកូដរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ) ផ្ញើជូន គ.ជ.ប
- ១ច្បាប់ រក្សាទុកជាឯកសារ គធ.ខប។

## VIII. ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅ គ.ជ.ប

ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» ស្បោង «ឃ» និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ត្រូវធ្វើចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលមានវត្តមាន ដើម្បីពួកគាត់ចូលរួមសង្កេតពិនិត្យមើល និងកត់ត្រាលេខសោឃ្លុំដែលចងស្បោង «ឃ»។

ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យ៖

+ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ច្បាប់ ចុះហត្ថលេខាសម្រាប់ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» និងស្បោង «ឃ» នីមួយៗ

ទ.១១០៧ ចំនួន ៣ច្បាប់
- ១ច្បាប់ ច្រកចូលក្នុងស្រោមសំបុត្រ រួចដាក់ក្នុងកញ្ចប់ «ឃ ពិសេស» ឬស្បោង «ឃ»
- ១ច្បាប់ ដាក់ក្នុងហោប៉ៅកញ្ចប់ «ឃ ពិសេស» ឬស្បោង «ឃ»
- ១ច្បាប់ ទុកប្រើពេលប្រគល់ ទទួលនៅ គ.ជ.ប។

+ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ច្បាប់ ចុះហត្ថលេខាសម្រាប់ការវេចខ្ចប់កញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់

ទ.១១០៧ ចំនួន ២ច្បាប់
- ១ច្បាប់ ច្រកចូលក្នុងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់
- ១ច្បាប់ ទុកប្រើពេលប្រគល់ ទទួលនៅ គ.ជ.ប។

១. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស»

ក. ការវេចខ្ចប់កញ្ចប់ «ឃស ពិសេស» នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់រាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតដោយឡែកៗ តាមលំដាប់លេខកូដក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្ត។

ក្នុងកញ្ចប់ «ឃស ពិសេស» មាន៖

- ស្រោមសំបុត្រតែមួយសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដាក់ ទ.១១១៦តពស ចំនួន ១ច្បាប់ ទ.១១១១ស ចំនួន ១ច្បាប់ និង ទ.១១១៩ស ចំនួន ១ច្បាប់

- រាល់ស្រោមសំបុត្រដាក់ ទ.១១០១ស ទ.១១០៨ស និង ទ.១១០២ស ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «កស» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យពាក់ព័ន្ធ (ប្រសិនបើមាន)
- ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់។

**ចំណាំ៖**

- ផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឱ្យប្រាកដថា កញ្ចប់ «ឃស ពិសេស» ត្រូវបានវេចខ្ចប់ត្រឹមត្រូវហើយ
- បិទភ្ជិតកញ្ចប់ «ឃស ពិសេស» ដោយការសុវត្ថិភាព
- សរសេរសម្គាល់ឈ្មោះ និងលេខកូដរាជធានី ឬខេត្ត និងក្រុង ឬស្រុក ឬខណ្ឌ នៅផ្នែកខាងក្រៅនៃកញ្ចប់ «ឃស ពិសេស» ដោយប៊ិកហ្វឺតលុបមិនជ្រះ។

**កញ្ចប់ "ឃស ពិសេស"**

- ស្រោមសំបុត្រដាក់ ទ.១១១៦តពស ចំនួន ១ច្បាប់ ទ.១១១១ស ចំនួន ១ច្បាប់ និង ទ.១១១៨ស ចំនួន ១ច្បាប់
- រាល់ស្រោមសំបុត្រដាក់ ទ.១១០១ស ទ.១១០៨ស និង ទ.១១០២ស ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «កស» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យពាក់ព័ន្ធ (ប្រសិនបើមាន)
- ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់។

ទ.១១០៧ ចំនួន ១ច្បាប់

ខ. ការវេចខ្ចប់កញ្ចប់ «ឃ₂ ពិសេស» នៃក្រុមប្រឹក្សារាជធានី ខេត្ត

ប្រធាន គធ.ឃប ត្រូវចាត់ចែងអនុវត្តការវេចខ្ចប់កញ្ចប់ «ឃ₂ ពិសេស» នៃក្រុមប្រឹក្សារាជធានី ខេត្ត ដែលដាក់រាល់សម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម ៖

- ស្រោមសំបុត្រតែមួយដាក់ ទ.១១១០ខ ចំនួន ១ច្បាប់ ទ.១១១៦គពខ ចំនួន ១ច្បាប់ ទ.១១១១ខ ចំនួន ១ច្បាប់ និង ទ.១១១៤ខ ចំនួន ១ច្បាប់
- រាល់ស្រោមសំបុត្រដាក់ ទ.១១០១ខ ទ.១១០៨ខ និង ទ.១១០២ខ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក₂» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឃប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន)
- ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឃប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ១ច្បាប់។

<u>ចំណាំ</u>៖

- បិទភ្ជិតកញ្ចប់ «ឃ₂ ពិសេស» ដោយការសុវត្ថិភាព
- សរសេរសម្គាល់ឈ្មោះ និងលេខកូដរាជធានី ឬខេត្ត នៅខាងក្រៅកញ្ចប់ «ឃ₂ ពិសេស» ដោយប៊ិកហ្វឺតលុបមិនជ្រះ។

**កញ្ចប់ "ឃ₂ ពិសេស"**

| | |
|---|---|
| | |

- ស្រោមសំបុត្រដាក់ ទ.១១១០ខ ចំនួន ១ច្បាប់ ទ.១១១៦គពខ ចំនួន ១ច្បាប់ ទ.១១១១ខ ចំនួន ១ច្បាប់ និង ទ.១១១៤ខ ចំនួន ១ច្បាប់
- រាល់ស្រោមសំបុត្រដាក់ ទ.១១០១ខ ទ.១១០៨ខ និង ទ.១១០២ខ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព «ក₂» ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឃប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យពាក់ព័ន្ធ (ប្រសិនបើមាន)
- ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឃប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត ទ.១១០៧ ចំនួន ១ច្បាប់។

ទ.១១០៧ ចំនួន ១ច្បាប់

២. ការវេចខ្ចប់កញ្ចប់ «ឃ ពិសេស» នៃក្រុមប្រឹក្សាដែល គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្នលទ្ធផលនៃការបោះឆ្នោត

ក្នុងករណី គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្នលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោត ដោយឡែកតាមប្រភេទក្រុមប្រឹក្សានៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ឬទាំងនោះទៅក្នុងស្រោមសំបុត្រធំ និងស្បោង «ឃ» មួយដោយឡែក៖

ក. ដាក់ក្នុងស្រោមសំបុត្រធំមួយនូវ៖

- របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព «ក$_{ស}$» ឬកញ្ចប់ «ក$_{ខ}$» ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះចំនួន ១ច្បាប់
- សម្រង់សេចក្ដីសម្រេចយល់ព្រមលើពាក្យបណ្ដឹងដែលត្រូវព្យួរជាបណ្ដោះអាសន្នលទ្ធផលបោះឆ្នោត (ទ.១២០៣) ចំនួន ១ច្បាប់
- ស្រោមសំបុត្រតែមួយដែលមានដាក់៖
  - ទ.១១១៦គពស ឬ ទ.១១១៦គពខ ចំនួន ១ច្បាប់
  - ទ.១១១១ស ឬ ទ.១១១១ខ ចំនួន ១ច្បាប់
  - ទ.១១១៤ស ឬ ទ.១១១៤ខ ចំនួន ១ច្បាប់
  - ទ.១១១០ខ ចំនួន ១ច្បាប់ (ប្រសិនពាក់ព័ន្ធក្រុមប្រឹក្សារាជធានី ខេត្ត)
- កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងចំណុច ២ នៃចំណុច VII ក្នុងសៀវភៅណែនាំនេះ (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់ ទ.១១០៧ ចំនួន ១ច្បាប់។

ខ. ដាក់ក្នុងស្បោង «ឃ$_{ស}$» ឬស្បោង «ឃ$_{ខ}$» ដោយឡែកដែលមាន៖

- ស្បោង «ខ$_{ស}$» ឬស្បោង «ខ$_{ខ}$» ផ្ទុកកញ្ចប់សុវត្ថិភាព «ក$_{ស}$» ឬកញ្ចប់សុវត្ថិភាព «ក$_{ខ}$» ដែលត្រូវបានបើក និងត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ន
- រាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតដែលត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ន។

<u>ចំណាំ៖</u>

- ផ្ទៀងផ្ទាត់ឡើងវិញ រួចចងភ្ជិតស្បោង «ឃ» ពាក់ព័ន្ធ រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅស្បោង «ឃ» នោះ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះនូវ៖
  - លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
  - ឈ្មោះរាជធានី ខេត្ត និងលេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ
  - ពាក្យថា «ព្យួរលទ្ធផល»។
- ទ.១១០៧ ចំនួន ៣ច្បាប់ ត្រូវមានបញ្ជាក់រាល់សម្ភារ ឯកសារបោះឆ្នោតនៅក្នុងស្រោមសំបុត្រធំ និងក្នុងស្បោង «ឃ» និងត្រូវប្រើប្រាស់ដូចខាងក្រោម៖

| | |
|---|---|
| ទ.១១០៧ ចំនួន ៣ច្បាប់ | - ១ច្បាប់ ច្រកចូលក្នុងស្រោមសំបុត្រធំ ឬស្បោង «ឃ»<br>- ១ច្បាប់ កិបជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ ឬស្បោង «ឃ»<br>- ១ច្បាប់ ទុកប្រើពេលប្រគល់ ទទួលនៅ គ.ជ.ប |

**គ. ការបញ្ជូនស្រោមសំបុត្រធំ និងស្បោង «យស» ឬស្បោង «យខ» ព្យួរលទ្ធផលជាបណ្ដោះអាសន្ន**

គធ.ខប ត្រូវបញ្ជូនស្រោមសំបុត្រធំ និងស្បោង «យស» ឬស្បោង «យខ» ព្យួរលទ្ធផលជាបណ្ដោះអាសន្ន និងប្រគល់ជូន គ.ជ.ប យ៉ាងយូរ ២៤ម៉ោង គឺចាប់ពីពេលដែល គធ.ខប បានចេញសម្រង់សេចក្ដីសម្រេចយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលត្រូវព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត។

**ស្រោមសំបុត្រធំ**

**សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យលេខ**

☐☐ ☐☐☐☐ ☐☐☐☐

- *របាយការណ៍បើកកញ្ចប់សុវត្ថិភាព "កស" ឬ "កខ" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ចំនួន ១ច្បាប់*
- *ស្រោមសំបុត្រដាក់ ទ.១២០៣ របស់ គធ.ខប បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ចំនួន ១ច្បាប់*
- *ស្រោមសំបុត្រដាក់៖*
  - *ទ.១១១៦តពស ឬ ទ.១១១៦តពខ ចំនួន ១ច្បាប់*
  - *ទ.១១១១ស ឬ ទ.១១១១ខ ចំនួន ១ច្បាប់*
  - *ទ.១១១៤ស ឬ ទ.១១១៤ខ ចំនួន ១ច្បាប់*
  - *ទ.១១១០ខ ចំនួន ១ច្បាប់(សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត)*
- *ស្រោមសំបុត្រដាក់ ទ.១១០៧ ចំនួន ១ច្បាប់។*

*ទ.១១០៧ ចំនួន ១ច្បាប់*




**៣. ការវេចខ្ចប់ស្បោង «យស» និងស្បោង «យខ»**

ការិយាល័យបោះឆ្នោតទាំងឡាយណាក្នុងរាជធានី ខេត្ត ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់រាល់ស្បោង «ខស» ឬស្បោង «ខខ» ផ្ទុកកញ្ចប់សុវត្ថិភាព «កស» ឬកញ្ចប់សុវត្ថិភាព «កខ» និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទាំងនោះ ដាក់ក្នុងស្បោង «យស» និងស្បោង «យខ» តាមប្រភេទក្រុមប្រឹក្សា រួចពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឱ្យប្រាកដថា ក្នុងស្បោង «យស» និងស្បោង «យខ» នោះបានវេចខ្ចប់ត្រឹមត្រូវហើយ ទើបចងភ្ជិតចាក់សោឃ្លុំមានលេខ និងសរសេរខាងក្រៅស្បោង «យស» និងស្បោង «យខ» ដោយប៊ិកហ្វឺតលុបមិនជ្រះនូវលេខរៀងស្បោង «យស» និងស្បោង «យខ» នូវលេខកូដរាជធានី ខេត្ត ព្រមទាំងពាក្យ «ពិនិត្យរួច»។




ចំពោះការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តណាមួយ មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ដែលមាន ឬគ្មានការបើកកញ្ចប់សុវត្ថិភាព «ក» ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធាន គថ.ខប ត្រូវចាត់ចែងវេចខ្ចប់រាល់ស្បោង «ខ» ផ្ទុកកញ្ចប់សុវត្ថិភាព «ក» និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទាំងនោះ តាមប្រភេទក្រុមប្រឹក្សាពាក់ព័ន្ធ ដាក់ក្នុងស្បោង «ឃ» ពាក់ព័ន្ធ រួចពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដើម្បីឱ្យប្រាកដថា ក្នុងស្បោង «ឃ» នោះបានវេចខ្ចប់ត្រឹមត្រូវហើយ ទើបចងភ្ជិតចាក់សោឃ្លុំមានលេខ និងសរសេរខាងក្រៅស្បោង «ឃ» ដោយប៊ិកហ្វឺតលុបមិនជ្រះ នូវលេខរៀងស្បោង «ឃ» នូវលេខកូដរាជធានី ខេត្ត ព្រមទាំងពាក្យ «មានពាក្យបណ្តឹង» ។



ចំណាំ៖ ប្រសិនបើស្បោង «ឃ» មានចំនួនលើសពីមួយ ប្រធាន គធ.ឱប ត្រូវចាត់ចែងសរសេរសម្គាល់លេខរៀងនៅលើស្បោង «ឃ» ទាំងនោះ។ ឧទាហរណ៍ ប្រសិនបើស្បោង «ឃ» មានចំនួន ៣ ត្រូវសរសេរថា ១/៣ ២/៣ និង ៣/៣។

៤. **ការវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់**

រាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបម្រុង និងកេស ឬស្បោង ឬកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ត្រូវតែបានបំពេញក្នុង (ទ.១១០៧) ចំនួន ២ច្បាប់។

- រាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ចប់ដោយឡែកដើម្បីបញ្ជូនមក គ.ជ.ប។
- រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលបានទទួលពី គ.ជ.ប ត្រូវតែបានវេចខ្ចប់ដោយដាក់ក្នុងកេស ឬស្បោង ឬកញ្ចប់ទៅតាមសភាពជាក់ស្តែង។

៥. **ការបញ្ជូនកញ្ចប់ «ឃ ពិសេស» ស្បោង «ឃ» និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គ.ជ.ប**

ការបញ្ជូនកញ្ចប់ «ឃ ពិសេស» ស្បោង «ឃ» និងផ្ទុកសម្ភារ ឯកសារបោះឆ្នោតនៅសល់ គធ.ឱប ត្រូវបញ្ជូនព្រមពេលជាមួយគ្នាទៅ គ.ជ.ប នៅថ្ងៃទី៥ បន្ទាប់ពីថ្ងៃបោះឆ្នោត។

## IX. ការបោះឆ្នោតសាជាថ្មី

១. **ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន**

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខសាធារណៈ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះបាន។

ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ដូចជាករណីមួយក្នុងចំណោមករណីខាងក្រោម៖

- ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងៗ
- អសន្តិសុខជាសាធារណៈ
- ការដួលរលំអគារ សម្រាប់ការបោះឆ្នោតដោយយថាហេតុណាមួយ ឬអគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់
- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន
- ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ក. **ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងមុនថ្ងៃបោះឆ្នោត**

ក្រោយទទួលបានសេចក្តីរាយការណ៍ពី គ.ក.ប គធ.ឱប ត្រូវ៖

- ពិនិត្យ និងវាយតម្លៃសភាពការណ៍ឱ្យបានច្បាស់លាស់
- ផ្តល់យោបល់ និងរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប ដើម្បី គ.ជ.ប សម្រេចអំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោតនោះ។

ក្រោយទទួលបានការសម្រេចពី គ.ជ.ប គធ.ឱប ត្រូវជូនដំណឹងជាបន្ទាន់ទៅ គ.ក.ប ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.ប។

ខ. **ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងនៅថ្ងៃបោះឆ្នោត**

ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងនៅថ្ងៃបោះឆ្នោត បន្ទាប់ពីទទួលបានរបាយការណ៍អំពីការសម្រេចបិទការិយាល័យបោះឆ្នោតពីប្រធាន គ.ក.ប គធ.ឱប ត្រូវ៖

- រាយការណ៍ជាបន្ទាន់អំពីករណីនេះទៅ គ.ជ.ប
- រៀបចំចាត់ចែងអនុវត្តការងារទៅតាមនីតិវិធីដែលមានចែងក្នុង ប.ន.ក។

ចំណាំ៖

- ការរាយការណ៍ ឬការជូនដំណឹងជាបន្ទាន់ ត្រូវធ្វើឡើងតាមរយៈទូរសព្ទ ទូរសារ វិទ្យុទាក់ទង ឬអ៊ីមែល
- ការិយាល័យបោះឆ្នោតដែលមិនបានបើក ឬសម្រេចបិទនៅថ្ងៃបោះឆ្នោតដោយ គ.ជ.ប ឬ គ.ក.ប ដែលបានប្រគល់សិទ្ធិត្រូវតែបិទរហូតពេញមួយថ្ងៃ
- សមាសភាព គ.ក.ប ដែលមិនត្រូវបានបើក ឬ/និងដែលត្រូវបានបិទ នឹងត្រូវរំសាយ ស្របតាមកិច្ចសន្យា បន្ទាប់ពីបានប្រគល់សម្ភារ ឯកសារបោះឆ្នោតជូន គធ.ខប។

**២. ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និងដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ឬ/និងលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គ.ជ.ប**

ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទ ឬដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គ.ជ.ប នឹងត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេលយ៉ាងយូរ ៨ថ្ងៃ បន្ទាប់ពីថ្ងៃកើតមានករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ឬដែល គ.ជ.ប ប្រកាសបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីនៅទីតាំងដដែល ឬទីតាំងណាមួយនៅទីប្រជុំជនរាជធានី ខេត្ត ដែល គ.ជ.ប យល់ថាមានសន្តិសុខ និងសុវត្ថិភាពល្អ។

បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវយកមកប្រើប្រាស់ក្នុងការបោះឆ្នោតសាជាថ្មី។ គធ.ខប និង គ.ក.ប ពាក់ព័ន្ធ ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតនេះនៅ ១ថ្ងៃមុនថ្ងៃបោះឆ្នោត។

បញ្ជីបោះឆ្នោត ចំនួន ៤ច្បាប់
- ១ច្បាប់ បិទផ្សាយនៅ លគធ.ខប
- ១ច្បាប់ បិទផ្សាយនៅទីកន្លែងណាមួយក្នុងទីប្រជុំជនរាជធានី ខេត្ត
- ១ច្បាប់ បិទផ្សាយនៅទីតាំងការិយាល័យបោះឆ្នោត
- ១ច្បាប់ សម្រាប់ប្រើនៅពេលបោះឆ្នោត។

សមាសភាពភ្នាក់ងារគណបក្សនយោបាយ ដែលត្រូវចូលរួមសង្កេតមើលដំណើរការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី។

សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវបោះពុម្ពតាមគំរូសន្លឹកឆ្នោតលើកមុនសម្រាប់មណ្ឌលពាក់ព័ន្ធ និងនៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងមានចំនួនគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។

ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតត្រូវហាមឃាត់។

នីតិវិធីនៃការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តនីតិវិធីនៃការបោះឆ្នោតដែលបានបញ្ញត្តក្នុង ប.ន.ក ដោយឡែកតែការជ្រលក់ទឹកខ្មៅលុបមិនជ្រះដែលត្រូវធ្វើលើម្រាមដៃឆ្វេង។

ក្នុងចន្លោះពេលពីដំណើរការនៃការបោះឆ្នោតសាជាថ្មីរហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តដូចគ្នានឹងការកំណត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដូចមានចែងក្នុង ប.ន.ក៕

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# កំណត់ហេតុនៃការបោះឆ្នោត (ឆ.១១០១ស)

គំរូត្រាសម្ងាត់

## ១~ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដក្រុង ស្រុក ខណ្ឌ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

## ២~ សមាសភាពនៃគណៈកម្មការការិយាល័យបោះឆ្នោត (បំពេញឈ្មោះ)

| | | | |
|---|---|---|---|
| ប្រធាន | | សមាជិកទី១ | |
| អនុប្រធាន | | សមាជិកទី២ | |
| លេខាធិការ | | សមាជិកទី៣ | |

## ៣~ សមាសភាពភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មានវត្តមានពេលបើកការបោះឆ្នោត

| ល.រ | គោត្តនាម និងនាមខ្លួន | អង្គភាព | ល.រ | គោត្តនាម និងនាមខ្លួន | អង្គភាព |
|---|---|---|---|---|---|
| ១ | | | ៦ | | |
| ២ | | | ៧ | | |
| ៣ | | | ៨ | | |
| ៤ | | | ៩ | | |
| ៥ | | | ១០ | | |

## ៤~ សម្ភារ ឯកសារសម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត

សម្ភារឯកសារសម្រាប់ការិយាល័យបោះឆ្នោតនេះ ត្រូវបានទទួលទាំងអស់ ☐ ឬមួយផ្នែក ☐ ឬមិនបានទទួល ☐ ។ សម្ភារឯកសារដែលមិនបានទទួលមាន៖........................................................................................................................................

## ៥~ ចំនួនអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត

| | |
|---|---|
| អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះមានចំនួន | នាក់ |

## ៦~ ការបោះឆ្នោត

នៅចន្លោះម៉ោង......................ដល់......................ព្រឹកនៃថ្ងៃបោះឆ្នោត នៅចំពោះមុខអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត ប្រធានរៀបចំត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតតាមការណែនាំ រួចបិទគម្របខាងក្នុង និងចាក់សោឃ្មុំពណ៌..................និងលេខ..............................។ អនុប្រធានពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលទទួលជាក់ស្ដែង (**ត្រូវរាប់ជាចាំបាច់**) ដែលមានចំនួន និងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកចុងក្រោយនៃក្បាលចុងក្រោយដូចខាងក្រោម៖

| | | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតបានទទួលជាក់ស្ដែង | សន្លឹក | លេខរៀងពី ដល់ |

**កំណត់សម្គាល់ករណីចំនួនសន្លឹកឆ្នោតតិចជាង ឬច្រើនជាងចំនួនត្រូវផ្ដល់ជូន៖** ..................................................................
........................................................................................................................................
........................................................................................................................................
........................................................................................................................................

បន្ទាប់មក ប្រធានបើកស្រោមសំបុត្រ ដកយកត្រាសម្ងាត់សម្រាប់បោះលើផ្នែកខាងខ្នងនៃសន្លឹកឆ្នោត មកបោះសាកល្បងលើក្រដាសធម្មតា ដើម្បីបង្ហាញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ពិនិត្យរូបសញ្ញានៃត្រានោះសម្រាប់ជាការសម្គាល់ ។ ប្រធានប្រកាសបើកការបោះឆ្នោតនៅម៉ោង..................ព្រឹក កិច្ចប្រតិបត្តិការបោះឆ្នោតបានប្រព្រឹត្តទៅ តាមសម្រួល ☐ ឬមានបញ្ហាបន្តិចបន្តួច ☐ ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ☐ ។ នៅម៉ោង ៣:០០ រសៀល អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យនេះបានបោះឆ្នោតរួចរាល់ ☐ ឬមានអ្នកបោះឆ្នោតចំនួន.....................នាក់កំពុងឈរក្នុងជួរនៅបរិវេណខាងក្នុងរង់ចាំការបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានឈ្មោះនៅសល់ក្នុងបញ្ជីបោះឆ្នោតគ្មានវត្តមាននៅម៉ោង ៣:០០ រសៀល ☐ ។

ទម្រង់បែបបទ ១១០១ស សម្រាប់បំពេញដោយ គ.ក.ប ១

**កំណត់សម្គាល់ពាក់ព័ន្ធនឹងភាពមិនប្រក្រតីផ្សេងៗ ឬ/និងការជំទាស់ក្នុងអំឡុងពេលបោះឆ្នោត (ប្រសិនបើមាន) ៖....................**

......................................................................................................................................................................

......................................................................................................................................................................

### ៧~ ការបិទការបោះឆ្នោត ការផ្ទៀងផ្ទាត់ និងការបំពេញតួលេខទាក់ទងនឹងការបោះឆ្នោត

នៅម៉ោង..................រសៀល ប្រធានប្រកាសបិទការបោះឆ្នោត។ ប្រធានបិទភ្ជិតសន្ទះប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរ និងបិទពាស ក្រដាសស្អិតមួយសន្លឹកដែលមានចុះហត្ថលេខាប្រធាន និងសាក្សីដែលជាភ្នាក់ងារគណបក្សនយោបាយ។ បន្ទាប់មក ប្រធានបិទគម្របខាងក្រៅនៃហិបឆ្នោត ហើយចាក់សោឃុំពីរនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត។

| | | | |
|---|---|---|---|
| ភិនភាគសោឃុំទាំងពីរ | ពណ៌ | លេខ | និងលេខ |

អនុប្រធានបានរាប់សន្លឹកឆ្នោតខូចពេលបោះឆ្នោតបើមាន ( ខ ) និងសន្លឹកឆ្នោតដែលមិនបានប្រើ ( គ ) មានចំនួន៖

| | | | |
|---|---|---|---|
| ខ) ចំនួនសន្លឹកឆ្នោតខូចពេលបោះឆ្នោត (បើមាន) | សន្លឹក | គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | សន្លឹក |

សមាជិកទី២ បានចោះ ឬកាត់សន្លឹកឆ្នោតដែលនៅសល់មិនបានប្រើទាំងអស់ដើម្បីធ្វើមោឃភាព ☐ ។

លេខាធិការបានរាប់ចំនួនគំនូសក្នុងកូនប្រអប់លើបញ្ជីបោះឆ្នោត បញ្ជាក់អ្នកបោះឆ្នោតដែលបានបោះឆ្នោត និងរាប់ចំនួនក្រដាស់ព័ត៌មានអ្នកអះអាងមិនបោះឆ្នោត (ទ.១១០៤) ដែលបានអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (បើមាន) មានចំនួន......................។

| | |
|---|---|
| ឃ) អ្នកបោះឆ្នោតដែលបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | នាក់ |
| ច) ចំនួនគំនូសលើបញ្ជីបោះឆ្នោតបញ្ជាក់អ្នកបានមកបោះឆ្នោត | នាក់ |
| ឆ) ចំនួនអ្នកបោះឆ្នោតដែលបានអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | នាក់ |

- តួលេខដែលត្រូវបំពេញក្នុងចំណុច ក ខ គ ឃ ច និង ឆ ខាងលើត្រូវផ្អែកលើចំនួនដែលមាន ឬ/និងពិនិត្យឃើញជាក់ស្តែង
- ជាធម្មតា ឃ = ក - ( ខ + គ ) = ច - ឆ

**សម្គាល់៖** ប្រធាន គ.ក.ប ត្រូវចាត់លេខាធិការបោះត្រាសម្ងាត់នៅលើជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ។

### ៨~ ការជំទាស់ និងការមិនយល់ព្រមតាមការដោះស្រាយលើការជំទាស់

| | | | |
|---|---|---|---|
| ការជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការមិនយល់ព្រមតាមការដោះស្រាយលើការជំទាស់ | | | ករណី |
| ការជំទាស់ដែលបានដោះស្រាយ | ករណី | ការតវ៉ា និងការជំទាស់ដែលអាចនឹងប្តឹងទៅ គធ.ខប | ករណី |

### ៩~ សោឃុំដែលនឹងត្រូវចាក់ភ្ជាប់នឹងមាត់ស្បោង " ខ៨ "

សោឃុំដែលនឹងត្រូវចាក់ភ្ជាប់នឹងមាត់ស្បោង " ខ៨ " មានពណ៌.............................. និងលេខ...................................។

កាលបរិច្ឆេទ៖........../ .......... /..........

**ជ.គណៈកម្មការការិយាល័យបោះឆ្នោត**

**ប្រធាន** លេខាធិការ...........................

ត្រា

### ១០~ សាក្សី ៖ ភ្នាក់ងារគណបក្សនយោបាយ

| ល.រ | គោត្តនាមនិងនាមខ្លួន | គណបក្សនយោបាយ | ហត្ថលេខា | ល.រ | គោត្តនាមនិងនាមខ្លួន | គណបក្សនយោបាយ | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១ | | | | ៦ | | | |
| ២ | | | | ៧ | | | |
| ៣ | | | | ៨ | | | |
| ៤ | | | | ៩ | | | |
| ៥ | | | | ១០ | | | |

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## កំណត់ហេតុនៃការបោះឆ្នោត (ឧ.១១០១ខ)

គំរូត្រាសម្ងាត់

### ១~ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដក្រុង ស្រុក ខណ្ឌ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

### ២~ សមាសភាពនៃគណៈកម្មការការិយាល័យបោះឆ្នោត (បំពេញឈ្មោះ)

| | | | |
|---|---|---|---|
| ប្រធាន | | សមាជិកទី១ | |
| អនុប្រធាន | | សមាជិកទី២ | |
| លេខាធិការ | | សមាជិកទី៣ | |

### ៣~ សមាសភាពភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មានវត្តមានពេលបើកការបោះឆ្នោត

| ល.រ | គោត្តនាម និងនាមខ្លួន | អង្គភាព | ល.រ | គោត្តនាម និងនាមខ្លួន | អង្គភាព |
|---|---|---|---|---|---|
| ១ | | | ៦ | | |
| ២ | | | ៧ | | |
| ៣ | | | ៨ | | |
| ៤ | | | ៩ | | |
| ៥ | | | ១០ | | |

### ៤~ សម្ភារ ឯកសារសម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត

សម្ភារឯកសារសម្រាប់ការិយាល័យបោះឆ្នោតនេះ ត្រូវបានទទួលទាំងអស់ ☐ ឬមួយផ្នែក ☐ ឬមិនបានទទួល ☐ ។ សម្ភារឯកសារដែលមិនបានទទួលមាន៖.............................................................................................................................

### ៥~ ចំនួនអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត

| | |
|---|---|
| អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះមានចំនួន | នាក់ |

### ៦~ ការបោះឆ្នោត

នៅចន្លោះម៉ោង......................ដល់......................ព្រឹកនៃថ្ងៃបោះឆ្នោត នៅចំពោះមុខអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត ប្រធានរៀបចំត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតតាមការណែនាំ រួចបិទគម្របខាងក្នុង និងចាក់សោឃ្លុំពណ៌..................និងលេខ.............................។ អនុប្រធានពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តដែលទទួលជាក់ស្តែង **(ត្រូវរាប់ជាចាំបាច់)** ដែលមានចំនួន និងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកចុងក្រោយនៃក្បាលចុងក្រោយដូចខាងក្រោម៖

| | | |
|---|---|---|
| ក) ចំនួនសន្លឹកឆ្នោតបានទទួលជាក់ស្តែង | សន្លឹក | លេខរៀងពី ដល់ |

**កំណត់សម្គាល់ករណីចំនួនសន្លឹកឆ្នោតតិចជាង ឬច្រើនជាងចំនួនត្រូវផ្តល់ជូន** ÷...........................................................
.............................................................................................................................
.............................................................................................................................
.............................................................................................................................

បន្ទាប់មក ប្រធានបើកស្រោមសំបុត្រ ដកយកត្រាសម្ងាត់សម្រាប់បោះលើផ្នែកខាងខ្នងនៃសន្លឹកឆ្នោត មកបោះសាកល្បងលើក្រដាសធម្មតា ដើម្បីបង្ហាញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ពិនិត្យរូបសញ្ញានៃត្រានោះសម្រាប់ជាការសម្គាល់ ។ ប្រធានប្រកាសបើកការបោះឆ្នោតនៅម៉ោង................ព្រឹក កិច្ចប្រតិបត្តិការបោះឆ្នោតបានប្រព្រឹត្តទៅ តាមសម្រួល ☐ ឬមានបញ្ហាបន្តិចបន្តួច ☐ ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ☐ ។ នៅម៉ោង ៣:០០ រសៀល អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យនេះបានបោះឆ្នោតរួចរាល់ ☐ ឬមានអ្នកបោះឆ្នោតចំនួន.................នាក់កំពុងឈរក្នុងជួរនៅបរិវេណខាងក្នុងរង់ចាំការបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានឈ្មោះនៅសល់ក្នុងបញ្ជីបោះឆ្នោតគ្មានវត្តមាននៅម៉ោង ៣:០០ រសៀល ☐ ។

ទម្រង់បែបបទ ១១០១ខ សម្រាប់បំពេញដោយ គ.ក.ប ១

**កំណត់សម្គាល់ពាក់ព័ន្ធនឹងភាពមិនប្រក្រតីផ្សេងៗ ឬ/និងការជំទាស់ក្នុងអំឡុងពេលបោះឆ្នោត (ប្រសិនបើមាន) ÷....................**

..............................................................................................................................................................................

..............................................................................................................................................................................

## ៧~ ការបិទការបោះឆ្នោត ការផ្ទៀងផ្ទាត់ និងការបំពេញតួលេខទាក់ទងនឹងការបោះឆ្នោត

នៅម៉ោង..................រសៀល ប្រធានប្រកាសបិទការបោះឆ្នោត។ ប្រធានបិទភ្ជិតសន្ទះប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរ និងបិទពាសក្រដាសស្តើងមួយសន្លឹកដែលមានចុះហត្ថលេខាប្រធាន និងសាក្សីដែលជាភ្នាក់ងារគណបក្សនយោបាយ។ បន្ទាប់មក ប្រធានបិទគម្របខាងក្រៅនៃហិបឆ្នោត ហើយចាក់សោឃ្លុំពីរនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត។

| | | | |
|---|---|---|---|
| ភិនភាគសោឃ្លុំទាំងពីរ | ពណ៌ | លេខ | និងលេខ |

អនុប្រធានបានរាប់សន្លឹកឆ្នោតខូចពេលបោះឆ្នោតបើមាន ( ខ ) និងសន្លឹកឆ្នោតដែលមិនបានប្រើ ( គ ) មានចំនួន៖

| | | | |
|---|---|---|---|
| ខ) ចំនួនសន្លឹកឆ្នោតខូចពេលបោះឆ្នោត(បើមាន) | សន្លឹក | គ) ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ | សន្លឹក |

សមាជិកទី២ បានចោះ ឬកាត់សន្លឹកឆ្នោតដែលនៅសល់មិនបានប្រើទាំងអស់ដើម្បីធ្វើមោឃភាព ☐ ។

លេខាធិការបានរាប់ចំនួនគំនូសក្នុងកូនប្រអប់លើបញ្ជីបោះឆ្នោត បញ្ជាក់អ្នកបោះឆ្នោតដែលបានបោះឆ្នោត និងរាប់ចំនួនក្រដាសព័ត៌មានអ្នកអះអាងមិនបោះឆ្នោត (ទ.១១០៤) ដែលបានអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (បើមាន) មានចំនួន......................។

| | |
|---|---|
| ឃ) អ្នកបោះឆ្នោតដែលបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត | នាក់ |
| ច) ចំនួនគំនូសលើបញ្ជីបោះឆ្នោតបញ្ជាក់អ្នកបានមកបោះឆ្នោត | នាក់ |
| ឆ) ចំនួនអ្នកបោះឆ្នោតដែលបានអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត | នាក់ |

- តួលេខដែលត្រូវបំពេញក្នុងចំណុច ក ខ គ ឃ ច និង ឆ ខាងលើត្រូវផ្អែកលើចំនួនដែលមាន ឬ/និងពិនិត្យឃើញជាក់ស្តែង
- ជាធម្មតា ឃ = ក - ( ខ + គ ) = ច - ឆ

**សម្គាល់៖** ប្រធាន គ.ក.ប ត្រូវចាត់លេខាធិការបោះត្រាសម្ងាត់នៅលើជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ។

## ៨~ ការជំទាស់ និងការមិនយល់ព្រមតាមការដោះស្រាយលើការជំទាស់

| | | | |
|---|---|---|---|
| ការជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការមិនយល់ព្រមតាមការដោះស្រាយលើការជំទាស់ | | | ករណី |
| ការជំទាស់ដែលបានដោះស្រាយ | ករណី | ការតវ៉ា និងការជំទាស់ដែលអាចនឹងប្តឹងទៅ គជ.ខប | ករណី |

## ៩~ សោឃ្លុំដែលនឹងត្រូវចាក់ភ្ជាប់នឹងមាត់ស្បោង " ខ៦ "

សោឃ្លុំដែលនឹងត្រូវចាក់ភ្ជាប់នឹងមាត់ស្បោង " ខ៦ " មានពណ៌.............................. និងលេខ...................................។

កាលបរិច្ឆេទ៖........../ .......... /..........

**៩.គណៈកម្មការការិយាល័យបោះឆ្នោត**

**ប្រធាន** លេខាធិការ...........................

ត្រា

## ១០~ សាក្សី ÷ ភ្នាក់ងារគណបក្សនយោបាយ

